ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា



# របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនៅកម្ពុជា

រៀបចំដោយ

គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ខែមីនា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនៅកម្ពុជា


រៀបចំដោយ

គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា



ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ខែមីនា ឆ្នាំ២០២២

# អារម្ភកថា

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលសម្រេចបាននូវមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន និងចីរភាព ។ អត្រាកំណើនសេដ្ឋកិច្ចក្នុងរយៈពេលជាងពីរទសវត្សរ៍ ជាមធ្យមប្រមាណ ៧.៧% បានបញ្ជាក់អំពីវឌ្ឍនភាពល្អប្រសើរក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា ។ លើមូលដ្ឋាននេះ កម្ពុជាត្រូវបានក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៦ និងត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចក្នុងឆ្នាំ២០២១ ។ ទោះជាយ៉ាងនេះក្តី អត្រាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ បានថយចុះក្នុងកម្រិតអវិជ្ជមាន -៣.១% ក្នុងឆ្នាំ ២០២០ ដោយសារផលប៉ះពាល់ពីជំងឺកូវីដ-១៩ មុននឹងកើនឡើងដល់ ៣% ក្នុងឆ្នាំ ២០២១ ។

ការរីករាលដាលនៃជំងឺកូវីដ-១៩ នាចុងឆ្នាំ២០១៩ បានបង្កើតបញ្ហាប្រឈមដល់សុខភាពសាធារណៈ និងសេដ្ឋកិច្ចសកល ។ នៅពេលដែលជំងឺកូវីដ-១៩ បានរីករាលដាលក្នុងកម្រិតខុសៗគ្នា ដល់ប្រទេសជាច្រើនលើសកលលោក, លទ្ធភាពឆ្លើយតបទៅនឹងវិបត្តិនេះបានក្លាយជាមធ្យោបាយ សម្រាប់វាស់វែងសមត្ថភាពរបស់រដ្ឋាភិបាលនីមួយៗ ។ ព្រះរាជាណាចក្រកម្ពុជាក៏ទទួលរងផលប៉ះពាល់អវិជ្ជមានពីការរីករាលដាលនៃជំងឺកូវីដ-១៩ នេះដែរ ។ ទោះបីឥទ្ធិពលនៃជំងឺកូវីដ-១៩ អាចមានភាពធ្ងន់ធ្ងរ គួបផ្សំនឹងប្រភពធនធានមានកំណត់របស់កម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍន៍, កម្ពុជាបានធ្វើឱ្យសហគមន៍អន្តរជាតិមានការភ្ញាក់ផ្អើល តាមរយៈការគ្រប់គ្រងជំងឺរាតត្បាតនេះប្រកបដោយប្រសិទ្ធភាព ។

ក្នុងការឆ្លើយតបទៅនឹងផលប៉ះពាល់នៃជំងឺកូវីដ-១៩, រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវវិធានការឆ្លើយតបដែលមានលក្ខណៈជាប្រព័ន្ធ និងស្របតាមអភិក្រម "ទូទាំងសង្គម" ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺនេះ ក៏ដូចជាកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរទៅលើវិស័យគន្លឹះមួយចំនួន ។ ដោយទទួលស្គាល់អំពីតួនាទីសំខាន់របស់វ៉ាក់សាំងក្នុងការគ្រប់គ្រងស្ថានការណ៍ និងដើម្បីបញ្ចៀសការជាប់គាំងនៃដំណើរការសង្គម-សេដ្ឋកិច្ច រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវកម្មវិធីចាក់វ៉ាក់សាំងដល់ប្រជាជនទូទាំងប្រទេស នាដើម ខែកុម្ភៈ ឆ្នាំ២០២១ និងយុទ្ធនាការផ្តល់ដូសជំរុញ ដែលមានសន្ទុះលឿនគួរកត់សម្គាល់ ។ កម្ពុជាត្រូវបានទទួលស្គាល់ជាប្រទេសឈានមុខក្នុងចំណោមប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ និងប្រទេសអភិវឌ្ឍន៍ជាច្រើនលើសកលលោក ។

ទោះបីមានការផ្លាស់ប្តូរទម្រង់ក្នុងការបើកផ្តល់ហិរញ្ញប្បទាន ដោយសារការសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប និងការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច រួមជាមួយនឹងការប្រណាំងប្រជែងរបស់ប្រទេសជាដៃគូក្នុងការទទួលធនធាន ក៏ដូចជាការរឹតត្បិតរបស់ដៃគូអភិវឌ្ឍន៍ក្នុងការបើកផ្តល់ធនធានក្នុងបណ្តាឆ្នាំចុងក្រោយនេះក៏ដោយ, ក៏រំហូរនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅតែមានស្ថានភាពល្អប្រសើរនៅឡើយ ។ ក្នុងពេលដែលការបើកផ្តល់ហិរញ្ញប្បទានឥតសំណងនៅមានទំហំថេរ, ឥណទានសម្បទាន មានការកើនឡើង ទាំងទំហំដុល និងសមាមាត្រ ។ ទាំងនេះបានបង្ហាញអំពីសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការទទួល និងគ្រប់គ្រងហិរញ្ញប្បទានប្រកបដោយការប្រុងប្រយ័ត្នស្របតាមយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ។ រីឯសហគមន៍ដៃគូអភិវឌ្ឍន៍បានប្តេជ្ញាបន្តការគាំទ្រដល់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ តាមរយៈការចូលរួមក្នុងយុទ្ធនាការ

ចាក់វ៉ាក់សាំង, ការគាំទ្រដល់ការឆ្លើយតបបន្ទាន់ប្រឆាំងនឹងជំងឺកូវីដ-១៩, និងការផ្តល់ហិរញ្ញប្បទានគាំទ្រសម្រាប់ការស្តារសង្គម-សេដ្ឋកិច្ចកម្ពុជាឡើងវិញ ។ ទំហំនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការក្នុងឆ្នាំ២០២០-២០២១ បានបង្ហាញអំពីភាពជាដៃគូប្រកបដោយការជឿទុកចិត្តគ្នា និងកិច្ចប្រឹងប្រែងរួមគ្នារវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ក្នុងកាលៈទេសៈដ៏លំបាកនេះ ។

សមិទ្ធផលដ៏ត្រចះត្រចង់ទាំងនេះ បានឆ្លុះបញ្ចាំងឱ្យឃើញច្បាស់អំពីគុណវុឌ្ឍិផ្នែកនយោបាយរបស់រាជរដ្ឋាភិបាល និងទំនុកចិត្តយ៉ាងមុតមាំ និងការគាំទ្រឥតងាករេពីសំណាក់សាធារណជន ក៏ដូចជាការចូលរួមរបស់សហគមន៍អន្តរជាតិ ។ យុត្តិកម្មទាំងនេះគឺជាមូលដ្ឋានសម្រាប់រាជរដ្ឋាភិបាលរៀបចំគោលនយោបាយជាតិរយៈពេលវែង ដើម្បីក្តាប់ជាប់នូវចលនការនៃការអភិវឌ្ឍសម្រាប់ស្តារសេដ្ឋកិច្ចឡើងវិញប្រកបដោយភាពធន់ ។

ដើម្បីចាប់ផ្តើមស្តារភាពធន់ឡើងវិញប្រកបដោយភាពប្រុងប្រយ័ត្ន, រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវ "ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ឆ្នាំ ២០២១-២០២៣" ដើម្បីស្តារ និងអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ។ ភាពជោគជ័យក្នុងការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រនេះ ត្រូវផ្អែកលើការបន្តពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្ន និងការកៀរគរការគាំទ្រពីភាគីពាក់ព័ន្ធទាំងអស់ ទន្ទឹមនឹងការដោះស្រាយបញ្ហាប្រឈមថ្មីៗដែលទើបកើតឡើង ហើយប្រែក្លាយបញ្ហាប្រឈមទាំងនេះ ឱ្យទៅជាកាលានុវត្តភាព តាមរយៈការដាក់ចេញនូវអភិក្រមឆ្ពោះទៅមុខយ៉ាងម៉ត់ចត់ ស្របតាមជវភាពតំបន់ និងសកលលោក ដែលមានការវិវត្តយ៉ាងឆាប់រហ័ស ។

គោលបំណងចម្បងនៃរបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនេះ គឺដើម្បីធ្វើការត្រួតពិនិត្យវឌ្ឍនភាពនៃភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ និងផ្តល់នូវការវិភាគដែលផ្អែកលើសក្ខីកម្មជាក់ស្តែង លើការវិវត្តនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ក្នុងនោះ រួមមានការគាំទ្រអាទិភាពក្នុងការអភិវឌ្ឍជាតិ, គោលដៅអភិវឌ្ឍន៍កម្ពុជាប្រកបដោយចីរភាពកម្ពុជា, ការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩, និងការគាំពារសង្គម ។ របាយការណ៍នេះក៏បានវាយតម្លៃភាពជាដៃគូ ដែលអាចប្រើប្រាស់សម្រាប់តម្រង់ទិសការពិភាក្សា និងជាឯកសារយោងសម្រាប់កិច្ចសន្ទនាស្តីពីភាពជាដៃគូ ។ របាយការណ៍នេះនឹងជួយកម្ពុជាក្នុងការត្រៀមខ្លួនចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចនាពេលខាងមុខ ។ ខ្ញុំជឿជាក់យ៉ាងមុតមាំថារបាយការណ៍នេះនឹងបង្ហាញ អំពីការវិភាគស៊ីជម្រៅសម្រាប់អ្នករៀបចំគោលនយោបាយ, ដៃគូអភិវឌ្ឍន៍, និងភាគីពាក់ព័ន្ធដទៃទៀត ។ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងសហការីទាំងអស់ក្នុងគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលបានចូលរួម ក្នុងកិច្ចការដ៏សំខាន់នេះ ។

ថ្ងៃអង្គារ ១២រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា**

**ឈៀង យ៉ាណារ៉ា**

## មាតិកា


**ខ្លឹមសារសង្ខេបប្រតិបត្តិ....................................................................................................i-vi**

**ជំពូក១ - សេចក្តីផ្តើម-បរិការណ៍នៃហិរញ្ញប្បទានសហប្រតិបត្តិការ............................................................១**

**ជំពូក ២- ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍......................................................................................... ៥**

វឌ្ឍនភាពស្តីពីភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍................................................................................................. ៥

**ជំពូក ៣- ការវិវត្តនៃហិរញ្ញប្បទានសហប្រតិបត្តិការ.................................................................................. ១១**

ការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ...........................................................................................១១

ហិរញ្ញប្បទានសម្រាប់ប្រជាជនម្នាក់ និងអនុបាតធៀបនឹង ផ.ស.ស..............................................................................១១

ការបើកផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍.............................................................................................................១២

ការប្រែប្រួលសំខាន់ៗនៃការបើកផ្តល់ហិរញ្ញប្បទាន...................................................................................................១៥

ការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ.............................................................................................................១៥

ទម្រង់ និងទំហំនៃការបើកផ្តល់ឥណទានសម្បទាន..............................................................................................................១៧

ការចូលរួមរបស់ដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសចម្រុះ...........................................................................១៨

ការបើកផ្តល់ហិរញ្ញប្បទានតាមរាជធានី-ខេត្ត................................................................................................ ២០

ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ជាតិ ............................................................................. ២១

**ជំពូក ៤- ការគាំទ្រហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការឆ្លើយតបជំងឺកូវីដ-១៩ និងក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម..................................................................................................................២៤**

ការគាំទ្រដល់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩.................................................................................... ២៤

ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រលើការឆ្លើយតបបន្ទាន់................................................................................. ២៥

ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ........................................ ២៦

ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម.....................២៧

ការរួមចំណែកក្នុងការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម............................................................... ២៩

**ជំពូក ៥- ស្ថានភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្នុងអន្តរវិស័យ............................................................ ៣០**

ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់លើកកម្ពស់សមភាពយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រី........ ៣០

ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការប្រែប្រួលអាកាសធាតុ.................................................................. ៣៣

ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការអភិវឌ្ឍវិស័យឯកជន................................................................... ៣៦

**ជំពូក ៦- តួនាទីហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការគាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា............... ៣៩**

តួនាទីហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា.......................................... ៣៩

ការវិភាគហិរញ្ញប្បទានគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា.........................................៤០

ហិរញ្ញប្បទានសហប្រតិបត្តិការគាំទ្រវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងឧត្តមសិក្សា ៤២

**ជំពូក ៧ - ការគាំទ្រហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា...... ៤៤**

ការគាំទ្រហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា................៤៥
វឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា គោលដៅទី ១៧ : ភាពជាដៃគូ..........៤៨
**ជំពូក ៨- ការចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជា..................................................... ៥០**
ផលបច្ច័យនៃការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជា.............................................. ៥២
ផែនទីចង្អុលផ្លូវសម្រាប់ការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ...............................................៥៣
គោលនយោបាយសំខាន់..........................................................................................................៥៤
**ជំពូក ៩ - សេចក្តីសន្និដ្ឋាន..........................................................................................................៥៧**

## បញ្ជីតារាង


២.១- ស្ថានភាពស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ តាមដៃគូអភិវឌ្ឍន៍...................................................... ៩

៣.១- ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍន៍.................................................. ១៣

៣.២- ទម្រង់នៃការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍.................................................................. ១៤

៣.៣- ការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ ...................................................................................... ១៦

៣.៤- ការបើកផ្តល់ និងសកម្មភាពរបស់ដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសចម្រុះ.......................... ១៨

៣.៥- ដៃគូអភិវឌ្ឍន៍សំខាន់ៗក្នុងក្រុមការងារបច្ចេកទេសចម្រុះ ............................................................ ១៩

៣.៦- ការបើកផ្តល់តាមរាជធានី-ខេត្ត.................................................................................................. ២០

៣.៧- ការបើកផ្តល់របស់ដៃគូអភិវឌ្ឍន៍សំខាន់ៗតាមរាជធានី-ខេត្ត ឆ្នាំ២០២០............................................ ២០

៣.៨- ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ.......................................................................... ២១

៣.៩- ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗ ............................................................................ ២៣

៤.១- វ៉ាក់សាំងជំងឺកូវីដ-១៩ ក្រោមកិច្ចសហប្រតិបត្តិការទ្វេភាគី និងយន្តការ COVAX ................................ ២៥

៤.២- ហិរញ្ញប្បទានសហប្រតិបត្តិការគាំទ្រការឆ្លើយតបបន្ទាន់ ................................................................ ២៦

៤.៣- ការគាំទ្រទៅលើការស្តារឡើងវិញនៃសង្គម-សេដ្ឋកិច្ច.................................................................... ២៧

៤.៤- ហិរញ្ញប្បទានគាំទ្រវិស័យគាំពារសង្គមដោយដៃគូអភិវឌ្ឍន៍............................................................ ២៨

៤.៥- ការចូលរួមចំណែករបស់ដៃគូអភិវឌ្ឍន៍ក្នុងការគាំពារសង្គម .......................................................... ២៩

៥.១- ការបើកផ្តល់ហិរញ្ញប្បទានគាំទ្រវិស័យគោលយេនឌ័រ ឆ្នាំ២០១៩-២០២១........................................... ៣១

៥.២- ការបើកផ្តល់ហិរញ្ញប្បទានគាំទ្រវិស័យគោលយេនឌ័ររបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៩-២០២១......... ៣១

៥.៣- ការបញ្ជ្រាបសមភាពយេនឌ័រតាមវិស័យ ឆ្នាំ២០១៩-២០២១............................................................ ៣២

៥.៤- ការបញ្ជ្រាបសមភាពយេនឌ័ររបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៩-២០២១.............................................. ៣៣

៥.៥- ការបើកផ្តល់ហិរញ្ញប្បទានគាំទ្រវិស័យគោលប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៩-២០២១..................... ៣៤

៥.៦- ការបើកផ្តល់ហិរញ្ញប្បទានគាំទ្រវិស័យគោលប្រែប្រួលអាកាសធាតុរបស់ដៃគូ ឆ្នាំ២០១៩-២០២១.... ៣៤

៥.៧- ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុតាមវិស័យ ឆ្នាំ២០១៩-២០២១.............................................. ៣៥

៥.៨- ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៩-២០២១ ................................ ៣៦

៥.៩- ការបញ្ជ្រាបការអភិវឌ្ឍវិស័យឯកជនតាមវិស័យ ឆ្នាំ២០១៩-២០២១ ............................................... ៣៧

៥.១០- ការបញ្ជ្រាបការអភិវឌ្ឍវិស័យឯកជនរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៩-២០២១ ............................... ៣៨

៦.១- ហិរញ្ញប្បទានគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៨-២០១៩............ ៤០

៦.២- ធនធានរយៈពេលមធ្យមសម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម......................... ៤១

៦.៣- ធនធានរយៈពេលមធ្យមរបស់ដៃគូអភិវឌ្ឍន៍សម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម
........................................................................................................................................... ៤២

៦.៤- ធនធានរបស់ដៃគូអភិវឌ្ឍន៍គាំទ្រដល់វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងឧត្តមសិក្សា
........................................................................................................................................... ៤៣

៧.១-ការបើកផ្តល់ហិរញ្ញប្បទានតាមគោលដៅ គ.អ.ច.ក. ឆ្នាំ២០១៩-២០២២.................................... ៤៦
៧.២-ការបើកផ្តល់របស់ដៃគូអភិវឌ្ឍន៍សំខាន់ៗតាមគោលដៅ គ.អ.ច.ក. ឆ្នាំ២០២១............................ ៤៧
៧.៣-គោលដៅទី ១៧ ពង្រឹងមធ្យោបាយអនុវត្ត និងបង្កើតភាពរស់រវើកនៃភាពជាដៃគូសកល សម្រាប់កិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព............................................................................................. ៤៨
៨.១-លក្ខខណ្ឌវិនិច្ឆ័យសម្រាប់កម្ពុជាចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច.................................... ៥០
៨.២-សង្ខេបស្តីពីវឌ្ឍនភាពរបស់កម្ពុជាក្នុងដំណើរចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច................... ៥១
៨.៣-ផលចំណេញ និងការខាតបង់នៃការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច.............................. ៥២

## បញ្ជីតារាង

២.១- ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២០.......... ៥
២.២ - ការប្រើប្រាស់ក្របខណ្ឌលទ្ធផល ឆ្នាំ២០២១.......... ៥
២.៣ -ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២០ .......... ៦
២.៤ - ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២១.......... ៦
២.៥-ការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ ឆ្នាំ២០២០.......... ៦
២.៦-ការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ ឆ្នាំ២០២១.......... ៦
២.៧-ហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋ ឆ្នាំ២០២០.......... ៧
២.៨-ហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋ ឆ្នាំ២០២១ .......... ៧
២.៩-ភាពអាចទស្សន៍ទាយបាននៃហិរញ្ញប្បទាន ឆ្នាំ២០២០.......... ៨
២.១០-ភាពអាចទស្សន៍ទាយបាននៃហិរញ្ញប្បទាន ឆ្នាំ២០២១.......... ៨
២.១១-ហិរញ្ញប្បទានឥតភ្ជាប់លក្ខខណ្ឌ ឆ្នាំ២០២០.......... ៩
២.១២-ហិរញ្ញប្បទានឥតភ្ជាប់លក្ខខណ្ឌ ឆ្នាំ២០២១.......... ៩
៣.១-ការបើកផ្តល់ហិរញ្ញប្បទាន ឆ្នាំ២០១៣-២០២២.......... ១១
៣.២-ហិរញ្ញប្បទានសម្រាប់ប្រជាជនម្នាក់ និងអនុបាតហិរញ្ញប្បទានធៀបនឹង ផ.ស.ស.......... ១២
៣.៣-ដៃគូផ្តល់ហិរញ្ញប្បទានសំខាន់ៗ.......... ១៥
៣.៤-ទំហំហិរញ្ញប្បទានរបស់ដៃគូសំខាន់ៗ.......... ១៥
៣.៥-អនុបាតនៃការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ.......... ១៧
៣.៦-ទម្រង់នៃការបើកផ្តល់ហិរញ្ញប្បទាន.......... ១៨
៣.៧-ការបើកផ្តល់តាមវិស័យ និងតាមទម្រង់.......... ១៨
៣.៨-ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ.......... ២២
៣.៩-ភាគរយនៃធនធានរបស់អង្គការមិនមែនរាជរដ្ឋាភិបាល.......... ២២

## បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១: ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការតាមដៃគូអភិវឌ្ឍន៍ និងតាមវិស័យ ឆ្នាំ២០១៩
ឧបសម្ព័ន្ធទី២: ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការតាមដៃគូអភិវឌ្ឍន៍ និងតាមវិស័យ ឆ្នាំ២០២០
ឧបសម្ព័ន្ធទី៣: ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការតាមដៃគូអភិវឌ្ឍន៍ និងតាមវិស័យ ឆ្នាំ២០២១
ឧបសម្ព័ន្ធទី៤ ការបើកផ្តល់ និងការព្យាករណ៍ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៣-២០២៣
ឧបសម្ព័ន្ធទី៥: ការបើកផ្តល់ និងការព្យាករណ៍ហិរញ្ញប្បទានសហប្រតិបត្តិការតាមវិស័យ ឆ្នាំ២០១៣-២០២៣
ឧបសម្ព័ន្ធទី៦: ការបើកផ្តល់ និងការព្យាករណ៍ហិរញ្ញប្បទានសហប្រតិបត្តិការតាមរាជធានី និងខេត្ត ឆ្នាំ២០១៩-២០២២

# ខ្លឹមសារសង្ខេបប្រតិបត្តិ

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កម្ពុជារក្សាបានសន្តិភាព, ស្ថិរភាព, សណ្តាប់ធ្នាប់សង្គម, ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដោយប្រុងប្រយ័ត្ន និងការកែទម្រង់អភិបាលកិច្ច ដែលជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន ។ សមិទ្ធផលធំធេងទាំងនេះ បានស្តែងចេញតាមរយៈភាពជាម្ចាស់ និងសមត្ថភាព ព្រមទាំងភាពជាអ្នកដឹកនាំនយោបាយដ៏រឹងមាំរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានទទួលស្គាល់តួនាទីសំខាន់នៃហិរញ្ញប្បទានសហប្រតិបត្តិការ និងប្រភពហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍដទៃទៀត រួមទាំងវិស័យឯកជនសម្រាប់ជាមូលដ្ឋានសំខាន់ក្នុងការសម្រេចចក្ខុវិស័យឆ្នាំ២០៣០ និងឆ្នាំ២០៥០ ពិសេសក្នុងអន្តរកាលនៃការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ។

ដូចបណ្តាប្រទេសដទៃទៀត, កម្ពុជាបានទទួលរងផលប៉ះពាល់ពីការវិវត្តឆាប់រហ័សនៃបរិការណ៍អភិវឌ្ឍន៍ និងបញ្ហាប្រឈមសកល ពិសេសជំងឺកូវីដ-១៩ ។ ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយអន្តរាគមន៍ជាច្រើន ដើម្បីឆ្លើយតបបន្ទាន់នឹងបញ្ហាប្រឈមទាំងនេះ ដោយបានសហការជាមួយដៃគូអភិវឌ្ឍន៍ ។ ទន្ទឹមនឹងនេះ តាមរយៈយុទ្ធនាការចាក់វ៉ាក់សាំងទូទាំងប្រទេស, ការដាក់ចេញក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥, ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ឆ្នាំ២០២១-២០២៣ និងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ឆ្នាំ២០២១-២០៣៥, កម្ពុជាមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងស្ថានការណ៍នៃជំងឺកូវីដ-១៩ និងសម្រេចបានកំណើនសេដ្ឋកិច្ច ៣% ក្នុងឆ្នាំ២០២១ ហើយរំពឹងថានឹងអាចកើនដល់ ៥,៦% ក្នុងឆ្នាំ២០២២ និង ៦,៥% ក្នុងឆ្នាំ២០២៣ ។

## *ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍*

ដើម្បីគាំទ្រការអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, រាជរដ្ឋាភិបាលបានអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ដោយបានកំណត់គោលការណ៍, យន្តការ និងឧបករណ៍ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូដោយផ្តោតលើលទ្ធផល និងតាមដានវឌ្ឍនភាពសូចនាករស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ដែលមានសង្គតិភាពជាមួយគោលការណ៍ស្តីពីភាពជាដៃគូសកល។

ចំពោះសមិទ្ធកម្មដែលពាក់ព័ន្ធនឹងភាពជាដៃគូ, ក្នុងឆ្នាំ២០២១ ការប្រើប្រាស់ក្របខណ្ឌលទ្ធផលជាតិសម្រេចបានជិត ១០% មុនគោលដៅដែលបានកំណត់ ៨០% ក្នុងឆ្នាំ២០២៣ ។ ទន្ទឹមនឹងនេះ ហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋ និងភាពអាចទស្សន៍ទាយបាននូវហិរញ្ញប្បទានសហប្រតិបត្តិការ កំពុងមានវឌ្ឍនភាព ដោយសម្រេចបាន ៨៦% និង៩៦% ក្នុងឆ្នាំ២០២១ ។ ហិរញ្ញប្បទានឥតភ្ជាប់លក្ខខណ្ឌបានកើនបន្តិចពី ៧៤% ក្នុងឆ្នាំ២០២០ ដល់ ៧៧% ក្នុងឆ្នាំ២០២១ ។ រីឯការប្រើប្រាស់ប្រព័ន្ធជាតិ, ការបើកផ្តល់ហិរញ្ញប្បទានទំហំ ៧៤% ដែលបានគាំទ្រដល់វិស័យសាធារណៈ បានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ៣៨% បានប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ ។

*ការវិវត្តនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍*

ទោះបីមានការប្រកួតប្រជែងខាងធនធានសាធារណៈរវាងប្រទេសជាដៃគូ និងលទ្ធភាពធនធានរបស់ដៃគូអភិវឌ្ឍន៍, ក៏ក្នុងចន្លោះឆ្នាំ២០១៩-២០២១ ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ មានទំហំជាមធ្យម ២.០០០ លានដុល្លារ ក្នុងមួយឆ្នាំ ។ ក្នុងឆ្នាំ២០២០ ហិរញ្ញប្បទានបានកើនដល់ ២.៤០០ លានដុល្លារ ស្មើនឹង ២២% ធៀបនឹងឆ្នាំ២០១៩ ដោយសារការបើកផ្តល់លើគម្រោងធំពីរ ដើម្បីរួមចំណែកប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងដើម្បី គាំទ្រកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការស្តារសេដ្ឋកិច្ចឡើងវិញ ។ ប៉ុន្តែ ទំហំនេះអាចនឹងថយចុះប្រមាណ ១៦% ក្នុងឆ្នាំ២០២១ ។ ការបើកផ្តល់ហិរញ្ញប្បទានឥតសំណងក្នុងឆ្នាំ២០២០ បានកើនដល់ ៩៥៩ លានដុល្លារ ស្មើនឹង ៤០% នៃហិរញ្ញប្បទានសរុប ប៉ុន្តែ បានថយចុះ ៩% ធៀបនឹងឆ្នាំ២០១៩ ។ រីឯឥណទានសម្បទានបានកើនដល់កម្រិតខ្ពស់ ប្រមាណ ១.៤៥២ លានដុល្លារ ស្មើនឹង ៦០% នៃហិរញ្ញប្បទានសរុប និងបានកើន ៩% ធៀបនឹងឆ្នាំ ២០១៩ ដោយសារការបើកផ្តល់របស់សាធារណរដ្ឋប្រជាមានិតចិន, ជប៉ុន, ធនាគារអភិវឌ្ឍន៍អាស៊ី, ធនាគារពិភពលោក, សាធារណរដ្ឋកូរ៉េ និងបារាំង ។

ក្នុងចន្លោះឆ្នាំ២០១៣-២០១៨, អនុបាតហិរញ្ញប្បទានធៀបនឹង ផ.ស.ស បានធ្លាក់ចុះ ដោយសារកំណើនខ្ពស់នៃ ផ.ស.ស ធៀបនឹងកំណើនហិរញ្ញប្បទាន ។ ក្នុងឆ្នាំ២០២០ អនុបាតនេះបានកើនដល់កម្រិតខ្ពស់ ៩% ដោយសារការកើនឡើងឥណទានសម្បទាន ជាមួយនឹងកំណើនអវិជ្ជមាននៃ ផ.ស.ស ដែលបណ្តាលមកពីវិបត្តិជំងឺកូវីដ-១៩ ។ ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២២, សេដ្ឋកិច្ចបានចាប់ផ្តើមងើបឡើងវិញ ហើយការបើកផ្តល់ហិរញ្ញប្បទាននៅរក្សាទំហំថេរ ខណៈដែលអនុបាតហិរញ្ញប្បទានធៀបនឹង ផ.ស.ស នឹងរំពឹងថាធ្លាក់ចុះមកត្រឹម ៦% ក្នុងឆ្នាំ២០២២ ។

ក្នុងចន្លោះឆ្នាំ២០១៨-២០២២, សាធារណរដ្ឋប្រជាមានិតចិន, ជប៉ុន, កូរ៉េ និងបារាំង គឺជាដៃគូទ្វេភាគីដែលផ្តល់ហិរញ្ញប្បទានច្រើនជាងគេ ខណៈដែលធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក គឺជាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដែលផ្តល់ហិរញ្ញប្បទានច្រើន ។ សាធារណរដ្ឋប្រជាមានិតចិន, ជប៉ុន និងកូរ៉េ បានបង្កើនការបើកផ្តល់ហិរញ្ញប្បទានពី ៧៨៤ លានដុល្លារ ស្មើនឹង ៤០% នៃហិរញ្ញប្បទានសរុប ក្នុងឆ្នាំ២០១៩ ដល់ ១.១០០ លានដុល្លារ ស្មើនឹង ៤៦% នៃហិរញ្ញប្បទានសរុប ក្នុងឆ្នាំ២០២០ ។

ក្នុងចន្លោះឆ្នាំ២០១៨-២០២២, ការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ បានតម្រឹមល្អប្រសើរជាមួយនឹងអាទិភាពរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ។ ហិរញ្ញប្បទានមួយផ្នែកធំបានគាំទ្រដល់វិស័យសុខាភិបាល, អប់រំ ,កសិកម្ម, ដឹកជញ្ជូន និងថាមពល ដែលមានទំហំ ៥៧% និង ៧០% ធៀបនឹងហិរញ្ញប្បទានសរុប ក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១ ។ និន្នាការទាំងនេះបានបង្ហាញអំពីអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងការជំរុញកំណើន ដែលមានសង្គតិភាពជាមួយវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥ និងកិច្ចប្រឹងប្រែងឆ្លើយតបនឹងវិបត្តិជំងឺកូវីដ-១៩ និងការស្តារសេដ្ឋកិច្ច និងសង្គមឡើងវិញ ។

## ការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ

### និន្នាការនៃការបើកផ្តល់ហិរញ្ញប្បទាន (លានដុល្លារ)




### ការវិភាជតាមវិស័យ ឆ្នាំ២០២០ (លានដុល្លារ)




### ការបើកផ្តល់របស់ដៃគូអភិវឌ្ឍន៍ (លានដុល្លារ)

| ដៃគូអភិវឌ្ឍន៍ | 2018 | 2019 | 2020 | 2021 ប៉ាន់ស្មាន | 2022 ព្យាករណ៍ |
|---|---|---|---|---|---|
| UN Own Funds | 62.4 | 63.5 | 77.4 | 91.2 | 76.8 |
| Work Bank | 30.5 | 76.7 | 90.5 | 87.4 | 137.4 |
| ADB | 122.8 | 243 | 452.6 | 204.8 | 160.9 |
| GAVI Alliance | 7.9 | 20.1 | 8.9 | 9.1 | - |
| Global Fund | 19.9 | 40.9 | 39.7 | 42.8 | 41.1 |
| IAEA | - | - | 0.7 | 0.9 | 0.3 |
| EU/EC | 88.4 | 65.5 | 89.4 | 76.9 | 108.8 |
| Czech Republic | 1.1 | 1.7 | 2.2 | 2.7 | 1.9 |
| France | 80.6 | 195.4 | 85.7 | 117.4 | 130.0 |
| Germany | 37.3 | 29.5 | 29.8 | 44.8 | 82.9 |
| Ireland | 0.7 | 0.8 | 1.2 | 1.6 | - |
| Sweden | 23.8 | 23.0 | 27.0 | 22.5 | 18.0 |
| United Kingdom | 1.2 | 1.1 | 1.0 | 3.4 | 1.6 |
| Australia | 50.0 | 41.2 | 33.1 | 66.5 | 35.3 |
| Canada | 3.9 | 2.8 | 2.1 | 2.9 | 2.1 |
| China | 352.0 | 503.7 | 494.8 | 343.1 | 260.7 |
| Japan | 175.4 | 207.7 | 501.7 | 400.6 | 468.2 |
| New Zealand | 5.0 | 7.2 | 5.9 | 8.6 | 2.6 |
| Republic of Korea | 54.0 | 72.8 | 103.3 | 119.8 | 141.7 |
| Switzerland | 13.6 | 12.9 | 15.6 | 17.1 | 9.8 |
| USA | 91.7 | 95.3 | 93.0 | 112.1 | 97.0 |
| NGO Core Funds | 274.9 | 276.4 | 255.4 | 250.3 | 83.2 |
| Pipeline Projects | - | - | - | - | 219.8 |
| **សរុបរួម** | **1497.1** | **1981.2** | **2410.8** | **2026.6** | **1860.3** |

### *ការគាំទ្រការឆ្លើយតបនឹងជំងឺកូវីដ-១៩ និងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម*

ការលេចឡើងនៃជំងឺកូវីដ-១៩ នាដើមឆ្នាំ២០២០ បានធ្វើឱ្យសេដ្ឋកិច្ចពិភពលោកធ្លាក់ចុះយ៉ាងគំហុក ហើយកម្ពុជាក៏បានប្រឈមនឹងការថយចុះនៃកំណើនសេដ្ឋកិច្ច និងសុខុមាលភាពសង្គម ។ ទោះជាយ៉ាងនេះក្តី ក្រោមការដឹកនាំដ៏រឹងមាំរបស់រាជរដ្ឋាភិបាល និងកិច្ចសហការជាមួយភាគីពាក់ព័ន្ធ, កម្ពុជាអាចគ្រប់គ្រងស្ថានការណ៍ជំងឺរាតត្បាតនេះប្រកបដោយប្រសិទ្ធភាព និងស្តារសេដ្ឋកិច្ចឡើងវិញបានឆាប់រហ័ស ។ យុទ្ធនាការចាក់វ៉ាក់សាំង និងជួសជុំវិញ ទូទាំងប្រទេស, ការឆ្លើយតបបន្ទាន់នឹងជំងឺកូវីដ-១៩ និងការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ សុទ្ធសឹង តែជាអន្តរាគមន៍សំខាន់ៗក្នុងចំណោមកិច្ចអន្តរាគមន៍នានាកន្លងមក ។

ដោយសាររាជរដ្ឋាភិបាលបានពង្រឹងភាពជាដៃគូទូលំទូលាយជាមួយគ្រប់ភាគីពាក់ព័ន្ធ, កម្ពុជាបានទទួលវ៉ាក់សាំងប្រមាណ ១៥,៣ លានដូស ដែលមានតម្លៃ ១០៨ លានដុល្លារ ។ សាធារណរដ្ឋប្រជាមានិតចិនបានផ្តល់វ៉ាក់សាំងច្រើនជាងគេ ចំនួន ៨,៣ លានដូស ។ រីឯយន្តការ COVAX បានផ្តល់វ៉ាក់សាំង ចំនួន ៣ លានដូស ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បានវិភាជថវិកាដ៏ច្រើន សម្រាប់បញ្ជាទិញវ៉ាក់សាំងចំនួន ២៨ លានដូស ។ ក្រៅ

ពីការផ្តល់វ៉ាក់សាំង, ហិរញ្ញប្បទាន ១៦២ លានដុល្លារ ក្នុងឆ្នាំ២០២០ និង ៨១២,៧៥ លានដុល្លារ ក្នុងឆ្នាំ ២០២១ បានគាំទ្រដល់ការឆ្លើយតបបន្ទាន់នឹងជំងឺកូវីដ-១៩ ពិសេសវិស័យសុខាភិបាល និងការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ ។ របបថែទាំសុខភាពដែលស្ថិតក្រោមប្រព័ន្ធសន្តិសុខសង្គមនៃវិស័យគាំពារសង្គម ទទួលបានការគាំទ្រច្រើនជាងគេ ចំនួន៥០ លានដុល្លារ ក្នុងឆ្នាំ ២០២០ ។ ក្រៅពីការគាំទ្រក្នុងវិស័យគាំពារសង្គម, ការគាំទ្របានផ្តោតទៅលើជំនួយសង្គម ពិសេសការអភិវឌ្ឍមូលធនមនុស្ស ដែលទទួលបានហិរញ្ញប្បទាន ប្រមាណ ៩ លានដុល្លារ ។

***ស្ថានភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្នុងអន្តរវិស័យ***

ការបើកផ្តល់ហិរញ្ញប្បទានសរុបសម្រាប់វិស័យយេនឌ័រ បានកើនពី ៥,៩៤ លានដុល្លារ ក្នុងឆ្នាំ២០២០ ដល់ ៦,៦០ លានដុល្លារ ក្នុងឆ្នាំ២០២១ ក្នុងពេលដែលធនធានសម្រាប់បញ្ជ្រាបយេនឌ័រ មានទំហំ ៤៦៥,០៨ លានដុល្លារ ក្នុងឆ្នាំ២០២១ ។ ការបើកផ្តល់ធនធានសរុបសម្រាប់វិស័យប្រែប្រួលអាកាសធាតុ បានធ្លាក់ចុះពី ៩,០១ លានដុល្លារ ក្នុងឆ្នាំ២០២០ មកត្រឹម ៨,២៨ លានដុល្លារ ក្នុងឆ្នាំ២០២១ ទោះបីដៃគូអភិវឌ្ឍន៍នៅបន្តប្តេជ្ញាផ្តល់ការគាំទ្រក៏ដោយ ។ ជាមួយគ្នានេះ ធនធានសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ មាន ១៨% នៃហិរញ្ញប្បទានសរុប ។

ការអភិវឌ្ឍវិស័យឯកជន នៅតែជាអាទិភាពរបស់រាជរដ្ឋាភិបាលសម្រាប់លើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិ ។ ក្នុងឆ្នាំ២០២១ ហិរញ្ញប្បទានចំនួន ៦៩៣ លានដុល្លារ ស្មើ ៣៤,២៥% នៃហិរញ្ញប្បទានសរុប បានគាំទ្រដល់ការបញ្ជ្រាបការអភិវឌ្ឍវិស័យឯកជន ពោលគឺបានកើន ១៣% ធៀបឆ្នាំ២០២០ ។ វិស័យសំខាន់ៗដែលបានបញ្ជ្រាបការអភិវឌ្ឍវិស័យឯកជនទៅក្នុងវិស័យរបស់ខ្លួន រួមមាន ÷ ១) ដឹកជញ្ជូន ២) ថាមពល និងអគ្គិសនី ៣) កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម ៤) ទេសចរណ៍ និង ៥) សេវាកម្មធនាគារ និងធុរកិច្ច ។

***ការគាំទ្រគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា***

ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥ ប្រកបដោយប្រសិទ្ធភាពជំរុញឱ្យមានការអភិវឌ្ឍវិស័យឧស្សាហកម្ម និងកំណើនប្រកបដោយចីរភាពនៅកម្ពុជា ។ ហិរញ្ញប្បទានសហ-ប្រតិបត្តិការបន្តដើរតួនាទីជាកាតាលីករក្នុងការកៀរគរធនធានអភិវឌ្ឍន៍ដទៃទៀត ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សហកម្មកម្ពុជា និងអាទិភាពនៃគោលនយោបាយនេះ ។

ក្នុងឆ្នាំ២០១៩ ហិរញ្ញប្បទានទំហំ ៣០០,៣ លានដុល្លារ ស្មើ ១៧,៦% នៃហិរញ្ញប្បទានសរុប (មិនរាប់បញ្ចូលធនធានរបស់អង្គការមិនមែនរដ្ឋាភិបាល) បានគាំទ្រដល់វិធានការគន្លឹះបួនជាក់ស្តែង, វិធានការគោល-នយោបាយ និងផែនការសកម្មភាពនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ។ ក្នុងឆ្នាំ២០២២ ហិរញ្ញប្បទាននេះ បានកើនឡើង ៦% ពោលគឺកើនដល់ ៣១៨,៣ លានដុល្លារ ។ ហិរញ្ញប្បទាននេះ ត្រូវបានប៉ាន់ស្មានថាមានទំហំ ៣០៦,១ លានដុល្លារ ក្នុងឆ្នាំ២០២១ ដែលធនធានប្រមាណ ២/៣ បានគាំទ្រដល់ការអនុវត្តវិធានការគន្លឹះបួនជាក់ស្តែង ក្នុងនោះធនធានចំនួន ១៩០,៧ លានដុល្លារ បានគាំទ្រវិស័យថាមពល ដែលធនធានភាគច្រើនត្រូវបានផ្តល់ដោយសាធារណរដ្ឋប្រជាមានិតចិន និងជប៉ុន ។

***ការគាំទ្រគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.)***

ការផ្តល់ហិរញ្ញប្បទានសម្រាប់អនុវត្តក្របខណ្ឌនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាសម្រេចបានវឌ្ឍនភាពគួរកត់សម្គាល់ ។ គោលដៅទី ៣ ស្តីពីការធានាឱ្យជីវភាពរស់នៅប្រជាជនប្រកបដោយសុខភាព និងសុខុមាលភាព និងគោលដៅទី ៩ ស្តីពីការលើកកម្ពស់ឧស្សាហូបនីយកម្មប្រកបដោយចីរភាព និងបរិយាប័ន្ន, ការលើកកម្ពស់នវានុវត្តន៍ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ទទួលបានការគាំទ្រច្រើនជាងគេ ។ ជាក់ស្តែង ក្នុងឆ្នាំ ២០១៩ និងឆ្នាំ២០២០, គោលដៅទី ៣ ទទួលបានការគាំទ្រចំនួន ១៥១ លានដុល្លារ និងចំនួន ៥៦២ លានដុល្លារ ក្នុងពេលដែលគោលដៅទី ៩ ទទួលបានការគាំទ្រចំនួន ៥៥៧ លានដុល្លារ និងចំនួន ៥៤០ លានដុល្លារ ។ ប្រការទាំងនេះបានបង្ហាញអំពីការតម្រឹមការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ ជាមួយនឹងអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍធនធានមនុស្ស, ការកសាងហេដ្ឋារចនាសម្ព័ន្ធ, និងការឆ្លើយតបទៅនឹងផលប៉ះពាល់ផ្នែកសុខភាពដែលបណ្តាលពីជំងឺកូវីដ-១៩ ។

***ការចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជា***

ផ្អែកតាមលទ្ធផលនៃការត្រួតពិនិត្យ ៣ ឆ្នាំម្តង, គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិបានសម្រេចដាក់បញ្ចូលកម្ពុជា ទៅក្នុងបញ្ជីសម្រាប់ចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចកាលពីឆ្នាំ២០២១ ។ ការឈានទៅចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច បានលើកកម្ពស់កិត្យានុភាពជាតិនៅលើឆាកអន្តរជាតិ និងការទទួលស្គាល់ពីសមិទ្ធផលដែលសម្រេចបានក្នុងការរក្សាបានសន្តិភាព, ស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម, ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, និងការអភិវឌ្ឍប្រកបដោយចីរភាព ។ ប្រការទាំងនេះបានបង្កើតជាបរិយាកាសអំណោយផលសម្រាប់ទាក់ទាញវិនិយោគឯកជន ពិសេសការវិនិយោគផ្ទាល់ពីបរទេស ។ ទោះបីការចាកចេញពីក្រុមប្រទេសអភិវឌ្ឍតិចតួចអាចបង្កឱ្យបាត់បង់ភាពអនុគ្រោះ, លទ្ធភាពនៃការធ្លាក់ចុះនៃហិរញ្ញប្បទានឥតសំណង និងការថយចុះនៃកម្រិតសម្បទានរបស់ឥណទានសម្បទានក៏ដោយ, ក៏រាជរដ្ឋាភិបាលបានគិតគូរអំពីវិធានការសម្រាប់ជួយសម្រាលការខាតបង់ដែលអាចកើតមានឡើង ជាយថាហេតុ ។ ទន្ទឹមនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដូចជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន, កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ, និងកិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ដែលត្រូវបានពិភាក្សាបញ្ចប់, កិច្ចការដែលត្រូវប្រកាន់យក គឺការត្រៀមរៀបចំ និងការក្តាប់ឱ្យជាប់នូវកាលានុវត្តភាពនានា ។ ក្នុងន័យនេះ ដើម្បីសម្រេចគោលដៅនៃការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចប្រកបដោយចីរភាព, គប្បីយកចិត្តទុកដាក់លើអនុសាសន៍គោលនយោបាយ និងគោលដៅអាទិភាព ដូចខាងក្រោម÷

***<u>ការវិនិយោគលើមូលធនមនុស្ស</u>*** : ការពង្រឹងគុណភាពក្នុងវិស័យអប់រំ, វិស័យសុខភាពសាធារណៈ ពិសេសក្របខណ្ឌគោលនយោបាយគាំពារសង្គម ដែលមានចែងក្នុងផែនការស្តារសង្គម និងសេដ្ឋកិច្ច គឺជាគោលដៅចម្បងនៃការវិនិយោគលើការអភិវឌ្ឍធនធានមនុស្ស ។

***<u>គោលនយោបាយឧស្សាហកម្ម</u>***: ការលើកកម្ពស់សហគ្រាសខ្នាតមីក្រូ, ខ្នាតតូច និងមធ្យម នឹងដើរតួនាទីសំខាន់ក្នុងការបង្កើតបរិយាកាសអំណោយផលសម្រាប់ការធ្វើអាជីវកម្ម និងការបង្កើតការងារ ខណៈដែលការបង្កើតតំបន់សេដ្ឋកិច្ចពិសេសនឹងជំរុញឱ្យមានការផ្លាស់ប្តូរខាងរចនាសម្ព័ន្ធសេដ្ឋកិច្ច ។

***ហេដ្ឋារចនាសម្ព័ន្ធ និងភស្តុភារកម្ម***: ការអភិវឌ្ឍស្ពាន, ផ្លូវថ្នល់ និងប្រព័ន្ធទំនាក់ទំនង ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធដទៃទៀត ដែលប្រកបដោយគុណភាព គឺជាកិច្ចការសំខាន់ សម្រាប់លើកកម្ពស់ភាពប្រកួតប្រជែងសេដ្ឋកិច្ចកម្ពុជា ។

***ពិពិធកម្មសេដ្ឋកិច្ច***: ការទាក់ទាញវិនិយោគផ្ទាល់ពីបរទេស តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងតំបន់ ដូចជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន, កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ និងកិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ គឺជាមូលដ្ឋាននៃឧស្សាហូបនីយកម្ម ដែលអាចបង្កើតភាពប្រកួតប្រជែង និងពិពិធកម្ម សំដៅជំរុញការនាំចេញផលិតផលឧស្សាហកម្ម និងកាត់បន្ថយភាពក្រីក្រ ។

***ការអភិវឌ្ឍជំនាញថ្មី***: ការដាក់ចេញនូវក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ឆ្នាំ ២០២១-២០៣៥ គឺជាកត្តាចាំបាច់សម្រាប់អភិវឌ្ឍជំនាញឌីជីថល សំដៅសម្របទៅនឹងនិន្នាការសកលពិសេសសេដ្ឋកិច្ចឌីជីថល ។

***ការកៀរគរធនធាន***: ធនធានទាំងក្នុងស្រុក និងក្រៅប្រទេស មានតួនាទីគាំទ្រកម្ពុជាដល់ដំណើរការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាទី ១៧ ស្តីពីភាពជាដៃគូមានតួនាទីសំខាន់ដើម្បីកៀរគរបន្ថែមនូវវិធានការគាំទ្រអន្តរជាតិ និងសកម្មភាពនានាដែលអាចផ្តល់ប្រយោជន៍ដល់ក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ។

សរុបមក, ធនធានអភិវឌ្ឍន៍ពីក្រៅប្រទេសបានបន្តតួនាទីសំខាន់ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ពិសេសក្នុងបរិបទនៃវិបត្តិជំងឺកូវីដ-១៩ ។ ធនធានទាំងនេះនឹងបំពេញបន្ថែមឱ្យធនធានក្នុងស្រុក និងធនធានអភិវឌ្ឍន៍ដទៃទៀត រួមទាំងធនធានពីវិស័យសាធារណៈ និងឯកជន និងកិច្ចសហប្រតិបត្តិការត្បូង-ត្បូង ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍ជាតិ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលប្តេជ្ញាយ៉ាងមុតមាំក្នុងការបន្តពង្រឹងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូប្រកបដោយបរិយាប័ន្នជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ដើម្បីកៀរគរ, សម្របសម្រួល និងគ្រប់គ្រងធនធានអភិវឌ្ឍន៍សំខាន់ទាំងនេះប្រកបដោយប្រសិទ្ធភាព ។

# ជំពូក ១

# សេចក្តីផ្តើម : បរិការណ៍នៃហិរញ្ញប្បទានសហប្រតិបត្តិការ

រាជរដ្ឋាភិបាលកម្ពុជារក្សាបាននូវសុខសន្តិភាព, ស្ថិរភាព, សណ្តាប់ធ្នាប់សង្គម និងសាមគ្គីភាពជាតិ, សុខដុមរមនា និងជីវភាពរស់នៅសមរម្យរបស់ប្រជាជន ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមក ដែលបានបង្កើតជាមូលដ្ឋានរឹងមាំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន ។ កម្ពុជាបាន និងកំពុងដើរលើមាគ៌ាត្រឹមត្រូវក្នុងការអភិវឌ្ឍប្រកបដោយជោគជ័យ និងសម្រេចបានសមិទ្ធផលប្រកបដោយផ្លែផ្កា តាមរយៈការពង្រឹងសុខុមាលភាពសង្គម-សេដ្ឋកិច្ច និងវិបុលភាពរបស់ប្រជាជនកម្ពុជា ។ វឌ្ឍនភាពដ៏ល្អប្រសើរក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនេះ បានធ្វើឱ្យកម្ពុជាសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប ក្នុងឆ្នាំ២០១៦ និងបន្តជំរុញកម្ពុជាឱ្យចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច បន្ទាប់ពីត្រូវបានដាក់បញ្ចូលជាលើកដំបូងក្នុងបញ្ជីសម្រាប់ការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចក្នុងឆ្នាំ២០២១ ។

សមិទ្ធផលដ៏ត្រចះត្រចង់ទាំងនេះសម្រេចបាន អាស្រ័យដោយការដឹកនាំប្រកបដោយចក្ខុវិស័យរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការដឹកនាំនាវាកម្ពុជាឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពស្វាហាប់, បរិយាប័ន្ន, ចីរភាព និងភាពធន់ ។ កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល គួបផ្សំជាមួយការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ និងធនធានដទៃទៀត រួមទាំងធនធានរបស់វិស័យឯកជន សម្រាប់អនុវត្តរបៀបវារៈអភិវឌ្ឍន៍ជាតិ បានពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាមកទល់បច្ចុប្បន្ន ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានទទួលស្គាល់តួនាទីសំខាន់របស់ហិរញ្ញប្បទានសហប្រតិបត្តិការ ក្នុងការអភិវឌ្ឍជាតិ និងក្នុងអន្តរកាលសម្រាប់ចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច ក៏ដូចជាការសម្រេចបាននូវមហិច្ឆតាក្នុងការប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងប្រទេសមានចំណូលកម្រិតខ្ពស់ក្នុងឆ្នាំ២០៥០ ។

សមិទ្ធកម្មសេដ្ឋកិច្ចរបស់កម្ពុជាសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ។ ទោះជាយ៉ាងនេះក្តី ការវិវត្តសេដ្ឋកិច្ចកម្ពុជាបានជួបប្រទះបញ្ហាប្រឈមមួយចំនួន ពិសេសការទទួលឥទ្ធិពលនៃការប្រែប្រួលនានានៅកម្រិតសកល ។ ការធ្លាក់ចុះនៃទំនិញសាធារណៈសកល, ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល, ការកើនឡើងនៃភាពពឹងផ្អែកទៅវិញទៅមកខាងផ្នែកសេដ្ឋកិច្ច, ការកើនឡើងនៃសេដ្ឋកិច្ចឌីជីថល និងបដិវត្តន៍បច្ចេកវិទ្យា, ការព្រួយបារម្ភកាន់តែច្រើនឡើងខាងបរិស្ថាន និងបញ្ហាប្រឈមកាន់តែខ្លាំងលើផ្នែកសន្តិសុខសង្គម តម្រូវឱ្យមានកិច្ចសហការរួមគ្នាក្នុងការដោះស្រាយរាល់បញ្ហាទាំងនេះ ។

ចរន្តសកលភាវូបនីយកម្មបច្ចុប្បន្នបាន និងកំពុងបន្តកើនឡើង ស្របពេលដែលបរិបទថ្មីៗក្នុងកិច្ចអភិវឌ្ឍន៍ បានកំពុងបន្តវិវត្តយ៉ាងឆាប់រហ័ស ។ ជាក់ស្តែង បញ្ហាពាក់ព័ន្ធនឹងពាណិជ្ជកម្មបានជះឥទ្ធិពលដល់ហិរញ្ញប្បទានសហប្រតិបត្តិការ ។ ក្នុងពេលដែលកម្ពុជាកំពុងធ្វើសមាហរណកម្មក្នុងទីផ្សារអន្តរជាតិ តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយសាធារណរដ្ឋប្រជាមានិតចិន និងសាធារណរដ្ឋកូរ៉េ និងកិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់, ភាពជាដៃគូក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការ ត្បូង-ត្បូង ត្រូវបានជំរុញជាបន្តបន្ទាប់ ។

លើសពីនេះ ការរីករាលដាលនៃជំងឺកូវីដ-១៩ បានជះឥទ្ធិពលដល់ការអនុវត្តភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ ការរីករាលដាលនៃជំងឺកូវីដ-១៩ ត្រូវបានចាត់ទុកជាវិបត្តិសកលលោក ដែលបានរាំងស្ទះដល់វឌ្ឍនភាពនៃកិច្ចអភិវឌ្ឍន៍នៅគ្រប់ប្រទេសទាំងអស់ និងបង្កហានិភ័យដល់ការអនុវត្តគោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាព ហើយបានបង្វែរការយកចិត្តទុកដាក់សកល ទៅរកគោលការណ៍នៃការកសាងភាពធន់ និង ភាពប្រសើរជាងមុនរួមគ្នា ។ លើមូលដ្ឋាននេះ បញ្ហាប្រឈមថ្មីនេះបានទាមទារឱ្យពិនិត្យឡើងវិញនូវគោលការណ៍ ស្ដីពីស័ក្ដិសិទ្ធិភាព ក្នុងកិច្ចអភិវឌ្ឍន៍របស់យន្តការភាពជាដៃគូសកលស្ដីពីស័ក្ដិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ។

ឥទ្ធិពលនៃជំងឺកូវីដ-១៩ បានជំរុញឱ្យមានការផ្លាស់ប្ដូរគោលដៅនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ពីការផ្ដោតលើកំណើនសេដ្ឋកិច្ច និងអភិបាលកិច្ច ទៅការគិតគូរពីសន្តិសុខមនុស្សជាតិ ដែលពាក់ព័ន្ធជុំវិញបញ្ហាសុខភាពសាធារណៈជាសកល, ការប្រែប្រួលអាកាសធាតុ និងសន្តិសុខស្បៀង ដែលនឹងក្លាយជាគោលដៅអាទិភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្រោយវិបត្តិជំងឺកូវីដ-១៩ ។ ជាក់ស្ដែង កិច្ចសហប្រតិបត្តិការក្នុងការផ្គត់ផ្គង់ និងចែកចាយវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជាសក្ខីកម្មបញ្ជាក់អំពីតម្រូវការនៃការផ្គត់ផ្គង់ទំនិញសាធារណៈជាសកល ដែលបានបង្កើតឱ្យមាននិម្មាបនកម្មកិច្ចអភិវឌ្ឍន៍ថ្មីនេះ ។ ក្នុងន័យនេះ ក្រៅពីកិច្ចសហប្រតិបត្តិការរវាងដៃគូផ្ដល់ និងប្រទេសទទួលជំនួយ, កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍តាមទម្រង់ថ្មី ក្នុងបរិការណ៍ជំងឺកូវីដ-១៩ បានបង្ហាញអំពីតួនាទីសំខាន់បន្ថែមទៀត របស់ប្រទេសមានសេដ្ឋកិច្ចលូតលាស់លឿន ដូចជា ÷ សាធារណរដ្ឋប្រជាមានិតចិន, ជប៉ុន និងសាធារណរដ្ឋកូរ៉េ ដែលជំរុញឱ្យមានកិច្ចប្រឹងប្រែងរួមជាសកល ដើម្បីសម្រេចជោគជ័យក្នុងការគ្រប់គ្រងជំងឺកូវីដ-១៩ និងសម្រេចបានការស្ដារសេដ្ឋកិច្ចឡើងវិញ ។

ដូចគ្នានឹងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត, សេដ្ឋកិច្ចកម្ពុជាកំពុងរងគ្រោះដោយសារជំងឺកូវីដ-១៩ ដែលកំពុងដាក់សម្ពាធយ៉ាងខ្លាំងលើប្រព័ន្ធសុខាភិបាល និងវិស័យដទៃទៀត ក្នុងឆ្នាំ២០២០ ។ ការរីករាលដាលនៃជំងឺកូវីដ-១៩ បាននាំឱ្យមានការធ្លាក់ចុះចំណូលក្នុងស្រុក, ការថយចុះការវិនិយោគឯកជន រួមទាំងការវិនិយោគផ្ទាល់ពីបរទេស, ការបាត់បង់ចំណូលមួយផ្នែកធំពីវិស័យទេសចរណ៍, ការធ្លាក់ចុះនៃការផ្ញើរសាច់ប្រាក់ពីបរទេស, ការថយចុះសកម្មភាពរបស់សហគ្រាសធុនតូច និងមធ្យម, និងការថមថយសេដ្ឋកិច្ចទាំងមូលដោយសារផលវិបាកចំពោះតម្រូវការនាំចេញ និងខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងពាណិជ្ជកម្មអន្តរជាតិ ។ ផលប៉ះពាល់ទាំងអស់នេះបានធ្វើឱ្យអត្រាភាពក្រីក្រកើនឡើង ដែលបន្ទប់បង្អាក់ដល់វឌ្ឍនភាពកម្ពុជាក្នុងការសម្រេចបាននូវរបៀបវារៈអភិវឌ្ឍន៍ជាតិ, គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា និងអាចរាំងស្ទះដល់វឌ្ឍនភាពកម្ពុជាក្នុងដំណើរការត្រៀមចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច នាពេលខាងមុខ ។

ឆ្លើយតបទៅនឹងវិបត្តិជំងឺកូវីដ-១៩, ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃរបស់រាជរដ្ឋាភិបាល, កម្ពុជាបានខិតខំប្រឹងប្រែង និងទទួលបានជោគជ័យគួរជាទីមោទនៈក្នុងការគ្រប់គ្រងជំងឺរាតត្បាតនេះ ។ ជាក់ស្ដែងរាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការឆ្លើយតបរហ័ស និងមានប្រសិទ្ធភាព តាមរយៈអន្តរាគមន៍នានាពាក់ព័ន្ធទៅនឹងសុខភាពសាធារណៈ ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តវិធានការមួយចំនួនបន្ថែមទៀត ដើម្បីគាំទ្រដល់ការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥ ដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងជួយសម្រាល

វិស័យមួយចំនួនដែលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ក៏ដូចជាធានាប្រាក់ចំណូល និងសុខុមាលភាពរបស់ក្រុមជនងាយរងគ្រោះ ។ ទាំងនេះសុទ្ធសឹងតែជាផ្លែផ្កានៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលតាមរយៈការអនុវត្តនូវអភិក្រម "ទូទាំងរាជរដ្ឋាភិបាល" ដែលបានដាក់ចេញឱ្យអនុវត្តបានទាន់ពេលវេលានូវវិធានការគោលនយោបាយ និងពង្រឹងកិច្ចសហការជាមួយគ្រប់ភាគីពាក់ព័ន្ធ ដោយប្រកាន់ខ្ជាប់នូវអភិក្រម "ទូទាំងសង្គម" ដើម្បីឆ្លើយតបនឹងជំងឺរាតត្បាតកូវីដ-១៩ ។

ជាលទ្ធផល វិធានការគាំទ្រដែលរាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្ត បានជួយឱ្យសេដ្ឋកិច្ចកម្ពុជាងើបឡើងវិញក្នុងអត្រា ៣% ក្នុងឆ្នាំ២០២១ បន្ទាប់ពីបានធ្លាក់ចុះក្នុងកម្រិតអវិជ្ជមាន ៣,១% ក្នុងឆ្នាំ ២០២០ ។ សន្ទុះកំណើនវិជ្ជមាន គួបផ្សំជាមួយនឹងយុទ្ធនាការចាក់វ៉ាក់សាំងទូទាំងប្រទេស ផ្អែកលើអភិក្រម "ផ្ការីក" របស់រាជរដ្ឋាភិបាល នឹងជំរុញសេដ្ឋកិច្ចកម្ពុជាឱ្យមានកំណើន ៥,៦% ក្នុងឆ្នាំ២០២២ និង ៦,៥% ក្នុងឆ្នាំ២០២៣ ។ តាមរយៈយុទ្ធនាការចាក់វ៉ាក់សាំងទ្រង់ទ្រាយធំទូទាំងប្រទេសរបស់រាជរដ្ឋាភិបាល និងការគាំទ្រពីដៃគូអភិវឌ្ឍន៍ កម្ពុជាបានឈានមុខគេក្នុងការចាក់វ៉ាក់សាំងជូនប្រជាជនប្រមាណជាង ៩០% នៃប្រជាជនសរុប និងបានក្លាយជាប្រទេសមួយក្នុងចំណោមក្រុមប្រទេសដែលមានអត្រាចាក់វ៉ាក់សាំងខ្ពស់ ។ បើទោះយ៉ាងនេះក្តី, ស្ថានភាពនៃវិបត្តិជំងឺកូវីដ-១៩ ពេលបច្ចុប្បន្ន មិនទាន់មានភាពច្បាស់លាស់នៅឡើយ ដោយសារតែការលេចឡើងនៃមេរោគកូវីដ-១៩ បំប្លែងថ្មី ។

ទន្ទឹមនឹងនេះ ជំងឺកូវីដ-១៩ បានបង្កើតកាលានុវត្តភាពថ្មីសម្រាប់កម្ពុជាក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន, ចីរភាព, និងភាពធន់ ។ ដើម្បីសម្រួលការស្តារសេដ្ឋកិច្ច, រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តនូវ "ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣" ដែលបានកំណត់គោលដៅអាទិភាព ដោយផ្អែកលើសសរស្តម្ភចំនួន ៣ រួមមាន÷ ការស្តារឡើងវិញ, ការកែទម្រង់, និងការកសាងភាពធន់ ។

ការចាប់យកបច្ចេកវិទ្យាថ្មី ពិសេសនៅក្នុងឧស្សាហកម្ម ៤.០ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកម្ពុជាឱ្យជម្នះបានផលប៉ះពាល់ដែលបង្កឡើងដោយជំងឺកូវីដ-១៩ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាល បានអនុម័ត និងដាក់ឱ្យអនុវត្តនូវ "ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥" ដើម្បីទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថល សម្រាប់បង្កើនផលិតភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច ក៏ដូចជាលើកកម្ពស់ពិពិធកម្មសេដ្ឋកិច្ចនៅកម្ពុជា ។

ការអនុវត្តប្រកបដោយប្រសិទ្ធភាព នូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥ បានបញ្ជាក់អំពីទិសដៅនៃការកែប្រែរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា ឱ្យក្លាយជាឧស្សាហកម្មដែលពឹងផ្អែកលើជំនាញ ។ លើមូលដ្ឋាននេះ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម បានដើរតួយ៉ាងសំខាន់ក្នុងការលើកកម្ពស់ពិពិធកម្មសេដ្ឋកិច្ច, ភាពប្រកួតប្រជែង, ផលិតភាព, និងចំណេះដឹងផ្នែកបច្ចេកវិទ្យា ។ ដំណាក់កាលទី១ នៃការអនុវត្ត និងការជះឥទ្ធិពលនៃគោលនយោបាយនេះមកលើសង្គម-សេដ្ឋកិច្ចកម្ពុជា ត្រូវបានវាយតម្លៃក្នុងរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ ដែលបានលើកឡើងនូវអនុសាសន៍គោលនយោបាយសំខាន់ៗសម្រាប់ ពន្លឿនការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មនេះ ក្នុងដំណាក់កាលទី២ ឆ្នាំ

២០២១-២០២៥ និងពេលអនាគត ។ ច្បាប់វិនិយោគថ្មីត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ ដើម្បីជំរុញការវិនិយោគ និងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានប្ដេជ្ញាបន្តអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ សម្រាប់តម្រង់ទិសរបៀបវារៈអភិវឌ្ឍន៍ជាតិ ដែលត្រូវបានអនុវត្តតាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ ដែលរួមបញ្ចូលគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ។ ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិត្រូវបានត្រួតពិនិត្យតាមរយៈរបាយការណ៍ពាក់កណ្ដាលអាណត្តិ សម្រាប់ជាមូលដ្ឋានក្នុងការអនុវត្តដំណាក់កាលបន្ទាប់ ដោយយកចិត្តទុកដាក់ដល់បរិការណ៍នៃជំងឺកូវីដ-១៩ ដែលអាចជះឥទ្ធិពលដល់ការកំណត់អាទិភាព ។

លើមូលដ្ឋាននេះ ស័ក្តិសិទ្ធិភាពក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ បានដើរតួនាទីកាន់តែសំខាន់ឡើងក្នុងបរិការណ៍ថ្មីនេះ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានគូសបញ្ជាក់សារជាថ្មីអំពីសារៈសំខាន់នៃហិរញ្ញប្បទានសហប្រតិបត្តិការក្នុងតួនាទីជាកាតាលីករ រួមផ្សំជាមួយនឹងធនធានក្នុងស្រុក ក៏ដូចជាហិរញ្ញប្បទានអភិវឌ្ឍន៍ដទៃទៀត សម្រាប់រួមចំណែកអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចកម្ពុជា ពិសេសសម្រាប់គាំទ្រដល់ការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ និងការស្ដារសេដ្ឋកិច្ចឡើងវិញ ក៏ដូចជាដំណើរនៃការចាកចេញរបស់កម្ពុជា ពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច ។

គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.ន/ក.អ.ក) ដែលជាស្ថាប័នសម្របសម្រួលរបស់រាជរដ្ឋាភិបាល បានដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់ស័ក្តិសិទ្ធិភាពក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ តាមរយៈការអនុវត្តយុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូឆ្នាំ២០១៩-២០២៣ ដែលបានកំណត់គោលការណ៍, យន្តការ និងគោលការណ៍ណែនាំ ដើម្បីធានាភាពជាម្ចាស់របស់រាជរដ្ឋាភិបាល និងពង្រឹងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ដើម្បីឈានទៅសម្រេចគោលដៅនិងអាទិភាពអភិវឌ្ឍន៍ជាតិ ។ ក្នុងន័យនេះ របាយការណ៍ស្ដីពីប្រសិទ្ធភាពកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ សម្រាប់ឆ្នាំ២០២០-២០២១ ត្រូវបានរៀបចំឡើង ដើម្បីឆ្លុះបញ្ចាំងអំពីនិន្នាការនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។ ទិន្នន័យ និងការវិភាគក្នុងរបាយការណ៍នេះ នឹងត្រូវបានប្រើប្រាស់សម្រាប់ជាធាតុចូលក្នុងដំណើរការរៀបចំគោលនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់លើកកម្ពស់ប្រសិទ្ធភាព ក្នុងការប្រើប្រាស់ហិរញ្ញប្បទាន ក៏ដូចជា បន្តពង្រឹងភាពជាដៃគូក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ពិសេសក្នុងបរិការណ៍នៃជំងឺកូវីដ-១៩ ។

# ជំពូក ២

# ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍

## *វឌ្ឍនភាពស្តីពីភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍*

រាជរដ្ឋាភិបាលបានប្តេជ្ញាអនុវត្តគោលការណ៍ស្តីពីភាពជាដៃគូសកល ដែលបានចែងក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៊ូសាន ។ ការប្តេជ្ញា និងកិច្ចប្រឹងប្រែងនេះបានស្តែងចេញតាមរយៈការបន្តចូលរួមក្នុងការផ្តួចផ្តើមនានានៃភាពជាដៃគូសកល និងក្របខណ្ឌតាមដានសូចនាករសមិទ្ធកម្មគន្លឹះដោយផ្តោតលើលទ្ធផលរបស់យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ ។ ការប្តេជ្ញាក្នុងភាពជាដៃគូត្រូវបានអនុវត្ត តាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ។ សូចនាករស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ត្រូវបានប្រើប្រាស់សម្រាប់រៀបចំក្របខណ្ឌលទ្ធផលនៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ និងតាមដានជាទៀងទាត់ តាមរយៈរបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនៅកម្ពុជា ។ ជំពូកនេះនឹងវាស់វែងវឌ្ឍនភាពនៃភាពជាដៃគូ ធៀបនឹងគោលដៅ ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ។ ការវិភាគនេះ គឺជាផ្នែកមួយនៃការត្រួតពិនិត្យតាមដានវឌ្ឍនភាពនៃភាពជាដៃគូ ដែលត្រូវបានប្រើប្រាស់សម្រាប់តម្រង់ទិសកិច្ចពិគ្រោះយោបល់ភាពជាដៃគូជាក់លាក់ (Action Dialogue) និងជាមូលដ្ឋានសម្រាប់កិច្ចពិគ្រោះយោបល់ ក្នុងភាពជាដៃគូដទៃទៀត ។

**គំនូរទី ២.១ ការប្រើប្រាស់ក្របខណ្ឌលទ្ធផលឆ្នាំ២០២០**




**គំនូរទី ២.២ ការប្រើប្រាស់ក្របខណ្ឌលទ្ធផលឆ្នាំ២០២១**




*% នៃហិរញ្ញប្បទានគាំទ្រវិស័យសាធារណៈ

រាជរដ្ឋាភិបាលបានលើកកម្ពស់ការប្រើប្រាស់ក្របខណ្ឌលទ្ធផលប្រកបដោយប្រសិទ្ធភាព ។ ទិន្នន័យបង្ហាញថា ការប្រើប្រាស់ក្របខណ្ឌលទ្ធផលសម្រេចបានប្រមាណ ៩០% ក្នុងឆ្នាំ២០២១ ធៀបនឹងគោលដៅ ៨០% ក្នុងឆ្នាំ២០២៣ ។ លទ្ធផលទទួលបាននេះគឺដោយសារកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការជំរុញសង្គតិភាព ខាងគោលនយោបាយនៅក្នុងផែនការជាតិ ពិសេសផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការតាមវិស័យ ។ ទន្ទឹមនឹងនេះ ក្រសួង និងស្ថាប័នក៏បានរៀបចំក្របខណ្ឌលទ្ធផលតាមវិស័យនីមួយៗ ដែលត្រូវបានប្រើប្រាស់ទូលំទូលាយដោយដៃគូអភិវឌ្ឍន៍ ។ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ រួមមានធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក បានប្រើប្រាស់ក្របខណ្ឌលទ្ធផលជាតិពេញលេញ ។ ភ្នាក់ងារអង្គការសហប្រជាជាតិ បានប្រើប្រាស់ជាមធ្យមច្រើនជាង ៩០% ក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១ ខណៈដែលសហគមន៍អឺរ៉ុបបានបង្កើនការ

ប្រើប្រាស់បន្តិចបន្តួចពី ៣៥% ក្នុងឆ្នាំ២០២០ ទៅ ៥៧% ក្នុងឆ្នាំ២០២១ ។ រីឯសហរដ្ឋអាមេរិក បានបន្ថយការប្រើប្រាស់ពី ៩០% ក្នុងឆ្នាំ២០២០ មកត្រឹម ៤០% ក្នុងឆ្នាំ២០២១ ។ ដៃគូអភិវឌ្ឍន៍ដទៃទៀតបានតម្រឹមការប្រើប្រាស់ក្របខណ្ឌលទ្ធផលរបស់ខ្លួនច្រើនជាង ៦០% ។

**គំនូរទី ២.៣ ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២០**




**គំនូរទី ២.៤ ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២១**




*% នៃហិរញ្ញប្បទានគាំទ្រវិស័យសាធារណៈ

ចំពោះការប្រើប្រាស់ប្រព័ន្ធជាតិ, ៧៨% នៃហិរញ្ញប្បទានដែលត្រូវបានបើកផ្តល់សម្រាប់គាំទ្រដល់វិស័យសាធារណៈ បានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងឆ្នាំ២០២០ និងបន្តធ្លាក់ចុះមកត្រឹម ៧៤% ក្នុងឆ្នាំ២០២១ ពោលគឺទាបជាងទិន្នន័យមូលដ្ឋាន ៧៦% ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ។ ទោះបីឥណទានសម្បទានបានកើនឡើងបន្តបន្ទាប់, ដៃគូអភិវឌ្ឍន៍មួយចំនួននៅតែប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុរបស់ខ្លួន ពិសេសរបាយការណ៍ហិរញ្ញវត្ថុ និងសវនកម្ម ។ GAVI និងមូលនិធិអន្តរជាតិអភិវឌ្ឍន៍កសិកម្ម ដែលជាដៃគូពហុភាគី បានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ១០០% ។រីឯដៃគូទ្វេភាគី រួមមានចិន និងបារាំង ដែលជាអ្នកផ្តល់ឥណទានសម្បទាន បានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ១០០% ដោយសារដៃគូទាំងនេះត្រូវបានចាត់ទុកថា បានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយស្វ័យប្រវត្តិ ។ ដៃគូទ្វេភាគីដទៃទៀត មានវឌ្ឍនភាពចម្រុះក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ អូស្ត្រាលីបានបន្ថយការប្រើប្រាស់ពី ២១% ក្នុងឆ្នាំ២០២០ មកត្រឹមតែ ១៥% ក្នុងឆ្នាំ២០២១ និងអាល្លឺម៉ង់ក៏បានបន្ថយការប្រើប្រាស់ពី ២៥% មក ៩% ក្នុងពេលដូចគ្នា ។

**គំនូរទី ២.៥ ការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ ឆ្នាំ២០២០**




**គំនូរទី ២.៦ ការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ ឆ្នាំ២០២១**




*% នៃហិរញ្ញប្បទានគាំទ្រវិស័យសាធារណៈ

ប្រព័ន្ធលទ្ធកម្មជាតិ គឺជាសមាសភាគទី២ នៃការប្រើប្រាស់ប្រព័ន្ធជាតិ ។ ការប្រើប្រាស់ប្រព័ន្ធនេះ នៅតែជាបញ្ហាប្រឈមសម្រាប់ដៃគូអភិវឌ្ឍន៍ភាគច្រើន ។ ក្នុងឆ្នាំ២០២០ ហិរញ្ញប្បទានដែលបានគាំទ្រវិស័យសាធារណៈចំនួន ៣៣% បានប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ (៤៥% តិចជាងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រង

ហិរញ្ញវត្ថុសាធារណៈ) និងបានកើនដល់ ៣៨% ក្នុងឆ្នាំ២០២១ ដែលបង្ហាញអំពីវឌ្ឍនភាពតិចតួចធៀបនឹងទិន្នន័យ មូលដ្ឋាន ៤៥% ក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ។ ស្ថានភាពនេះអាចបណ្តាលភាគច្រើន មកពីការផ្លាស់ប្តូររបៀបកត់ត្រាគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។ មូលនិធិអន្តរជាតិអភិវឌ្ឍន៍កសិកម្ម, GAVI និង ធនាគារពិភពលោក បានប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិពេញលេញ ក្នុងពេលដែលសហគមន៍អឺរ៉ុប និងជប៉ុន បានប្រើប្រាស់ជាមធ្យម ចំនួន ៦០% និង ៧០% នៃធនធានរបស់ខ្លួន ។ អង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន និងស្វីស បានប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិតិចជាង ១០% និង ៥% ។ ក្នុងន័យនេះ ការឈាន ទៅសម្រេចគោលដៅ ៦០% ត្រឹមឆ្នាំ២០២៣ ទាមទារកិច្ចប្រឹងប្រែងបន្ថែមទៀតរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ពិសេសដៃគូដែលផ្តល់ឥណទានសម្បទាន ។

**គំនូរទី ២.៧ ហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋឆ្នាំ២០២០**




**គំនូរទី ២.៨ ហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋឆ្នាំ២០២១**




*%នៃហិរញ្ញប្បទានគាំទ្រវិស័យសាធារណៈ

ហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋ បានធ្លាក់ចុះពី ៩១% ក្នុងឆ្នាំ២០២០ ដល់ ៨៦% ក្នុងឆ្នាំ ២០២១ ។ ការធ្លាក់ចុះបន្តិចនេះ អាចបណ្តាលមកពីសមិទ្ធកម្មរបស់ដៃគូអភិវឌ្ឍន៍ភាគច្រើនបានធ្លាក់ចុះក្រោមមធ្យមភាគនៃហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋ (៨៦%) ។ ធនាគារពិភពលោកបានកាត់បន្ថយការប្រើប្រាស់ហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋពីប្រមាណ ៩៩% ក្នុងឆ្នាំ២០២០ មកត្រឹម ៩៤% ក្នុងឆ្នាំ២០២១ ។ មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម បានបង្កើនការប្រើប្រាស់ ពី ៩១% ទៅ ៩៥% ក្នុងពេលដូចគ្នា ខណៈដែលសាធារណរដ្ឋប្រជាមានិតចិន, ជប៉ុន និងធនាគារអភិវឌ្ឍន៍អាស៊ី បានប្រើប្រាស់ពេញលេញ ។

ដោយសារការប្រើប្រាស់ហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋ គឺស្ទើរតែពេញលេញ, ដៃគូផ្តល់ឥណទានសម្បទានសំខាន់ៗ គួរត្រូវយកចិត្តទុកដាក់បន្ថែមទៀត ខណៈដែលឥណទានរបស់ពួកគេស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវដាក់បញ្ចូលទៅក្នុងច្បាប់ថវិកា ។ លើសពីនេះ ហិរញ្ញប្បទានឥតសំណងក្នុងទម្រង់ជាការគាំទ្រថវិកា និងតាមគម្រោង/កម្មវិធីវិនិយោគ ក៏ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធថវិកា និងកត់ត្រាក្នុងថវិការដ្ឋ ។ ការរក្សាបានវឌ្ឍនភាពនេះ គឺជាការចាំបាច់ ក្នុងការឈានទៅសម្រេចគោលដៅ ៩៥% ត្រឹមឆ្នាំ២០២៣ នៃយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ។

**គំនូរទី ២.៩ ភាពអាចទស្សន៍ទាយបាននៃហិរញ្ញប្បទាន ឆ្នាំ ២០២០**




**គំនូរទី ២.១០ ភាពអាចទស្សន៍ទាយបាននៃហិរញ្ញប្បទាន ឆ្នាំ ២០២១**




*%នៃហិរញ្ញប្បទានគាំទ្រវិស័យសាធារណៈ

ទិន្នន័យបង្ហាញថា កម្ពុជាសម្រេចបានវឌ្ឍនភាពល្អលើសូចនាករស្តីពីភាពអាចទស្សន៍ទាយបាននៃហិរញ្ញប្បទានសហប្រតិបត្តិការ ។ ភាពអាចទស្សន៍ទាយបាននៃហិរញ្ញប្បទានប្រចាំឆ្នាំសម្រេចបាន ១១៣% ក្នុងឆ្នាំ២០២០ និង៩៦% ក្នុងឆ្នាំ២០២១ ដែលប្រែប្រួលក្នុងរង្វង់ ១៥% ធៀបនឹងផែនការ ។ ក្នុងឆ្នាំ ២០២០ ដៃគូរួមមាន អង្គការពលកម្មអន្តរជាតិ, សមាគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក បានបើកផ្តល់ហិរញ្ញប្បទានក្នុងរង្វង់ដែលអាចព្យាករណ៍បាន ១០០% ធៀបនឹងផែនការ ។ ចិន, អាល្លឺម៉ង់ និងមូលនិធិសកល បានបើកផ្តល់ធនធានគាំទ្រវិស័យសាធារណៈ ក្នុងរង្វង់ដែលអាចព្យាករណ៍បាន ក្នុងរង្វង់ប្រែប្រួល ១៧% ។ ហិរញ្ញប្បទានរបស់អូស្ត្រាលី (២៣៥%) និងអង្គការយូនីសេហ្វ (១៩៤%) ពុំអាចព្យាករណ៍បាន ទន្ទឹមនឹងពេលដែលដៃគូជាច្រើនពុំបានផ្តល់ផែនការបើកផ្តល់ហិរញ្ញប្បទានជាក់លាក់ សម្រាប់គណនាភាពអាចទស្សន៍ទាយបាននូវហិរញ្ញប្បទាននេះបានឡើយ ។ លើសពីនេះ ភាពអាចទស្សន៍ទាយបាននៃហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងជប៉ុនបានកើនដល់ ១៦០% និង១៤៦% ដោយសារដៃគូទាំងពីរនេះបានបើកផ្តល់ហិរញ្ញប្បទានទាំងអស់របស់គម្រោងតែមួយលើក ដើម្បីគាំទ្រការឆ្លើយតបនឹងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២០ ។

ក្នុងឆ្នាំ២០២១ ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ រួមមានអង្គការសុខភាពពិភពលោក, អង់គ្លេស, សហរដ្ឋអាមេរិក, អូស្ត្រាលី, និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ នៅមិនអាចព្យាករណ៍បាន ដោយការគ្រោងផ្តល់ហិរញ្ញប្បទាន និងការបើកផ្តល់ជាក់ស្តែងរបស់ពួកគេ មានគម្លាតខុសគ្នាពីរដង រហូតដល់សែសិបដង ។ ចិន, ជប៉ុន, សាធារណរដ្ឋកូរ៉េ, និងអាល្លឺម៉ង់ បានផ្តល់ហិរញ្ញប្បទានក្នុងរង្វង់ដែលអាចព្យាករណ៍បាន ។ ការផ្តល់ហិរញ្ញប្បទានដែលអាចព្យាករណ៍បានពិតជាមានសារសំខាន់ ដោយសារថវិកា គឺជាឧបករណ៍សំខាន់របស់រាជរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយ ដើម្បីសម្រេចគោលដៅនៃយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ។ ភាពខ្វះចន្លោះរបស់ដៃគូអភិវឌ្ឍន៍ក្នុងការផ្តល់ហិរញ្ញប្បទានដែលអាចព្យាករណ៍បាន ធៀបនឹងផែនការអាចបណ្តាលមកពី÷ ក) ខ្វះការយកចិត្តទុកដាក់ក្នុងការប៉ាន់ស្មានហិរញ្ញប្បទាន ពិសេសក្នុងដំណាក់កាលរៀបចំផែនការ, ខ) ការអនុវត្តគម្រោងមិនត្រឹមត្រូវតាមផែនការ ឬ គ) ការកត់ត្រាទិន្នន័យមិនត្រឹមត្រូវក្នុងដំណាក់កាលរៀបចំផែនការ ឬក្នុងដំណាក់កាលរៀបចំរបាយការណ៍ ។ លើមូលដ្ឋាននេះ ការរៀបចំកម្មវិធី, ការកត់ត្រាទិន្នន័យ និង

ការផ្តល់របាយការណ៍ត្រឹមត្រូវស្តីពីការបើកផ្តល់ហិរញ្ញប្បទាន គឺជាកិច្ចការសំខាន់សម្រាប់ធានាភាពអាចទស្សន៍-ទាយបាននៃហិរញ្ញប្បទានសហប្រតិបត្តិការ ។

**គំនូរទី ២.១១ ហិរញ្ញប្បទានឥតភ្ជាប់លក្ខខណ្ឌឆ្នាំ២០២០**




**គំនូរទី ២.១២ ហិរញ្ញប្បទានឥតភ្ជាប់លក្ខខណ្ឌឆ្នាំ២០២១**




*%នៃហិរញ្ញប្បទានគាំទ្រវិស័យសាធារណៈ

ហិរញ្ញប្បទានឥតភ្ជាប់លក្ខខណ្ឌមានវឌ្ឍនភាពតិចតួច ដោយកើនពី ៧៤% ក្នុងឆ្នាំ២០២០ ដល់ ៧៧% ក្នុងឆ្នាំ២០២១ ។ ទោះជាយ៉ាងនេះក្តី ដៃគូអភិវឌ្ឍន៍ភាគច្រើនសម្រេចបានវឌ្ឍនភាពគួរកត់សម្គាល់ក្នុងការផ្តល់ហិរញ្ញប្បទានឥតភ្ជាប់លក្ខខណ្ឌពេញលេញ ឬដោយផ្នែក ដោយបានកើនលើសអត្រាជាមធ្យម ។ ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូភាគខាងត្បូង ពិសេសសាធារណរដ្ឋប្រជាមានិតចិន មិនត្រូវបានចាត់បញ្ចូលជាហិរញ្ញប្បទានឥតភ្ជាប់លក្ខខណ្ឌឡើយ ដោយសារការកំណត់និយមន័យរបស់ខ្លួន ។ ក្នុងន័យនេះ ទំហំសរុបនៃហិរញ្ញប្បទានឥតភ្ជាប់លក្ខខណ្ឌ ត្រូវផ្សារភ្ជាប់នឹងសមាមាត្រហិរញ្ញប្បទានរបស់សាធារណរដ្ឋប្រជាមានិតចិន ដែលជាដៃគូដ៏ធំរបស់កម្ពុជា ។

**តារាង ២.១ : សូចនាករស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍តាមដៃគូអភិវឌ្ឍន៍**

| ដៃគូអភិវឌ្ឍន៍ | ការប្រើប្រាស់ក្របខណ្ឌលទ្ធផល(%) | | ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (%) | | ការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ (%) | | ហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋ (%) | | ភាពអាចទស្សន៍ទាយបាននៃហិរញ្ញប្បទានប្រចាំឆ្នាំ (%) | | ហិរញ្ញប្បទានឥតភ្ជាប់លក្ខខណ្ឌ និងភ្ជាប់ដោយផ្នែក(%) | | ផែនការប្រចាំឆ្នាំផ្តល់ឱ្យប្រទេសដៃគូ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2020 ជាក់ស្តែង | 2021 ប៉ាន់ស្មាន | 2020 ជាក់ស្តែង | 2021 ប៉ាន់ស្មាន | 2020 ជាក់ស្តែង | 2021 ប៉ាន់ស្មាន | 2020 | 2021 | 2020 | 2021 | 2020 | 2021 | 2020 ជាក់ស្តែង | 2021 ប៉ាន់ស្មាន |
| **UN Agencies** | | | | | | | | | | | | | | |
| FAO | 100 | 100 | 0 | 0 | 0 | 0 | 0 | 0 | 40 | 0 | 100 | 100 | Yes | Yes |
| IAEA | 87 | 78 | 0 | 0 | 0 | 0 | 0 | 0 | 0 | 98 | 100 | 100 | No | No |
| IFAD | 100 | 100 | 100 | 100 | 100 | 100 | 91 | 95 | 74 | 63 | 100 | 100 | Yes | Yes |
| ILO | 100 | 100 | 0 | 0 | 0 | 0 | 0 | 0 | 102 | 103 | 100 | 100 | Yes | Yes |
| UN Women | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | No | No |
| UNAIDS | 100 | 100 | 0 | 0 | 0 | 0 | 0 | 0 | 0 | 91 | 100 | 100 | Yes | Yes |
| UNCOHCHR | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | No | No |
| UNDP | 100 | 100 | 0 | 0 | 0 | 0 | 0 | 0 | 83 | 209 | 100 | 100 | Yes | Yes |
| UNESCO | 90 | 100 | 0 | 0 | 0 | 0 | 0 | 0 | 63 | 109 | 100 | 100 | Yes | Yes |
| UNFPA | 100 | 100 | 12 | 7 | 18 | 10 | 0 | 0 | 134 | 127 | 100 | 100 | Yes | Yes |
| UNICEF | 100 | 100 | 100 | 100 | 0 | 0 | 0 | 0 | 194 | 82 | 100 | 100 | Yes | Yes |
| UNIDO | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | Yes | Yes |
| WFP | 100 | 35 | 0 | 0 | 0 | 0 | 0 | 0 | 36 | 267 | 100 | 100 | Yes | Yes |
| WHO | 100 | 100 | 0 | 0 | 0 | 0 | 0 | 0 | 0 | 2415 | 100 | 100 | Yes | Yes |

| ដៃគូអភិវឌ្ឍន៍ | ការប្រើប្រាស់ក្របខណ្ឌលទ្ធផល(%) | | ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (%) | | ការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ (%) | | ហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋ (%) | | ភាពអាចទស្សន៍ទាយបាននៃហិរញ្ញប្បទានប្រចាំឆ្នាំ (%) | | ហិរញ្ញប្បទានឥតភ្ជាប់លក្ខខណ្ឌ និងភ្ជាប់ដោយផ្នែក(%) | | ផែនការប្រចាំឆ្នាំផ្ដល់ឱ្យប្រទេសដៃគូ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2020 ជាក់ស្ដែង | 2021 ប៉ាន់ស្មាន | 2020 ជាក់ស្ដែង | 2021 ប៉ាន់ស្មាន | 2020 ជាក់ស្ដែង | 2021 ប៉ាន់ស្មាន | 2020 | 2021 | 2020 | 2021 | 2020 | 2021 | 2020 ជាក់ស្ដែង | 2021 ប៉ាន់ស្មាន |
| **Multilateral Partners** | | | | | | | | | | | | | | |
| ADB | 100 | 100 | 67 | 67 | 0 | 0 | 100 | 100 | 160 | 79 | 100 | 100 | Yes | Yes |
| GAVI | 0 | 0 | 100 | 100 | 100 | 100 | 0 | 0 | 153 | 100 | 100 | 100 | No | No |
| Global Fund | 100 | 0 | 0 | 0 | 0 | 100 | 0 | 0 | 117 | 104 | 100 | 100 | Yes | Yes |
| World Bank | 100 | 100 | 66 | 67 | 100 | 100 | 99 | 94 | 64 | 55 | 100 | 100 | Yes | Yes |
| **European Partners** | | | | | | | | | | | | | | |
| EU/EC | 35 | 57 | 79 | 60 | 79 | 60 | 90 | 97 | 103 | 47 | 100 | 100 | Yes | Yes |
| Czech Rep. | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | Yes | Yes |
| France | 98 | 99 | 97 | 98 | 96 | 97 | 100 | 75 | 30 | 147 | 100 | 100 | Yes | Yes |
| Germany | 96 | 95 | 25 | 9 | 43 | 15 | 10 | 16 | 118 | 94 | 100 | 100 | Yes | Yes |
| Ireland | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | No | No |
| Sweden | 66 | 0 | 44 | 0 | 66 | 0 | 0 | 0 | 144 | 87 | 100 | 100 | Yes | Yes |
| Switzerland | 100 | 100 | 6 | 2 | 9 | 4 | 0 | 73 | 75 | 20 | 100 | 100 | Yes | Yes |
| UK | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 4659 | 0 | 100 | Yes | Yes |
| **Bilateral Partners** | | | | | | | | | | | | | | |
| Australia | 60 | 73 | 21 | 15 | 31 | 22 | 0 | 0 | 235 | 245 | 100 | 100 | Yes | Yes |
| Canada | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | Yes | Yes |
| China | 75 | 77 | 100 | 100 | 0 | 0 | 100 | 100 | 117 | 107 | 0 | 0 | Yes | Yes |
| Japan | 100 | 100 | 79 | 72 | 79 | 72 | 97 | 97 | 146 | 110 | 100 | 100 | Yes | Yes |
| New Zealand | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | Yes | Yes |
| Rep. Korea | 76 | 77 | 67 | 65 | 0 | 1 | 61 | 66 | 129 | 103 | 97 | 100 | Yes | Yes |
| USA | 90 | 40 | 0 | 0 | 0 | 0 | 0 | 0 | 111 | 250 | 100 | 100 | Yes | Yes |
| **Total** | **89** | **88** | **78** | **74** | **33** | **38** | **91** | **86** | **113** | **96** | **74** | **77** | **99** | **99** |

តាមរយៈការត្រួតពិនិត្យសមិទ្ធកម្មនៃការអនុវត្តសូចនាករស្ដីពីភាពជាដៃគូនៅកម្ពុជា ក្នុងឆ្នាំ២០២០-២០២១, យើងអាចរៀបចំការវាយតម្លៃសង្ខេបលើក្របខណ្ឌលទ្ធផលរបស់យុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ។ ផ្អែកលើការត្រួតពិនិត្យតាមដាន, គោលការណ៍ និងគោលដៅដែលបានកំណត់ក្នុងយុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ នៅរក្សាភាពសមស្របនៅក្នុងបរិការណ៍ដែលកំពុងវិវត្តយ៉ាងឆាប់រហ័ស និងមិនអាចប៉ាន់ប្រមាណទុកជាមុនបាន ។ ការប្រើប្រាស់ក្របខណ្ឌលទ្ធផល និងការកំណត់ផែនការឆ្ពោះទៅមុខ សម្រេចបានមុនគោលដៅកំណត់ ។ ហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋ និងភាពអាចទស្សន៍ទាយបាននៃហិរញ្ញប្បទានកំពុងមានវឌ្ឍនភាពល្អប្រសើរ ហើយរំពឹងថានឹងសម្រេចបានគោលដៅនៅឆ្នាំ២០២៣ ។ ទោះជាយ៉ាងនេះក្ដី ក៏តម្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀតលើការប្រើប្រាស់ប្រព័ន្ធជាតិ ដោយសារដៃគូអភិវឌ្ឍន៍ភាគច្រើនមិនទាន់ប្រើប្រាស់ទូលំទូលាយនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធលទ្ធកម្មជាតិនៅឡើយ ។

# ជំពូកទី ៣
# ការវិវត្តនៃហិរញ្ញប្បទានសហប្រតិបត្តិការ

រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលសំខាន់ៗជាច្រើន ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន ទន្ទឹមនឹងការទទួលស្គាល់អំពីកិច្ចប្រឹងប្រែង និងការចូលរួមពីដៃគូអភិវឌ្ឍន៍ តាមរយៈកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូប្រកបដោយប្រសិទ្ធភាព ។ ជំពូកនេះនឹងបង្ហាញអំពីការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការក្នុងរយៈពេលមធ្យម ដោយផ្តោតសំខាន់លើការបើកផ្តល់ក្នុងឆ្នាំ ២០២០, ការប៉ាន់ស្មានក្នុងឆ្នាំ២០២១ និងការព្យាករណ៍សម្រាប់ឆ្នាំ២០២២ ដោយប្រើប្រាស់ទិន្នន័យដកស្រង់ពីប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការកម្ពុជា ត្រឹមខែមករា ឆ្នាំ២០២២ ។ ជំពូកនេះនឹងវិភាគអំពីសមាសភាគសំខាន់ៗ នៃហិរញ្ញប្បទាន និងការប្រែប្រួលនៃការបើកផ្តល់របស់ដៃគូអភិវឌ្ឍន៍, ការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ, និងតួនាទីហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការគាំទ្រកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ ។

### *ការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ*

គំនូរទី ៣.១ ការបើកផ្តល់ហិរញ្ញប្បទានឆ្នាំ២០១៣-២០២២




ការបើកផ្តល់ហិរញ្ញប្បទានសរុប បានកើនឡើងគួរកត់សម្គាល់ពី ១.៤៩៧ លានដុល្លារ ក្នុងឆ្នាំ ២០១៨ និង ១.៩៨១ លានដុល្លារ ក្នុងឆ្នាំ ២០១៩ ដល់ ២.៤១០ លានដុល្លារ ក្នុងឆ្នាំ ២០២០ ទោះបីមានបញ្ហាប្រឈម អំពីលទ្ធភាពធនធានសាធារណៈ របស់ប្រទេសដៃគូអភិវឌ្ឍន៍ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ។ ទោះយ៉ាងនេះក្តី ក្នុងឆ្នាំ ២០២១ ការបើកផ្តល់ហិរញ្ញ-ប្បទាន ត្រូវបានប៉ាន់ស្មានថា ធ្លាក់ចុះមកត្រឹម ២.០៣ លានដុល្លារ ។ ក្នុងចន្លោះ ឆ្នាំ ២០១៩-២០២១, អនុបាតនៃឥណទានសម្បទាន រក្សាបានទំហំថេរ ក្នុងរង្វង់៥០% ប៉ុន្តែ បានកើនឡើងដល់៦០% ក្នុងឆ្នាំ ២០២០ ដោយសារការប្រើប្រាស់ទម្រង់ “បើកផ្តល់ហិរញ្ញប្បទានតែមួយលើក” ពីដៃគូផ្តល់ឥណទានមួយចំនួន ។

### *ហិរញ្ញប្បទានសម្រាប់ប្រជាជនម្នាក់ និងអនុបាតហិរញ្ញប្បទានធៀបនឹង ផ.ស.ស*

គំនូរទី ៣.២ បង្ហាញពីនិន្នាការនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ និងតួនាទីក្នុងការរួមចំណែកអភិវឌ្ឍន៍ជាតិ ដូចជាការគិតគូរផលធៀបនឹង ផ.ស.ស ។ អនុបាតហិរញ្ញប្បទានធៀបនឹង ផ.ស.ស បានធ្លាក់ចុះជាលំដាប់ពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៨ ដោយសារការកើនឡើងបន្តបន្ទាប់នៃ ផ.ស.ស ប៉ុន្តែបានកើនខ្ពស់បំផុតដល់ ៩% ក្នុងឆ្នាំ ២០២០ ដោយសារកំណើននៃការបើកផ្តល់ឥណទានសម្បទាន គួបផ្សំនឹងកំណើនអវិជ្ជមានរបស់ ផ.ស.ស ដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ ។ ក្នុងឆ្នាំ២០២១-២០២២ នៅពេលដែលសេដ្ឋកិច្ចកម្ពុជាបានចាប់ផ្តើមងើបឡើងវិញ ហើយហិរញ្ញប្បទានសហប្រតិបត្តិការ

នៅរក្សាទំហំថេរ, អនុបាតហិរញ្ញប្បទានធៀបនឹង ផ.ស.ស ត្រូវបានរំពឹងថា នឹងធ្លាក់ចុះមកក្នុងរង្វង់ ៦% ក្នុងឆ្នាំ ២០២២ ។ រីឯហិរញ្ញប្បទានសម្រាប់ប្រជាជនម្នាក់ បានកើនឡើងចាប់ពីឆ្នាំ២០១៦ និងកើនខ្ពស់បំផុត នៅក្នុងឆ្នាំ២០២០ ។ ជារួម ហិរញ្ញប្បទានសហប្រតិបត្តិការ ធៀបនឹងហិរញ្ញប្បទានសរុប សម្រាប់ការអភិវឌ្ឍជាតិ មានការធ្លាក់ចុះ ទោះបីទំហំហិរញ្ញប្បទានសហប្រតិបត្តិការ អាចរក្សាលំនឹង ឬអាចកើនឡើងក៏ដោយ លើកលែងតែក្នុងឆ្នាំ ២០២០ ដែលហិរញ្ញប្បទានសហប្រតិបត្តិការ គិតទាំងទំហំដុល និងសមាមាត្រ បានកើនឡើងខ្ពស់បំផុត ។

**គំនូរទី ៣.២: ហិរញ្ញប្បទានសម្រាប់ប្រជាជនម្នាក់ និង អនុបាតហិរញ្ញប្បទានធៀបនឹង ផ.ស.ស**




## *ការបើកផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍*

តារាងទី ៣.១ បង្ហាញពីការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០២២ ។ ការបើកផ្តល់ហិរញ្ញប្បទានរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិបានកើនឡើងគួរកត់សម្គាល់ ។ ក្នុងឆ្នាំ ២០២០ ធនាគារអភិវឌ្ឍន៍អាស៊ីបានបង្កើនការបើកផ្តល់ហិរញ្ញប្បទានក្នុងទំហំ ៩៥៣ លានដុល្លារ ពោលគឺបានកើនឡើងស្ទើរទ្វេដង ធៀបនឹងឆ្នាំមុន ដោយសារការបើកផ្តល់ហិរញ្ញប្បទានទាំងអស់តែមួយលើកនៃគម្រោងរបស់ខ្លួន ដែលមានទំហំ២៥០ លានដុល្លារ សំដៅគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិនៃជំងឺកូវីដ-១៩ ។ រីឯធនាគារពិភពលោកបានបង្កើនការគាំទ្រពី ៧៦,៧ លានដុល្លារ ក្នុងឆ្នាំ ២០១៩ ដល់ ៩០,៥ លានដុល្លារ ក្នុងឆ្នាំ២០២០ ។ ក្នុងឆ្នាំ ២០២១ ហិរញ្ញប្បទានរួមរវាងធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក មានទំហំសរុប ប្រមាណ ៣០០ លានដុល្លារ ។ ភ្នាក់ងារអង្គការសហប្រជាជាតិបានបង្កើនការគាំទ្ររបស់ខ្លួនពី ៦៣,៥ លានដុល្លារ ក្នុងឆ្នាំ ២០១៩ ដល់ ៩០ លានដុល្លារ ក្នុងឆ្នាំ ២០២១ ។

ក្នុងចន្លោះឆ្នាំ ២០១៩ -២០២០, ដៃគូទ្វេភាគីជាច្រើនបានបង្កើនការគាំទ្ររបស់ខ្លួន ។ ការបើកផ្តល់ធនធានរបស់សាធារណរដ្ឋប្រជាមានិតចិន, ជប៉ុន និងកូរ៉េ បានកើនឡើងពី ៧៨៤ លានដុល្លារ ស្មើនឹង ៤០% នៃ ហិរញ្ញប្បទានសរុប ក្នុងឆ្នាំ២០១៩ ដល់ ១ ១០០ លានដុល្លារ ស្មើនឹង ៤៦% នៃហិរញ្ញប្បទានសរុប ក្នុងឆ្នាំ ២០២០ ។ ចំណែកការបើកផ្តល់ហិរញ្ញប្បទានរបស់ប្រទេសជាសមាជិកសហភាពអឺរ៉ុប ក៏បានកើនឡើងផងដែរ ពីឆ្នាំ ២០២០-ដល់ឆ្នាំ ២០២១ ។ ការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអឺរ៉ុបបានកើនឡើងពី ២៣៦ លានដុល្លារ ក្នុងឆ្នាំ ២០២០ (ស្មើ ១០% នៃហិរញ្ញប្បទានសរុប) ដល់ ២៦៩ លានដុល្លារ ក្នុងឆ្នាំ ២០២១ (ស្មើ ១៣% នៃហិរញ្ញប្បទានសរុប) ទោះបីមានការធ្លាក់ចុះ ធៀបនឹងឆ្នាំ ២០១៩ ដែលមាន ៣១៧ លាន ដុល្លារ (ស្មើ ១៦% នៃហិរញ្ញប្បទានសរុប) ។ ជារួម ក្នុងចន្លោះឆ្នាំ ២០១៩-២០២១ ការបើកផ្តល់ហិរញ្ញប្បទានសរុបប្រចាំឆ្នាំ មានទំហំប្រមាណ ២.០០០ លាន ដុល្លារ ។ ការបើកផ្តល់ហិរញ្ញប្បទានសរុបកើនឡើងខ្ពស់ ក្នុងឆ្នាំ ២០២០ ដោយសារគម្រោងពីរដែលមានទំហំហិរញ្ញប្បទានធំបានអនុវត្តការបើកផ្តល់ហិរញ្ញប្បទានតែមួយលើក សម្រាប់គាំទ្រកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ និងការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិ ។

**តារាងទី ៣.១: ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍន៍ (លានដុល្លារ)**

| ដៃគូអភិវឌ្ឍន៍ | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 ប៉ាន់ស្មាន | 2022 ព្យាករណ៍ |
|---|---|---|---|---|---|---|---|---|---|---|
| **ភ្នាក់ងារអង្គការសហប្រជាជាតិ** | | | | | | | | | | |
| ធនធានសរុប | 100.6 | 107.2 | 93.7 | 91.7 | 87.4 | 86.2 | 83.7 | 94.7 | 124.2 | - |
| ធនធានផ្ទាល់ | 50.1 | 53.9 | 47.1 | 65.7 | 59.4 | 62.4 | 63.5 | 77.4 | 91.2 | 76.8 |
| **ដៃគូពហុភាគី** | | | | | | | | | | |
| ធនាគារពិភពលោក | 35.5 | 50.6 | 17.6 | 17.6 | 21.1 | 30.5 | 76.7 | 90.5 | 87.4 | 137.4 |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 171.4 | 129.8 | 137.2 | 118.2 | 125.7 | 122.8 | 243 | 452.6 | 204.8 | 160.9 |
| GAVI Alliance | 10.7 | 5.5 | 19.0 | 16.3 | 10.9 | 7.9 | 20.1 | 8.9 | 9.1 | - |
| មូលនិធិសកល | 45.4 | 54.6 | 33.3 | 28.2 | 33.1 | 19.9 | 40.9 | 39.7 | 42.8 | 41.1 |
| **សរុប** | **313.0** | **294.4** | **254.3** | **246.0** | **250.1** | **243.6** | **444.2** | **669.8** | **436.2** | **416.5** |
| **សហភាពអឺរ៉ុប** | | | | | | | | | | |
| គណៈកម្មការអឺរ៉ុប | 36.6 | 70.3 | 55.8 | 55.7 | 50.8 | 88.4 | 65.5 | 89.4 | 76.9 | 108.7 |
| សាធារណរដ្ឋឆែក | 1.0 | 1.2 | 1.2 | 1.5 | 1.3 | 1.1 | 1.7 | 2.2 | 2.7 | 1.9 |
| បារាំង | 17.8 | 59.5 | 63.3 | 32.1 | 90.8 | 80.6 | 195.4 | 85.7 | 117.4 | 130.0 |
| អាល្លឺម៉ង់ | 34.3 | 29.8 | 25.8 | 46.9 | 38.4 | 37.3 | 29.5 | 29.8 | 44.8 | 82.9 |
| អៀកឡង់ | 1.2 | 0.7 | 0.6 | 0.6 | 0.7 | 0.7 | 0.8 | 1.2 | 1.6 | - |
| ស៊ុយអែត | 33.8 | 33.0 | 21.8 | 30.1 | 33.5 | 23.8 | 23.1 | 27.1 | 22.6 | 18.0 |
| ចក្រភពអង់គ្លេស | 13.7 | 0.07 | 0.2 | 1.6 | 2.3 | 1.2 | 1.1 | 0.9 | 3.4 | 1.6 |
| **សរុប** | **148.3** | **200.6** | **168.7** | **168.6** | **217.8** | **233.0** | **317.0** | **236.2** | **269.3** | **343.2** |
| **ដៃគូទ្វេភាគី** | | | | | | | | | | |
| អូស្ត្រាលី | 59.2 | 64.9 | 55.9 | 51.9 | 58.3 | 50.0 | 41.2 | 33.1 | 66.5 | 35.3 |
| កាណាដា | 11.8 | 5.7 | 3.8 | 3.2 | 3.4 | 3.9 | 2.8 | 2.1 | 2.9 | 2.2 |
| សាធារណរដ្ឋប្រជាមានិតចិន | 436.6 | 347.8 | 339.4 | 307.2 | 415.8 | 352.0 | 503.7 | 494.8 | 343.1 | 260.7 |
| ជប៉ុន | 130.8 | 111.4 | 110.4 | 119.7 | 146.4 | 175.4 | 207.7 | 501.7 | 400.6 | 468.2 |
| នូវែលហ្សេឡង់ | 3.2 | 6.0 | 4.9 | 4.0 | 4.9 | 5.0 | 7.2 | 5.9 | 8.6 | 2.6 |
| សាធារណរដ្ឋកូរ៉េ | 50.1 | 80.3 | 62.0 | 42.0 | 57.1 | 53.8 | 72.8 | 103.3 | 119.8 | 141.7 |
| ស្វីស | 7.8 | 11.8 | 13.0 | 15.8 | 15.5 | 13.6 | 12.9 | 15.6 | 17.1 | 9.8 |
| សហរដ្ឋអាមេរិក | 93.5 | 91.6 | 101.0 | 77.9 | 93.2 | 91.7 | 95.3 | 93.0 | 112.1 | 97.1 |
| **សរុប** | **793.1** | **719.6** | **690.4** | **621.6** | **794.5** | **745.6** | **943.6** | **1,249.4** | **1,070.7** | **1,017.4** |
| **NGO ធនធានផ្ទាល់** | **220.8** | **228.9** | **237.0** | **251.0** | **259.8** | **274.9** | **276.4** | **255.4** | **250.3** | **83.2** |
| **សរុបរួម** | **1,475.1** | **1,443.4** | **1,350.1** | **1,287.1** | **1,522.2** | **1,497.1** | **1,981.2** | **2,410.8** | **2,026.6** | **1,860.03** |

តារាងទី ៣.២ បង្ហាញអំពីទម្រង់នៃការបើកផ្តល់ហិរញ្ញប្បទាន ពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០២២ ។ ទោះបី មានការប្រណាំងប្រជែងខាងធនធានសាធារណៈរវាងបណ្តាប្រទេសជាដៃគូ និងលទ្ធភាពផ្តល់ធនធានរបស់ដៃគូអភិវឌ្ឍន៍ក្នុងបណ្តាឆ្នាំចុងក្រោយ, ការបើកផ្តល់ហិរញ្ញប្បទាននៅកម្ពុជានៅតែកើនឡើងប្រមាណ ២២% ក្នុងឆ្នាំ២០២០ ប៉ុន្តែអាចធ្លាក់ចុះបន្តិចមកត្រឹម ១៦% ក្នុងឆ្នាំ ២០២១ ធៀបនឹងឆ្នាំ ២០២០ ។ ក្នុងឆ្នាំ ២០២០, ហិរញ្ញប្បទានឥតសំណងបានកើនដល់ ៩៥៩ លានដុល្លារ ស្មើនឹង ៤០% ធៀបនឹងហិរញ្ញប្បទានសរុប និងបានធ្លាក់ចុះ ៩% ធៀបនឹងឆ្នាំ ២០១៩ ។ ឥណទានសម្បទានបានកើនខ្ពស់បំផុតដល់ ១.៤៥២ លានដុល្លារ ស្មើនឹង ៦០% នៃ ហិរញ្ញប្បទានសរុប (កើន ៩% ធៀបឆ្នាំ ២០១៩) ដែលភាគច្រើនជាហិរញ្ញប្បទានរបស់សាធារណរដ្ឋប្រជាមានិតចិន, ជប៉ុន, ធនាគារអភិវឌ្ឍន៍អាស៊ី, ធនាគារពិភពលោក, កូរ៉េ និងបារាំង ។ ក្នុងឆ្នាំ ២០២១ ហិរញ្ញប្បទានឥតសំណងមានទំហំប្រហែលនឹងឥណទានសម្បទានដែរ ។ លើសពីនេះ ការព្យាករណ៍ក្នុងឆ្នាំ២០២២ បានបង្ហាញថាឥណទានសម្បទានអាចនឹងបន្តកើនឡើង ស្របពេលដែលហិរញ្ញប្បទាន

### តារាងទី ៣.២: ទម្រង់នៃការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ (លានដុល្លារ)

| ដៃគូអភិវឌ្ឍន៍ | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 ប៉ាន់ស្មាន | 2022 ព្យាករណ៍ |
|---|---|---|---|---|---|---|---|---|---|---|
| **សាធារណរដ្ឋប្រជាមានិតចិន** | | | | | | | | | | |
| Grant | 0.4 | | 4.5 | 3.4 | 38.7 | 70.2 | 92.6 | 96.7 | 78 | 27.6 |
| Loan | 436.2 | 347.8 | 334.9 | 303.8 | 377.1 | 281.8 | 411 | 398 | 265.2 | 233.1 |
| **Total:** | **436.6** | **347.8** | **339.4** | **307.2** | **415.8** | **352** | **503.7** | **494.8** | **343.1** | **260.7** |
| **ជប៉ុន** | | | | | | | | | | |
| Grant | 107.6 | 90.9 | 85.2 | 88.2 | 97 | 102.4 | 114.3 | 116.7 | 118.2 | 77.9 |
| Loan | 23.2 | 20.5 | 25.2 | 31.5 | 49.4 | 73 | 93.4 | 385 | 282.4 | 390.3 |
| **Total:** | **130.8** | **111.4** | **110.4** | **119.7** | **146.4** | **175.4** | **207.7** | **501.7** | **400.6** | **468.2** |
| **សហភាពអឺរ៉ុប និងសមាជិក** | | | | | | | | | | |
| Grant | 143.8 | 156.9 | 115.8 | 147.4 | 137.5 | 165.1 | 131.9 | 167.7 | 164.9 | 202.1 |
| Loan | 4.5 | 43.6 | 52.8 | 21.2 | 80.3 | 67.9 | 185.1 | 68.5 | 104.4 | 141.1 |
| **Total:** | **148.3** | **200.6** | **168.7** | **168.6** | **217.8** | **233.0** | **317.0** | **236.2** | **269.3** | **343.2** |
| **ធនាគារអភិវឌ្ឍន៍អាស៊ី** | | | | | | | | | | |
| Grant | 42.4 | 50.1 | 31.4 | 21.9 | 23 | 24.3 | 37.4 | 24 | 12.8 | 11.7 |
| Loan | 129 | 79.6 | 105.8 | 96.3 | 102.7 | 98.6 | 205.6 | 428.6 | 192.1 | 149.2 |
| **Total:** | **171.4** | **129.8** | **137.2** | **118.2** | **125.7** | **122.8** | **243** | **452.6** | **204.8** | **160.9** |
| **សាធារណរដ្ឋកូរ៉េ** | | | | | | | | | | |
| Grant | 21 | 29.1 | 33 | 33.7 | 27.7 | 29.9 | 30.8 | 35.7 | 46.4 | 35.2 |
| Loan | 29.1 | 51.2 | 28.7 | 8.3 | 29.4 | 23.9 | 42 | 67.6 | 73.4 | 106.5 |
| **Total:** | **50.1** | **80.3** | **61.7** | **42** | **57.1** | **53.8** | **72.8** | **103.3** | **119.8** | **141.7** |
| **ធនាគារពិភពលោក** | | | | | | | | | | |
| Grant | 23.3 | 16.1 | 15.7 | 11.8 | 7.3 | 3.3 | 1.4 | 0.8 | 1.3 | 1.9 |
| Loan | 12.2 | 34.5 | 1.9 | 5.8 | 13.8 | 27.2 | 75.3 | 89.8 | 86.1 | 135.5 |
| **Total:** | **35.5** | **50.6** | **17.6** | **17.6** | **21.1** | **30.5** | **76.7** | **90.6** | **87.4** | **137.4** |
| **ដៃគូអភិវឌ្ឍន៍ផ្សេងៗ** | | | | | | | | | | |
| Grant | 280.4 | 288.2 | 272.2 | 255.2 | 273.3 | 246.0 | 275.9 | 261.4 | 337.0 | 248.9 |
| Loan | 1.2 | 5.7 | 5.8 | 7.6 | 5.1 | 8.4 | 7.9 | 14.8 | 14.2 | 16.1 |
| **Total:** | **281.6** | **294.0** | **278.0** | **262.8** | **278.5** | **254.5** | **283.8** | **276.3** | **351.2** | **265.1** |
| **អង្គការមិនមែនរដ្ឋាភិបាល (ធនធានផ្ទាល់)** | | | | | | | | | | |
| Grant | 220.8 | 228.9 | 237.0 | 251.0 | 259.8 | 274.9 | 277.0 | 255.4 | 250.3 | 83.2 |
| **Total:** | **220.8** | **228.9** | **237.0** | **251.0** | **259.8** | **274.9** | **277.0** | **255.4** | **250.3** | **83.2** |
| **សរុបរួម** | | | | | | | | | | |
| **Grant** | **839.7** | **860.3** | **794.9** | **812.6** | **864.4** | **916.2** | **961.3** | **958.5** | **1008.9** | **688.5** |
| % Grant | 57% | 60% | 59% | 63% | 57% | 61% | 49% | 40% | 50% | 37% |
| **Loan** | **635.4** | **583.1** | **555.1** | **474.5** | **657.8** | **580.9** | **1,020.5** | **1,452.3** | **1,017.8** | **1,171.8** |
| % Loan | 43% | 40% | 41% | 37% | 43% | 39% | 51% | 60% | 50% | 63% |
| **សរុបរួម** | **1,475.1** | **1,443.4** | **1,350.1** | **1,287.1** | **1,522.2** | **1,497.1** | **1,981.8** | **2,410.8** | **2,026.6** | **1,860.3** |

ឥតសំណងអាចនឹងធ្លាក់ចុះ ។ ទោះជាយ៉ាងនេះក្តី ហិរញ្ញប្បទានសរុបនៅរក្សាកំណើនខ្ពស់ដដែល ទោះបីគម្រោងជាច្រើនសម្រាប់ក្រោយឆ្នាំ២០២២ មិនទាន់បញ្ជាក់ភាពច្បាស់លាស់នៅឡើយ ។ ប្រការដែលប្តូរទៅជាឥណទានសម្បទាន បានបង្ហាញអំពីវឌ្ឍនភាពល្អប្រសើរនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ។ ជាក់ស្តែង ការសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាបរបស់កម្ពុជា បានធ្វើឱ្យដៃគូអភិវឌ្ឍន៍កាត់បន្ថយ

ទំហំហិរញ្ញប្បទានឥតសំណង និងជំនួសដោយការបង្កើនឥណទានសម្បទាន ។ ការប្រែប្រួលនេះបានដើរទន្ទឹមនឹងកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការកៀរគរធនធានក្នុងស្រុក ។

### *ការប្រែប្រួលសំខាន់ៗនៃការបើកផ្ដល់ហិរញ្ញប្បទាន*

ដៃគូអភិវឌ្ឍន៍ រួមមានសាធារណរដ្ឋប្រជាមានិតចិន, ជប៉ុន, កូរ៉េ, បារាំង, ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី បានបើកផ្ដល់ហិរញ្ញប្បទាន ស្មើនឹង៨០% នៃហិរញ្ញប្បទានសរុប ក្នុងឆ្នាំ២០២០ និងប្រមាណ ៧០% នៃហិរញ្ញប្បទានសរុប ក្នុងឆ្នាំ ២០២១ និង ២០២២ ។ គំនូរទី៣.៣ បង្ហាញថាសាធារណរដ្ឋប្រជាមានិតចិន គឺជាដៃគូធំជាងគេ, បន្ទាប់មកគឺ ជប៉ុន និងធនាគារអភិវឌ្ឍន៍អាស៊ី ។ ការបើកផ្ដល់ហិរញ្ញប្បទានរបស់សាធារណរដ្ឋប្រជាមានិតចិនបានកើនខ្ពស់បំផុតក្នុងឆ្នាំ២០១៩ និងឆ្នាំ២០២០ ក្នុងទំហំ៥០០ លានដុល្លារ ។ ក្នុងឆ្នាំ២០២០ ការបើកផ្ដល់ហិរញ្ញប្បទានរបស់ជប៉ុន និងធនាគារអភិវឌ្ឍន៍អាស៊ី បានប្រែប្រួលគួរកត់សម្គាល់ ដោយបានកើនឡើងទ្វេដង ប្រមាណ៥០២ លានដុល្លារ និង ៤៥៣ លានដុល្លារ ។ គំនូរទី ៣.៤ បង្ហាញអំពីការកើនឡើងនៃឥណទានសម្បទានរបស់បារាំង និងកូរ៉េ ក្នុងពេលដែលពួកគេបានរក្សាហិរញ្ញប្បទានឥតសំណងក្នុងទំហំថេរ ។

**គំនូរទី ៣.៣ ដៃគូផ្ដល់ហិរញ្ញប្បទានសំខាន់ៗ**




**គំនូរទី ៣.៤ ទំហំហិរញ្ញប្បទានរបស់ដៃគូសំខាន់ៗ**




### *ការវិវត្តនៃការបើកផ្ដល់ហិរញ្ញប្បទានតាមវិស័យ*

តារាងទី ៣.៣ បង្ហាញអំពីការវិវត្តនៃការបើកផ្ដល់ហិរញ្ញប្បទានតាមវិស័យ ឆ្នាំ២០១៣-២០២២ ដែលបានតម្រឹមជាមួយនឹងអាទិភាពរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ ។ វិស័យហេដ្ឋារចនាសម្ព័ន្ធ ទទួលបានធនធានគាំទ្រច្រើនជាងគេ ក្នុងទំហំប្រចាំឆ្នាំប្រមាណ ៧៦០ លានដុល្លារ ក្នុងពេលដែលវិស័យសេដ្ឋកិច្ច និងវិស័យសង្គម ទទួលបានការគាំទ្រជាមធ្យមប្រចាំឆ្នាំប្រមាណ ៣៧៥ លានដុល្លារ សម្រាប់ឆ្នាំ២០១៩-២០២១ ។ ហិរញ្ញប្បទានមួយភាគធំត្រូវបានផ្ដល់ឱ្យវិស័យសុខាភិបាល, អប់រំ, កសិកម្ម, ការដឹកជញ្ជូន និងថាមពល ស្មើនឹង ៥៧% នៃហិរញ្ញប្បទានសរុប ក្នុងឆ្នាំ២០២០ និង ៧០% ក្នុងឆ្នាំ២០២១ ។ ការវិនិយោគទាំងនេះបានគូសបញ្ជាក់អំពីអាទិភាពរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការជំរុញកំណើនសេដ្ឋកិច្ច ដែលរំលេចអំពីសង្គតិភាពជាមួយនឹងវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥ក៏ដូចជាកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការឆ្លើយតបនឹងវិបត្តិជំងឺកូវីដ-១៩ និងការស្ដារសង្គម-សេដ្ឋកិច្ចឡើងវិញ ។ ជាទូទៅ អន្តរវិស័យជាវិស័យ ទទួលបានការគាំទ្រតិចជាងគេ

## តារាងទី ៣.៣ ការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ (លានដុល្លារ)

| វិស័យ | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 ប៉ាន់ស្មាន | 2022 ព្យាករណ៍ |
|---|---|---|---|---|---|---|---|---|---|---|
| **វិស័យសង្គម** | | | | | | | | | | |
| សុខាភិបាល | 133.2 | 128.5 | 126.0 | 141.4 | 107.0 | 127.7 | 168.3 | 216.4 | 226.6 | 163.0 |
| អប់រំ | 90.5 | 112.1 | 117.1 | 109.6 | 127.6 | 138.1 | 141.3 | 165.6 | 135.6 | 148.7 |
| គាំពារសង្គម | - | - | - | - | - | 0.3 | 1.8 | 55.0 | 9.2 | 7.8 |
| **សរុប** | **223.7** | **240.5** | **243.2** | **251** | **234.7** | **266.2** | **311.4** | **437** | **371.4** | **319.6** |
| **វិស័យសេដ្ឋកិច្ច** | | | | | | | | | | |
| កសិកម្ម | 177.8 | 211.8 | 165.8 | 135.9 | 173.1 | 184.4 | 289.8 | 221.0 | 249.5 | 286.7 |
| កម្មន្តសាល និងពាណិជ្ជកម្ម | 11.1 | 3.8 | 4.5 | 5.9 | 22.9 | 7.2 | 10.6 | 5.4 | 11.0 | 7.3 |
| អភិវឌ្ឍន៍ជនបទ | 56.4 | 65.1 | 71.5 | 45.6 | 84.4 | 67.0 | 53.3 | 48.2 | 72.0 | 112.3 |
| សេវាធុរកិច្ច និងហិរញ្ញវត្ថុ | 43.8 | 14.2 | 27.0 | 13.3 | 11.5 | 8.7 | 3.8 | 1.6 | 3.0 | 1.7 |
| នគរូបនីយកម្ម និងការគ្រប់គ្រង | 0.2 | 6.6 | 7.4 | 6.0 | 4.2 | 11.1 | 55.3 | 49.8 | 48.1 | 48.0 |
| **សរុប** | **289.3** | **300.8** | **276.2** | **206.6** | **296.1** | **278.3** | **412.9** | **326** | **383.6** | **456** |
| **វិស័យហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | | | |
| ព័ត៌មាន និងទូរគមនាគមន៍ | 2.9 | 10.5 | 5.0 | 12.5 | 0.3 | 1.8 | 1.3 | 2.9 | 9.0 | 8.0 |
| ថាមពល និងអគ្គិសនី | 60.1 | 66.5 | 54.2 | 158.3 | 157.4 | 97.6 | 199.7 | 236.3 | 190.7 | 113.7 |
| ការដឹកជញ្ជូន | 378.6 | 309.1 | 286.5 | 190.7 | 267.9 | 301.0 | 419.0 | 393.4 | 444.4 | 623.5 |
| ទឹកស្អាត និងអនាម័យ | 59.2 | 63.5 | 37.6 | 39.0 | 86.0 | 78.3 | 147.6 | 59.8 | 178.3 | 80.2 |
| **សរុប** | **500.8** | **449.7** | **383.4** | **400.5** | **511.7** | **478.6** | **767.7** | **692.4** | **822.5** | **825.5** |
| **អន្តរវិស័យ** | | | | | | | | | | |
| ការអភិវឌ្ឍន៍សហគមន៍ | 26.6 | 33.2 | 41.0 | 11.9 | 14.8 | 14.8 | 17.8 | 17.4 | 20.8 | 14.3 |
| វប្បធម៌ និងសិល្បៈ | 4.2 | 5.0 | 5.8 | 3.5 | 33.8 | 42.2 | 43.4 | 36.3 | 22.3 | 4.1 |
| បរិស្ថាន និងចីរភាព | 18.0 | 19.9 | 26.8 | 21.1 | 20.0 | 28.6 | 31.6 | 30.8 | 24.7 | 24.9 |
| ការប្រែប្រួលអាកាសធាតុ | 8.2 | 5.9 | 6.5 | 6.1 | 7.3 | 11.5 | 12.3 | 8.1 | 8.2 | 34.7 |
| យេនឌ័រ | 9.0 | 8.0 | 5.9 | 6.4 | 4.2 | 5.6 | 5.1 | 5.0 | 5.3 | 4.1 |
| មេរោគហ៊ីវ/ជំងឺអេដស៍ | 28.5 | 38.8 | 24.9 | 18.8 | 19.5 | 6.6 | 5.0 | 3.7 | 0.2 | 0.6 |
| អភិបាលកិច្ច និងរដ្ឋបាល | 114.8 | 81.8 | 75.9 | 100.2 | 72.6 | 81.4 | 72.5 | 92.0 | 84.5 | 53.0 |
| ទេសចរណ៍ | 0.7 | 0.5 | 1.8 | 1.3 | 14.8 | 2.6 | 6.5 | 4.9 | 6.5 | 2.1 |
| ការទ្រទ្រង់ថវិការ និងជញ្ជីងទូទាត់ | - | - | - | - | - | - | - | 495.4 | 10.7 | 10.8 |
| ជំនួយសង្គ្រោះបន្ទាន់ និងស្បៀងអាហារ | 19.1 | 24.9 | 14.6 | 1.0 | 0.1 | 0.1 | 3.5 | 1.0 | 9.2 | 1.8 |
| **សរុប** | **229.2** | **218.1** | **203.3** | **170.3** | **187.1** | **193.4** | **197.7** | **694.6** | **192.4** | **150.5** |
| **ផ្សេងៗ** | **11.3** | **5.3** | **7.0** | **7.7** | **32.8** | **5.6** | **15.0** | **5.4** | **6.4** | **25.5** |
| **សរុបរួម** | **1,254.3** | **1,214.5** | **1,113.0** | **1,036.1** | **1,262.5** | **1,222.2** | **1,704.8** | **2,155.4** | **1,776.3** | **1,777.1** |

ប៉ុន្តែក្នុងឆ្នាំ២០២០ បែរជាទទួលបានការគាំទ្រច្រើនជាងគេ ប្រមាណ ១/៣ នៃហិរញ្ញប្បទានសរុប ។ ការកើនឡើងនេះគឺដោយសារការបើកផ្តល់ហិរញ្ញប្បទានតែមួយលើកនៃគម្រោងទ្រទ្រង់ថវិការបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងជប៉ុន ដើម្បីគាំទ្ររាជរដ្ឋាភិបាលក្នុងការឆ្លើយតបនឹងវិបត្តិជំងឺកូវីដ-១៩ និងការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ ។

**គំនូរទី ៣.៥ អនុបាតនៃការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ**




គំនូរទី ៣.៥ បង្ហាញអំពីអនុបាតនៃការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ ឆ្នាំ២០១៦-២០២២ ។ វិស័យសង្គមកិច្ចទទួលបានធនធានក្នុង ទំហំ ១/៥ នៃហិរញ្ញប្បទានសរុបប្រចាំឆ្នាំ ។ ហិរញ្ញប្បទានសម្រាប់វិស័យសេដ្ឋកិច្ច រក្សាទំហំថេរ លើកលែង ឆ្នាំ២០២០ ដែលពិភពលោករួមទាំងកម្ពុជា ទទួលផលប៉ះពាល់ទាំងខាងសេដ្ឋកិច្ចនិងសង្គមដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ។ វិស័យហេដ្ឋារចនាសម្ព័ន្ធទទួលបានធនធានប្រចាំឆ្នាំច្រើនជាងគេ ក្នុងរង្វង់ ២/៥ ប៉ុន្តែ ក្នុងឆ្នាំ២០២០ ការគាំទ្រវិស័យនេះបានថយចុះបន្តិច ហើយជំនួសដោយការកើនឡើងក្នុងអន្តរវិស័យ ។

## *ទម្រង់ និងទំហំនៃការបើកផ្តល់ឥណទានសម្បទាន*

ឥណទានសម្បទានសម្រាប់គាំទ្រវិស័យហេដ្ឋារចនាសម្ព័ន្ធ និងអន្តរវិស័យ គឺជាប្រភពធនធានសំខាន់ដែលនាំឱ្យទំហំហិរញ្ញប្បទានសរុបបានកើនឡើង ក្នុងរយៈពេលកន្លងមកនេះ ។ ផ្នែកនេះបង្ហាញអំពីការបើកផ្តល់ហិរញ្ញប្បទានតាមទម្រង់ និងតាមវិស័យអាទិភាព ។ គំនូរទី ៣.៦ បង្ហាញថា ហិរញ្ញប្បទានសម្រាប់វិនិយោគបានកើនឡើងក្នុងរយៈពេលវែង ខណៈដែលកិច្ចសហប្រតិបត្តិការបច្ចេកទេសនៅតែរក្សាទំហំថេរ និងក្នុងកម្រិតទាបប្រមាណ ៤០០ លានដុល្លារ ជាមធ្យមក្នុងមួយឆ្នាំ ។ ប្រការនេះបានឆ្លុះបញ្ចាំងអំពីកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលនាពេលបច្ចុប្បន្ន ពិសេសក្នុងបរិបទនៃជំងឺកូវីដ-១៩ ដែលបានផ្តោតសំខាន់លើការវិនិយោគក្នុងវិស័យសង្គម-សេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធ ។ ជាមួយគ្នានេះដែរ ដៃគូអភិវឌ្ឍន៍សំខាន់ៗក៏បានបើកផ្តល់ឥណទានសម្បទានសម្រាប់គម្រោងវិនិយោគដើម្បីពង្រីកប្រព័ន្ធដឹកជញ្ជូន, ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទឹកស្អាត ។ ការគាំទ្រទាំងនេះបានឆ្លុះបញ្ចាំងអំពីទិសដៅអាទិភាពរបស់រាជរដ្ឋាភិបាល និងវិសាលភាពនៃហិរញ្ញប្បទានដែលបានផ្តោតលើការវិនិយោគហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអភិវឌ្ឍសមត្ថភាព ។

គំនូរទី ៣.៧ បង្ហាញថា ការប្រែប្រួលនៃទំហំហិរញ្ញប្បទានដែលបានបើកផ្តល់ និងកំណើនឥណទានសម្បទាន សម្រាប់វិស័យហេដ្ឋារចនាសម្ព័ន្ធ និងវិស័យសេដ្ឋកិច្ច បានដើរតួនាទីសំខាន់ចាប់ពីឆ្នាំ ២០១៩ មក ។ ក្នុងឆ្នាំ២០២០ ឥណទានសម្បទានសម្រាប់វិស័យហេដ្ឋារចនាសម្ព័ន្ធមានប្រមាណ ៧១០ លានដុល្លារ ខណៈឥណទានសម្បទានសម្រាប់អន្តរវិស័យ មានទំហំ ៥១០ លានដុល្លារ ។ ឥណទានសម្បទានអាចបន្តកើនឡើងជាបន្តបន្ទាប់ក្នុងកម្រិតផ្សេងៗគ្នាស្ទើរគ្រប់វិស័យ (គិតទាំងទំហំ និងសមាមាត្រ) ពិសេសវិស័យសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធ ។ កំណើននៃឥណទានសម្បទាន ត្រូវបានប្រើប្រាស់សម្រាប់គាំទ្រវិស័យ ឬគម្រោងអាទិភាព និងកំពុងត្រូវបានជំនួសដោយប្រភពធនធានក្នុងស្រុក ដែលរាជរដ្ឋាភិបាលកំពុងខិតខំកៀរគរ ទន្ទឹមនឹងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ឆ្នាំ២០១៩-២០២៣ ។

**គំនូរទី ៣.៦ ទម្រង់នៃការបើកផ្តល់ហិរញ្ញប្បទាន**




**គំនូរទី ៣.៧ ការបើកផ្តល់តាមវិស័យ និងតាមទម្រង់**




***ការចូលរួមរបស់ដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសចម្រុះ***

ក្រុមការងារបច្ចេកទេសចម្រុះ គឺជាយន្តការពិគ្រោះយោបល់កម្រិតបច្ចេកទេស ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ប្រកបដោយបរិយាប័ន្ន និងគណនេយ្យភាពទ្វេទិស ដោយផ្តោតលើលទ្ធផល ។ តារាងទី ៣.៤ បង្ហាញថា ក្នុងចន្លោះឆ្នាំ២០១៩-២០២៣ ក្រុមការងារបច្ចេកទេសចម្រុះបានសម្របសម្រួលគម្រោង ៤០៥ គម្រោង គិតជាមធ្យមប្រមាណ ១.០០០ លានដុល្លារ ក្នុងមួយឆ្នាំ ។

ក្រុមការងារបច្ចេកទេសចម្រុះស្តីពីហេដ្ឋារចនាសម្ព័ន្ធ និងសមាហរណកម្មតំបន់ បានសម្របសម្រួលគម្រោង និងហិរញ្ញប្បទានច្រើនជាងគេ ដោយមានគម្រោងកំពុងដំណើរការសរុប ៧០ គម្រោង ជាមួយនឹងហិរញ្ញប្បទាន ៥៦៣ លានដុល្លារ ស្មើនឹង ៥០% នៃហិរញ្ញប្បទានសរុប ក្នុងមួយឆ្នាំ ។ លើសពីនេះ ក្រុមការងារបច្ចេកទេសចម្រុះ ស្តីពីវិស័យកសិកម្ម និងទឹក, អប់រំ និងវិស័យសុខាភិបាល បានសម្របសម្រួលគម្រោងជាច្រើន(៧២ គម្រោង ក្នុងវិស័យកសិកម្ម, ៤៦ គម្រោង ក្នុងវិស័យអប់រំ និង៤៥ គម្រោងក្នុងវិស័យសុខាភិបាល) ។

**តារាងទី៣.៤ ការបើកផ្តល់ និងសកម្មភាពរបស់ដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសចម្រុះ(លានដុល្លារ)**

| ក្រុមការងារបច្ចេកទេសចម្រុះ | 2019 | 2020 | 2021 ប៉ាន់ស្មាន | 2022 ព្យាករណ៍ | 2023 ព្យាករណ៍ | ចំនួនដៃគូ | ចំនួនគម្រោង | ការបើកផ្តល់ជាមធ្យមឆ្នាំ ២០១៩-២០២៣ |
|---|---|---|---|---|---|---|---|---|
| **វិស័យសង្គម** | | | | | | | | |
| សុខាភិបាល | 63.3 | 80.7 | 119.0 | 74.8 | 56.0 | 16 | 45 | 7.9 |
| ហ៊ីវ/អេដស៍ | 3.0 | 0.6 | 29.3 | 35.0 | 18.1 | 5 | 6 | 17.2 |
| អប់រំ | 72.8 | 75.3 | 66.9 | 82.0 | 47.6 | 16 | 46 | 68.9 |
| សន្តិសុខស្បៀង និងអាហារូបត្ថម្ភ | 11.5 | 17.0 | 19.1 | 12.9 | 6.6 | 6 | 11 | 13.4 |
| ទឹកស្អាតជនបទ និងអនាម័យ | 38.6 | 24.4 | 47.8 | 63.1 | 19.8 | 7 | 14 | 38.7 |
| បណ្តុះបណ្តាល និងវិជ្ជាជីវៈ | 1.0 | 3.4 | 4.2 | 4.1 | 4.0 | 5 | 11 | 3.3 |
| **សរុប** | **190.0** | **201.3** | **286.4** | **272.0** | **152.1** | | **133** | **220.4** |
| **វិស័យសេដ្ឋកិច្ច** | | | | | | | | |
| កសិកម្ម និងទឹក | 203.2 | 164.2 | 155.5 | 194.4 | 74.0 | 17 | 72 | 158.2 |
| នេសាទ | 17.3 | 17.1 | 32.2 | 46.4 | 44.6 | 8 | 21 | 31.5 |
| ព្រៃឈើ | 16.7 | 11.4 | 11.0 | 14.6 | 13.7 | 8 | 19 | 13.6 |
| ការគ្រប់គ្រងដីធ្លី | 0.1 | 0.2 | 0.4 | 0.1 | | 1 | 1 | 0.2 |

| ក្រុមការងារបច្ចេកទេសចម្រុះ | 2019 | 2020 | 2021 ប៉ាន់ស្មាន | 2022 ព្យាករណ៍ | 2023 ព្យាករណ៍ | ចំនួនដៃគូ | ចំនួនគម្រោង | ការបើកផ្ដល់ជាមធ្យមឆ្នាំ ២០១៩-២០២៣ |
|---|---|---|---|---|---|---|---|---|
| ការកំចាត់មីន | 14.7 | 25.5 | 20.4 | 14.7 | 10.0 | 9 | 10 | 17.1 |
| ការអភិវឌ្ឍវិស័យឯកជន | 6.5 | 9.9 | 11.9 | 23.5 | 13.5 | 6 | 7 | 13.0 |
| **សរុប** | **258.5** | **228.3** | **231.4** | **293.7** | **155.8** | | **130** | **233.6** |
| **វិស័យហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | |
| ហេដ្ឋារចនាសម្ព័ន្ធ និងសមាហរណកម្មតំបន់ | 505.6 | 545.2 | 698.0 | 741.4 | 327.0 | 8 | 70 | 563.4 |
| **សរុប** | **505.6** | **545.2** | **698.0** | **741.4** | **327.0** | | **70** | **563.4** |
| **អន្តរវិស័យ និងរដ្ឋបាល** | | | | | | | | |
| ការកែទម្រង់រដ្ឋបាលសាធារណៈ | 3.4 | 3.8 | 5.7 | 2.6 | 1.4 | 2 | 2 | 3.4 |
| ការគ្រប់គ្រងរដ្ឋបាលសាធារណៈ | 11.2 | 20.0 | 25.3 | 19.7 | 5.3 | 7 | 13 | 16.3 |
| វិមជ្ឈការ និងវិសហមជ្ឈការ | 19.5 | 17.3 | 18.7 | 7.4 | 5.0 | 9 | 15 | 13.6 |
| យេនឌ័រ | 7.9 | 14.8 | 15.0 | 14.0 | 11.5 | 10 | 14 | 12.7 |
| ការកែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ | 2.6 | 2.1 | 1.4 | 1.4 | | 2 | 2 | 1.9 |
| ភាពជាដៃគូ និងសុខុដុមនីយកម្ម | 3.6 | 3.7 | 5.9 | 3.7 | 3.4 | 2 | 2 | 7.1 |
| ផែនការ និងការកាត់បន្ថយភាពក្រីក្រ | 5.4 | 7.0 | 15.6 | 4.5 | 3.2 | 6 | 6 | 7.1 |
| ការប្រែប្រួលអាកាសធាតុ | 2.8 | 9.0 | 8.2 | 9.3 | 11.5 | 8 | 18 | 8.2 |
| **សរុប** | **56.4** | **77.7** | **95.8** | **62.6** | **41.3** | | **72** | **66.8** |
| គម្រោង/ហិរញ្ញប្បទានមិនស្ថិតនៅក្រោមការសម្របសម្រួលរបស់ក្រុមការងារបច្ចេកទេសចម្រុះ | 163.9 | 210.8 | 268.4 | 196.5 | 85.0 | 19 | 276 | 184.9 |
| **សរុបរួម** | **1,174.6** | **1,263.5** | **1,580.7** | **1,566.0** | **761.1** | **-** | **681** | **1,269.2** |

តារាងទី ៣.៥ បង្ហាញថា ធនាគារអភិវឌ្ឍន៍អាស៊ីគឺជាដៃគូអភិវឌ្ឍន៍ដែលបានចូលរួមច្រើនជាងគេ ក្នុងក្រុមការងារបច្ចេកទេសចម្រុះ ដោយមានគម្រោងចំនួន ៦២ បន្ទាប់មកគឺជប៉ុន ចំនួន ៣១ គម្រោង និងបារាំងចំនួន ២៣ គម្រោង ។ ក្នុងឆ្នាំ២០២០ ធនាគារអភិវឌ្ឍន៍អាស៊ី បានបើកផ្ដល់ហិរញ្ញប្បទានចំនួន ១៦៥ លានដុល្លារ ដល់បណ្ដាវិស័យដែលគ្រប់គ្រងដោយក្រុមការងារបច្ចេកទេសចម្រុះ ពោលគឺបានថយចុះ ២៩% ធៀបនឹងឆ្នាំ២០១៨ ។

### តារាងទី ៣.៥ ដៃគូអភិវឌ្ឍន៍សំខាន់ៗក្នុងក្រុមការងារបច្ចេកទេសចម្រុះ (លានដុល្លារ)

| ដៃគូអភិវឌ្ឍន៍ | ចំនួនគម្រោង | ការបើកផ្ដល់តាមឆ្នាំនីមួយៗ | | | |
|---|---|---|---|---|---|
| | | 2019 | 2020 | 2021 ប៉ាន់ស្មាន | 2022 ព្យាករណ៍ |
| សាធារណរដ្ឋប្រជាមានិតចិន | 11 | 239.4 | 361 | 261.4 | 250.8 |
| ជប៉ុន | 31 | 99.8 | 181.2 | 257.9 | 413.5 |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 62 | 233.4 | 164.5 | 174.4 | 160.9 |
| ធនាគារពិភពលោក | 22 | 49.1 | 76 | 75 | 124.3 |
| បារាំង | 23 | 148.7 | 4.8 | 109.7 | 57.6 |
| សាធារណរដ្ឋកូរ៉េ | 20 | 31.1 | 23.3 | 77 | 79.5 |
| សហភាពអឺរ៉ុប | 22 | 20 | 29.9 | 47.4 | 51.8 |
| អូស្ត្រាលី | 12 | 21.8 | 18.5 | 50 | 22 |
| មូលនិធិសកល Global Fund | 3 | - | - | 42.8 | 41 |
| អង្គការ UNICEF | 5 | 15.3 | 24.8 | 29.4 | 20 |
| ផ្សេងៗ | 137 | 350 | 105 | 108 | 81.6 |
| **សរុបរួម** | **348** | **969.2** | **989** | **1,233** | **1,303** |

រីឯជប៉ុនបានបើកផ្តល់ហិរញ្ញប្បទានចំនួន ១៨១ លានដុល្លារ ក្នុងឆ្នាំ២០២០ ហើយទំហំនេះអាចកើនដល់ ២៥៨ លានដុល្លារ ក្នុងឆ្នាំ២០២១ ។

### *ការបើកផ្តល់ហិរញ្ញប្បទានតាមរាជធានី-ខេត្ត*

តារាងទី ៣.៦ ការបើកផ្តល់តាមរាជធានី-ខេត្ត (លានដុល្លារ)

| រាជធានី-ខេត្ត | 2019 | 2020 | 2021 ប៉ាន់ស្មាន | ភាគរយធៀបនឹងការបើកសរុប |
|---|---|---|---|---|
| ទូទាំងប្រទេស | 434.4 | 997.1 | 455.3 | 29% |
| ភ្នំពេញ | 350.8 | 311.6 | 380.7 | 16% |
| បាត់ដំបង | 132.2 | 122.1 | 154.7 | 6% |
| សៀមរាប | 104.2 | 96.2 | 125.1 | 5% |
| កំពុងចាម | 78.6 | 59.8 | 81.2 | 3% |
| បន្ទាយមានជ័យ | 63.7 | 60.3 | 76.2 | 3% |
| ផ្សេងៗ | 817.3 | 760.6 | 752.2 | 36% |
| **សរុប** | **1,981** | **2,408** | **2,025** | **100%** |

ផ្នែកនេះបង្ហាញ អំពីការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍តាមរាជធានី-ខេត្តសម្រាប់រួមចំណែកអភិវឌ្ឍរាជធានី-ខេត្ត ដើម្បីផ្តល់អត្ថផលប្រយោជន៍ដល់ប្រទេសទាំងមូល ។ ការវិភាគនឹងផ្តល់នូវមូលដ្ឋាន សម្រាប់ពង្រឹងភាពជាដៃគូនៅថ្នាក់ក្រោមជាតិ ស្របតាមសេចក្តីណែនាំស្តីពីកិច្ចពិគ្រោះយោបល់ភាពជាដៃគូនៅថ្នាក់ក្រោមជាតិ នៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការនៅតាមបណ្តាខេត្តដែលមានការគាំទ្រតិចតួច ។ ក្នុងចន្លោះឆ្នាំ ២០១៩-២០២១ ហិរញ្ញប្បទានប្រចាំឆ្នាំ ប្រមាណ ២/៣ នៃហិរញ្ញប្បទានសរុប ត្រូវបានផ្តល់សម្រាប់អនុវត្តគម្រោងទូទាំងប្រទេស និងខេត្តសំខាន់ចំនួន ៥ ។ រីឯហិរញ្ញប្បទានប្រមាណ ១/៣ ទៀត ត្រូវបានផ្តល់ដល់ខេត្ត ២០ ផ្សេងទៀត ។ រាជធានីភ្នំពេញទទួលបានហិរញ្ញប្បទានច្រើនជាងគេ បន្ទាប់មកគឺខេត្តបាត់ដំបង, សៀមរាប, កំពង់ចាម និងបន្ទាយមានជ័យ ។

តារាងទី ៣.៧ បង្ហាញថា ក្នុងចំណោមបណ្តាដៃគូអភិវឌ្ឍន៍, ជប៉ុនបានបើកផ្តល់ហិរញ្ញទានច្រើនជាងគេដល់រាជធានី-ខេត្ត ចំនួន ៦ ។ ធនាគារអភិវឌ្ឍន៍អាស៊ីបានបើកផ្តល់ហិរញ្ញប្បទានក្នុងលំដាប់ទី២ និងបន្ទាប់មកគឺ សាធារណរដ្ឋប្រជាមានិតចិន, សហគមន៍អឺរ៉ុប, បារាំង និងសហរដ្ឋអាមេរិក ។ រីឯអង្គការមិនមែនរដ្ឋាភិបាលក៏បាន រួមចំណែកសំខាន់ក្នុងការគាំទ្រកិច្ចអភិវឌ្ឍន៍តាមរាជធានី-ខេត្ត ដែលបង្ហាញលម្អិតបន្ថែមក្នុងផ្នែកបន្ទាប់ ។

**តារាងទី ៣.៧ ការបើកផ្តល់របស់ដៃគូអភិវឌ្ឍន៍សំខាន់ៗតាមរាជធានី-ខេត្ត ឆ្នាំ២០២០ (លានដុល្លារ)**

| ដៃគូអភិវឌ្ឍន៍ | បន្ទាយមានជ័យ | បាត់ដំបង | កំពង់ចាម | ភ្នំពេញ | សៀមរាប | ទូទាំងប្រទេស | ខេត្តផ្សេងៗទាំង ២០ | សរុប |
|---|---|---|---|---|---|---|---|---|
| ជប៉ុន | 29.2 | 56.9 | 0.7 | 57.5 | 15.7 | 278.1 | 63.5 | 501.7 |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 9.9 | 18.3 | 7.6 | 5.3 | 15.3 | 301.4 | 94.6 | 452.6 |
| សាធារណរដ្ឋប្រជាមានិតចិន | - | - | 32.9 | 149.8 | 1.6 | - | 310.4 | 494.8 |
| សហភាពអឺរ៉ុប | 0.1 | 0.6 | 0.3 | 16.2 | 0.4 | 69.3 | 2.4 | 89.4 |
| បារាំង | - | 1.3 | 7.0 | 2.1 | 1.9 | 56.7 | 16.6 | 85.7 |
| សហរដ្ឋអាមេរិក | 1.3 | 5.6 | 0.8 | 5.3 | 5.0 | 47.4 | 27.1 | 92.5 |
| អង្គការមិនមែនរដ្ឋាភិបាល | 9.8 | 16.9 | 5.0 | 63.9 | 41.3 | 18.2 | 97.4 | 252.4 |
| ផ្សេងៗ | 10.1 | 22.6 | 5.4 | 11.4 | 15 | 225.8 | 148.1 | 438.3 |
| សរុប | **60.3** | **122.1** | **59.8** | **311.6** | **96.2** | **997.0** | **760.1** | **2,407.2** |

### *ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ជាតិ*

រាជរដ្ឋាភិបាលទទួលស្គាល់អំពីការរួមចំណែករបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងកិច្ចអភិវឌ្ឍន៍នៅកម្ពុជា ពិសេសការផ្តល់សេវាសង្គម និងការកៀរគរធនធានសម្រាប់អនុវត្តគម្រោងតាមវិស័យអាទិភាព និងតាមតំបន់គោលដៅនានា ។ ផ្អែកតាមទិន្នន័យដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល, គ.ជ.ន/ក.អក បានកត់ត្រា និងវិភាគអំពីនិន្នាការនៃការប្រើប្រាស់ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីឆ្លុះបញ្ចាំងអំពីការប្តេជ្ញាក្នុងការតម្រឹមជាមួយអាទិភាពរបស់រាជរដ្ឋាភិបាល និងរបៀបវារៈស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ។

ក្នុងឆ្នាំ២០២០ គ.ជ.ន/ក.អ.ក បានទទួលរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាពពីអង្គការមិនមែនរដ្ឋាភិបាល ចំនួន ៤១៨ ដែលអនុវត្តគម្រោងសរុប ចំនួន ៦៤៦ ។ ផ្អែកលើប្រព័ន្ធទិន្នន័យស្តីពីអង្គការមិនមែនរដ្ឋាភិបាល, ផ្នែកនេះបង្ហាញអំពីការរួមចំណែករបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងការអភិវឌ្ឍជាតិពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២១ និងបង្ហាញអំពីអង្គការមិនមែនរដ្ឋាភិបាលដែលបានផ្តល់ការគាំទ្រច្រើនជាងគេ ។

តារាងទី ៣.៨ បង្ហាញអំពីធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ ក្នុងចន្លោះឆ្នាំ ២០១៩-២០២១ ។ ក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយនេះ ធនធានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាលមាន ៣៦៥ លានដុល្លារ ជាមធ្យមក្នុងមួយឆ្នាំ ក្នុងនោះធនធានដែលកៀរគរពីដៃគូអភិវឌ្ឍន៍មានប្រមាណ ១០០ លានដុល្លារ ។ ក្នុងឆ្នាំ២០២០ អង្គការមិនមែនរដ្ឋាភិបាលបានប្រើប្រាស់ធនធានច្រើនជាងគេ ក្នុងវិស័យសុខាភិបាល ប្រមាណ ១១១ លានដុល្លារ, បន្ទាប់មកគឺ វិស័យអប់រំ (៧២,៩ លានដុល្លារ), ការអភិវឌ្ឍសហគមន៍ (៥៨.៨ លានដុល្លារ) និងការអភិវឌ្ឍជនបទ (៤១,៧ លានដុល្លារ) ។ ធនធានដែលបានប្រើប្រាស់ក្នុងវិស័យចម្បងទាំង ៤ នេះ មានប្រមាណ ៨០% នៃទំហំធនធានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាល ។ ការប្រើប្រាស់ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលបានថយចុះបន្តិច ក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១ បើធៀបនឹងឆ្នាំ ២០១៩ ។ ដោយឡែក ធនធានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាល បានរក្សាទំហំថេរ ប្រមាណ ២៦០ លានដុល្លារក្នុងមួយឆ្នាំ ។

**តារាងទី ៣.៨ ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ (លានដុល្លារ)**

| វិស័យ | 2019 | | | 2020 | | | 2021 ប៉ាន់ស្មាន | | |
|---|---|---|---|---|---|---|---|---|---|
| | ធនធានផ្ទាល់ | ធនធានដៃគូ | ធនធានសរុប | ធនធានផ្ទាល់ | ធនធានដៃគូ | ធនធានសរុប | ធនធានផ្ទាល់ | ធនធានដៃគូ | ធនធានសរុប |
| សុខាភិបាល | 86.2 | 27.7 | 113.9 | 80.1 | 30.9 | 111.0 | 87.4 | 30.9 | 118.3 |
| អប់រំ | 74.8 | 13.1 | 87.8 | 66.3 | 6.6 | 72.9 | 56.9 | 14.5 | 71.4 |
| ការអភិវឌ្ឍសហគមន៍ | 56.4 | 5.3 | 61.7 | 53.6 | 5.2 | 58.8 | 53.9 | 6.0 | 59.9 |
| ការអភិវឌ្ឍជនបទ | 22.9 | 19.7 | 42.6 | 23.9 | 17.8 | 41.7 | 23.4 | 17.2 | 40.6 |
| អភិបាលកិច្ច | 4.7 | 12.8 | 17.5 | 4.1 | 15.3 | 19.4 | 4.3 | 16.7 | 21.1 |
| ហ៊ីវ/អេដស៍ | 7.8 | 6.6 | 14.4 | 6.5 | 8.2 | 14.8 | 5.8 | 3.7 | 9.6 |
| កសិកម្ម | 11.7 | 8.8 | 20.5 | 7.3 | 9.2 | 16.5 | 7.3 | 9.2 | 16.6 |
| បរិស្ថាន | 8.6 | 5.7 | 14.3 | 8.5 | 4.9 | 13.3 | 8.6 | 5.9 | 14.5 |
| ផ្សេងៗ | 3.3 | 5.8 | 9.1 | 2.0 | 4.3 | 6.4 | 1.6 | 4.5 | 6.1 |
| **សរុប** | **276.4** | **105.5** | **381.9** | **252.4** | **102.4** | **354.8** | **249.1** | **108.8** | **357.9** |

**គំនូរទី ៣.៨ ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាល តាមវិស័យ (លានដុល្លារ)**




**គំនូរទី ៣.៩ ភាគរយជាមធ្យមនៃធនធានរបស់អង្គការមិនមែនរដ្ឋាភិបាល**




គំនូរទី ៣.៨ បង្ហាញអំពីការប្រៀបធៀបជាមធ្យមភាគនៃការប្រើប្រាស់ធនធានតាមវិស័យ រវាងធនធានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាល និងធនធានទទួលបានពីដៃគូអភិវឌ្ឍន៍ ក្នុងចន្លោះឆ្នាំ២០១៩-២០២១ ។ ធនធានផ្ទាល់ភាគច្រើនរបស់អង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រើប្រាស់ក្នុងវិស័យសុខាភិបាល ប្រមាណ ៨៥ លានដុល្លារ, វិស័យអប់រំ ប្រមាណ ៦៦ លានដុល្លារ, វិស័យអភិវឌ្ឍន៍សហគមន៍ ប្រមាណ ៥៥ លានដុល្លារ, ការអភិវឌ្ឍជនបទ ប្រមាណ ២៣ លានដុល្លារ និងវិស័យកសិកម្ម ប្រមាណ ៩ លានដុល្លារ ។ គំនូរទី ៣.៩ បង្ហាញថា ក្នុងចន្លោះឆ្នាំ២០១៩-២០២១ ធនធានដែលអង្គការមិនមែនរដ្ឋាភិបាលទទួលបានពីដៃគូអភិវឌ្ឍន៍ ប្រមាណ ៧៧% ត្រូវបានប្រើប្រាស់ក្នុងវិស័យអភិបាលកិច្ច និងធនធានបន្តិចបន្តួច (៩%) ក្នុងវិស័យអភិវឌ្ឍន៍សហគមន៍ ។ ប្រការនេះបានបង្ហាញអំពីភាពផ្ទុយគ្នាក្នុងការប្រើប្រាស់ធនធានផ្ទាល់ដែលអង្គការមិនមែនរដ្ឋាភិបាល កន្លងមក ។

តារាងទី ៣.៩ បង្ហាញថា ក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាល ចំនួន ៤១៨ មានអង្គការ ចំនួន ៣០ ដែលបានប្រើប្រាស់ធនធានសរុប ចំនួន ២០៣ លានដុល្លារ ស្មើនឹង ៥៧% នៃធនធានសរុប ក្នុងឆ្នាំ២០២០ ។ ក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយ មូលនិធិមន្ទីរពេទ្យគន្ធបុប្ផា និងអង្គការទស្សនពិភពលោកកម្ពុជា ផ្តល់ធនធានច្រើន ជាងគេ ប្រមាណ ៣១ លានដុល្លារ (៩% នៃធនធានផ្ទាល់) និង ២៤ លានដុល្លារ (៧% នៃធនធានផ្ទាល់) ។ ក្នុងឆ្នាំជាមួយគ្នានេះ អង្គការ Population Services International ដែលបានផ្តោតសកម្មភាពលើការលើកកម្ពស់វិស័យ សុខាភិបាលសម្រាប់ប្រជាជនកម្ពុជា និងការធានាគុណភាពនៃសេវាសុខាភិបាលក្នុងវិស័យសាធារណៈ និងឯកជន បានចំណាយធនធាន ១០,៧ លានដុល្លារ ស្មើនឹង ៣% នៃធនធានសរុប ។ សរុបមក ការវិភាគខាងលើ បានបង្ហាញអំពីលទ្ធភាពរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងការគ្រប់គ្រងធនធានផ្ទាល់ខ្លួន និងធនធានដែលកៀរគរបានពីដៃគូអភិវឌ្ឍន៍ ក៏ដូចជាកិច្ចប្រតិបត្តិការនៅថ្នាក់ក្រោមជាតិ ពិសេសការផ្តល់សេវាក្នុងវិស័យសង្គមកិច្ច ។

# តារាងទី ៣.៩ ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗ (លានដុល្លារ)

| អង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗ | 2019 | | | 2020 | | | 2021 ប៉ាន់ស្មាន | | |
|---|---|---|---|---|---|---|---|---|---|
| | ធនធានផ្ទាល់ | ធនធានដៃគូ | ធនធានសរុប | ធនធានផ្ទាល់ | ធនធានដៃគូ | ធនធានសរុប | ធនធានផ្ទាល់ | ធនធានដៃគូ | ធនធានសរុប |
| Foundation Children's Hospital Kantha Bopha | 27.7 | 4.3 | 32.0 | 26.5 | 4.5 | 31.0 | 30.4 | 4.6 | 35.0 |
| World Vision Cambodia | 22.9 | 3.0 | 25.8 | 21.5 | 3.3 | 24.8 | 18.8 | 1.0 | 19.7 |
| Population Services International | 8.1 | 3.1 | 11.2 | 7.2 | 3.5 | 10.7 | 7.0 | 2.4 | 9.5 |
| Cambodian Children's Fund | 7.9 | 0.0 | 7.9 | 6.7 | 0.0 | 10.6 | 1.0 | 0.0 | 1.0 |
| Pour un Sourire d'Enfant | 7.7 | 0.0 | 7.7 | 6.3 | 0.0 | 8.5 | 2.8 | 0.0 | 2.8 |
| Nokor Tep Foundation | 1.2 | 0.0 | 1.2 | 6.0 | 0.0 | 6.9 | 0.0 | 0.0 | 0.0 |
| Hope Worldwide | 11.6 | 0.0 | 11.6 | 5.9 | 0.0 | 6.7 | 7.1 | 0.0 | 7.1 |
| Angkor Hospital for Children | 5.8 | 0.0 | 5.8 | 5.3 | 0.0 | 6.3 | 5.4 | 0.0 | 5.4 |
| Japan Relief for Cambodia and World Assistance for Cambodia | 5.8 | 0.5 | 6.3 | 5.2 | 0.5 | 6.2 | 4.8 | 0.1 | 4.9 |
| Plan International | 4.2 | 7.7 | 11.9 | 5.0 | 3.5 | 6.0 | 7.4 | 7.6 | 15.0 |
| Sos Children's Villages of Cambodia | 4.1 | 0.0 | 4.1 | 4.1 | 0.0 | 5.9 | 2.6 | 0.0 | 2.6 |
| Child Fund Cambodia | 4.5 | 0.3 | 4.8 | 4.1 | 0.2 | 5.7 | 2.0 | 0.1 | 2.1 |
| The Sonja Kill Foundation Cambodia | 3.1 | 0.0 | 3.1 | 3.7 | 0.0 | 5.5 | 4.9 | 0.0 | 4.9 |
| Don Bosco Foundation of Cambodia | 4.2 | 0.0 | 4.2 | 3.6 | 0.0 | 5.3 | 2.5 | 0.0 | 2.5 |
| Toutes A l'Ecole | 3.0 | 0.0 | 3.0 | 3.5 | 0.0 | 5.2 | 3.4 | 0.0 | 3.4 |
| Room to Read | 3.5 | 0.0 | 3.5 | 3.3 | 0.0 | 5.2 | 3.2 | 0.0 | 3.2 |
| Clear Cambodia | 2.0 | 0.0 | 2.0 | 3.3 | 0.0 | 4.8 | 3.4 | 0.0 | 3.4 |
| Wildlife Alliance | 2.7 | 0.0 | 2.7 | 3.2 | 0.0 | 4.3 | 3.9 | 0.0 | 3.9 |
| Samaritan's Purse International Relief | 2.4 | 0.0 | 2.4 | 2.9 | 0.0 | 4.3 | 2.7 | 0.0 | 2.7 |
| Jay Pritzker Academy | 3.8 | 0.0 | 3.8 | 2.7 | 0.0 | 4.1 | 2.0 | 0.0 | 2.0 |
| International Development Enterprises Cambodia | 0.0 | 4.7 | 4.7 | 2.7 | 2.0 | 4.0 | 2.6 | 2.7 | 5.3 |
| Enfant du Mekong | 2.9 | 0.0 | 2.9 | 2.6 | 0.0 | 3.8 | 1.9 | 0.0 | 1.9 |
| Norwegian People's Aid | 2.2 | 3.2 | 5.4 | 2.5 | 2.8 | 3.7 | 2.7 | 2.6 | 5.3 |
| World Wide Fund for Nature - Cambodia | 2.3 | 3.8 | 6.1 | 2.4 | 3.8 | 3.7 | 1.5 | 3.6 | 5.1 |
| Medecins Sans Frontieres - France | 2.8 | 0.0 | 2.8 | 2.3 | 0.0 | 3.6 | 1.2 | 0.0 | 1.2 |
| Caritas Cambodia | 2.6 | 0.2 | 2.8 | 2.3 | 0.4 | 3.5 | 1.9 | 0.4 | 2.4 |
| Soutien a l'Initiative Prive pour l'Aide la Reconstruction des pays du Sud-est Asiatique | 1.1 | 0.2 | 1.3 | 2.2 | 0.5 | 3.3 | 1.2 | 0.4 | 1.6 |
| Food for the Hungry Cambodia | 2.0 | 0.0 | 2.0 | 2.2 | 0.0 | 3.3 | 2.2 | 0.0 | 2.2 |
| Child's Dream Cambodia Organisation | 1.2 | 0.0 | 1.2 | 2.0 | 0.0 | 3.2 | 1.6 | 0.0 | 1.6 |
| Save the Children International | 2.0 | 4.8 | 6.8 | 1.9 | 3.6 | 3.0 | 2.4 | 6.3 | 8.7 |
| **NGOs ធំៗទាំង ៣០** | **155.4** | **35.7** | **191.0** | **153.2** | **28.7** | **203.4** | **134.5** | **32.0** | **166.5** |
| **NGOs សរុប ៣៨៨** | **121.1** | **69.8** | **190.8** | **99.2** | **73.7** | **151.4** | **114.7** | **76.7** | **191.4** |
| សរុបរួម | **276.4** | **105.5** | **381.9** | **252.4** | **102.4** | **354.8** | **249.1** | **108.7** | **357.9** |

# ជំពូក ៤
# ការគាំទ្រហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការឆ្លើយតបជំងឺកូវីដ-១៩ និងក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម

ជំងឺកូវីដ-១៩ បានក្លាយជាជំងឺរាតត្បាតសកលនាពេលបច្ចុប្បន្ននេះ ។ បន្ទាប់ពីបានរីករាលដាលនាចុងខែធ្នូ ឆ្នាំ២០១៩, ជំងឺរាតត្បាតនេះបានបង្កើតបញ្ហាប្រឈមដល់សុខភាពសាធារណៈ និងសេដ្ឋកិច្ចសកល ។ កម្ពុជា ក៏ដូចជាប្រទេសដទៃទៀត បានទទួលរងនូវផលប៉ះពាល់ដែលបណ្តាលមកពីជំងឺកូវីដ-១៩ ។ ការរីករាលដាលនៃជំងឺនេះបានជះឥទ្ធិពលធ្ងន់ធ្ងរ មិនធ្លាប់មានកន្លងមក ដល់ប្រព័ន្ធសុខភាពសាធារណៈ និងប្រព័ន្ធគាំពារសង្គមកម្ពុជា ។ ផ្អែកលើផលប៉ះពាល់ធ្ងន់ធ្ងរដែលបណ្តាលមកពីជំងឺកូវីដ-១៩ ទន្ទឹមនឹងធនធានមានកំណត់របស់កម្ពុជាក្នុងឋានៈជាប្រទេសកំពុងអភិវឌ្ឍន៍, កម្ពុជាបានធ្វើឱ្យសហគមន៍អន្តរជាតិមានការភ្ញាក់ផ្អើលតាមរយៈការគ្រប់គ្រងជំងឺរាតត្បាតនេះប្រកបដោយប្រសិទ្ធភាព ។

### *ការគាំទ្រដល់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩*

ដើម្បីឆ្លើយតបនឹងការរីករាលដាលនៃជំងឺកូវីដ-១៩, រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយបន្ទាន់ជាច្រើន ដើម្បីទប់ស្កាត់ និងកាត់បន្ថយការខូចខាតធ្ងន់ធ្ងរក្នុងវិស័យដែលទទួលរងផលប៉ះពាល់ ។ ដោយកំណត់ថា វ៉ាក់សាំងជាឧបករណ៍ដ៏សំខាន់សម្រាប់គ្រប់គ្រងស្ថានភាពនៃការរីករាលដាល និងជៀសផុតពីភាពជាប់គាំងសង្គម និងសេដ្ឋកិច្ច រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធនាការចាក់វ៉ាក់សាំងទូទាំងប្រទេស និងយុទ្ធនាការផ្តល់ដូសជំរុញដើម្បីពង្រឹងភាពស៊ាំរបស់ប្រជាជន ។ យុទ្ធនាការចាក់វ៉ាក់សាំងបានចាប់ផ្តើមដំណើរការនាដើមខែកុម្ភៈ ឆ្នាំ២០២១ និងមានសន្ទុះលឿនគួរកត់សម្គាល់ ។ លើសពីនេះ ការគាំទ្រជាច្រើនរបស់សហគមន៍អន្តរជាតិ និងដៃគូសំខាន់ៗ បានផ្តល់លទ្ធភាពដល់រាជរដ្ឋាភិបាលក្នុងការផ្តួចផ្តើម និងរៀបចំគោលនយោបាយជាតិរយៈពេលវែង ដើម្បីក្តាប់យកនូវចលនការនៃកិច្ចអភិវឌ្ឍន៍ នៅពេលដែលជំងឺរាតត្បាតនេះចាប់ផ្តើមថមថយ ដើម្បីកម្ពុជាសម្រេចបាននូវការស្តារសេដ្ឋកិច្ចឡើងវិញប្រកបដោយភាពធន់ ។

ភាពជោគជ័យ នៃយុទ្ធនាការចាក់វ៉ាក់សាំងស្តែងឱ្យឃើញពីការគាំទ្រដ៏ច្រើនពីដៃគូអភិវឌ្ឍន៍សំខាន់ៗ តាមរយៈការផ្តល់វ៉ាក់សាំង ។ ការណ៍នេះបានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលទទួលបានវ៉ាក់សាំងជាច្រើន និងទាន់ពេលវេលា សម្រាប់សម្រេចគោលដៅរបស់ខ្លួន ។ ការផ្តល់វ៉ាក់សាំងត្រូវបានធ្វើឡើង តាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគី និងយន្តការ COVAX ។

តារាងទី ៤.១ បង្ហាញថា ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី, រាជរដ្ឋាភិបាលបានទទួលវ៉ាក់សាំងប្រមាណជាង ១២ លានដូស សមមូលនឹងទឹកប្រាក់ចំនួន ៨៦ លានដុល្លារអាមេរិក ក្នុងនោះសាធារណរដ្ឋប្រជាមានិតចិនជាដៃគូធំជាងគេ ដោយបានផ្តល់វ៉ាក់សាំង ៨,៣ លានដូស ស្មើនឹង ៥៨ លានដុល្លារ ។ រីឯអូស្ត្រាលីបានផ្តល់វ៉ាក់សាំង ២,៣ លានដូស សមមូលនឹង ២១ លានដុល្លារ ។ លើសពីនេះ ជប៉ុន, ចក្រភពអង់គ្លេស និងប៉ូឡូញ បានផ្តល់វ៉ាក់សាំង Astra Zeneca សរុប ១,៧ លានដូស សមមូលនឹង ៧,៧ លានដុល្លារ ។

**តារាងទី ៤.១ : វ៉ាក់សាំងជំងឺកូវីដ-១៩ ក្រោមកិច្ចសហប្រតិបត្តិការទ្វេភាគី និងយន្តការ COVAX**

| ដៃគូអភិវឌ្ឍន៍ | ប្រភេទវ៉ាក់សាំង | បរិមាណវ៉ាក់សាំង | តម្លៃសរុប (ដុល្លារអាមេរិក) |
|---|---|---|---|
| **កិច្ចសហប្រតិបត្តិការទ្វេភាគី** | | | |
| អូស្ត្រាលី | Pfizer-BioNTech | 2.350.530 | 20.916.031 |
| សាធារណរដ្ឋប្រជាមានិតចិន | Sinovac & Sinopharm | 8.300.000 | 58.100.000 |
| ជប៉ុន | AstraZeneca | 1.000.000 | 4.490.000 |
| ប៉ូឡូញ | AstraZeneca | 300.000 | 1.347.000 |
| ចក្រភពអង់គ្លេស | AstraZeneca | 415.000 | 1.863.530 |
| **សរុប** | | **12.365.530** | **86.716.561** |
| **យន្តការ COVAX** | | | |
| យន្តការ COVAX | AstraZeneca | 324.000 | 1.454.760 |
| | Sinovac | 424.800 | 2.973.600 |
| | Moderna | 188.160 | 1.881.600 |
| ជប៉ុន | AstraZeneca | 308.000 | 1.382.920 |
| ហូឡង់ | AstraZeneca | 290.400 | 1.303.896 |
| សាធារណរដ្ឋកូរ៉េ | AstraZeneca | 324.000 | 1.454.760 |
| អាមេរិក | Johnson & Johnson | 1.060.100 | 10.601.000 |
| **សរុប** | | **2.919.460** | **21.052.536** |
| **សរុបរួម** | | **15.284.990** | **107.769.097** |

ក្រៅពីការទទួលបានវ៉ាក់សាំងក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគីយន្តការ COVAX ដែលជាយន្តការសកល បានរួមចំណែកគួរឱ្យកត់សម្គាល់ក្នុងការយុទ្ធនាការចាក់វ៉ាក់សាំងនៅកម្ពុជាផងដែរ ។ វ៉ាក់សាំងប្រមាណជិត ៣ លានដូស (សមមូលនឹង ២១ លានដុល្លារ) ដែលផ្តល់តាមរយៈយន្តការនេះ បានផ្តល់លទ្ធភាពដល់រាជរដ្ឋាភិបាលពង្រឹងសមត្ថភាពរបស់ខ្លួន សម្រាប់ពង្រីកវិសាលភាពយុទ្ធនាការនៅទូទាំងប្រទេស និងចាក់វ៉ាក់សាំងដូសជំរុញ ។ តាមរយៈយន្តការនេះ កម្ពុជាមានលទ្ធភាពបញ្ជាទិញវ៉ាក់សាំងក្នុងតម្លៃសមរម្យ និងទទួលបានវ៉ាក់សាំងជាអំណោយពីដៃគូដទៃទៀតផង ។ ទន្ទឹមនឹងនេះ សហរដ្ឋអាមេរិកបានផ្តល់វ៉ាក់សាំង Johnson & Johnson ចំនួន ១ លានដូស សមមូលនឹង ១០ លានដុល្លារ ។ បន្ទាប់មក សាធារណរដ្ឋកូរ៉េ និងហូឡង់ក៏បានផ្តល់វ៉ាក់សាំងសរុប ៦១៤ ៤០០ ដូស (សមមូលនឹង ២,៧ លានដុល្លារ) ។ តាមរយៈយន្តការ COVAX នេះដែរ, ជប៉ុនបានផ្តល់វ៉ាក់សាំងរបស់ខ្លួន ចំនួន៣០៨.០០០ ដូស បន្ថែមពីលើកិច្ចសហប្រតិបត្តិការទ្វេភាគី ។ គួរឱ្យកត់សម្គាល់ផងដែរថា វ៉ាក់សាំងដែលទទួលបាន ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី និងយន្តការ COVAX មានប្រមាណ ១/៣ នៃចំនួនវ៉ាក់សាំងសរុប ។ រីឯ ចំនួន ២/៣ ទៀត គឺជាការបញ្ជាទិញដោយប្រើប្រាស់ថវិកាផ្ទាល់របស់រាជរដ្ឋាភិបាល ។

## ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រលើការឆ្លើយតបបន្ទាន់

ទន្ទឹមនឹងការផ្តល់វ៉ាក់សាំង, ដៃគូអភិវឌ្ឍន៍បានពង្រឹងការប្តេជ្ញារបស់ខ្លួន សម្រាប់គាំទ្ររាជរដ្ឋាភិបាលក្នុងអំឡុងពេលនៃជំងឺរាតត្បាតនេះ ។ រំហូរហិរញ្ញប្បទានសហប្រតិបត្តិការត្រូវបានចែកចេញជាពីរផ្នែកសំខាន់រួមមានហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការឆ្លើយតបបន្ទាន់ និងសម្រាប់ការស្តារសង្គម-សេដ្ឋកិច្ច ។

ជាក់ស្តែង តាមរយៈអតិក្រមដែលរាជរដ្ឋាភិបាលបានដាក់ចេញ, ដៃគូអភិវឌ្ឍន៍បានផ្តល់ហិរញ្ញប្បទានសម្រាប់គាំទ្រវិស័យដែលទទួលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងបានផ្តល់ធនធានដល់កម្ពុជាសម្រាប់ស្តារសេដ្ឋកិច្ចឡើងវិញ និងក្តាប់យកចលនការដើម្បីបន្តជំរុញការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ។

**តារាងទី ៤២ ហិរញ្ញប្បទានសហប្រតិបត្តិការគាំទ្រការឆ្លើយតបបន្ទាន់ (ពាន់ដុល្លារ)**

| ដៃគូអភិវឌ្ឍន៍ | 2020 | 2021 ប៉ាន់ស្មាន | 2022 ព្យាករណ៍ |
|---|---|---|---|
| អូស្ត្រាលី | 2,693 | 28,705 | 4,994 |
| សាធារណរដ្ឋប្រជាមានិតចិន | 28,100 | 30,000 | |
| សាធារណរដ្ឋឆែក | 107 | - | - |
| GAVI | - | 248 | - |
| អាល្លឺម៉ង់ | - | - | - |
| អៀរឡង់ | 397 | 535 | - |
| ជប៉ុន | 18,721 | 1,902 | - |
| ស្វីស | 272 | 926 | - |
| ចក្រភពអង់គ្លេស | 20 | 1,952 | 21 |
| សហរដ្ឋអាមេរិក | 7,990 | 16,602 | 11,891 |
| ភ្នាក់ងារអង្គការសហប្រជាជាតិ | 10,007 | 13,262 | 9,020 |
| **សរុប** | **68,307** | **94,132** | **25,926** |

តារាងទី ៤.២ បង្ហាញថា ក្នុងឆ្នាំ ២០២០ រាជរដ្ឋាភិបាលបានទទួលហិរញ្ញប្បទាន សម្រាប់ការឆ្លើយតបបន្ទាន់ចំនួន ៦៨ លានដុល្លារ ។ ធនធានទាំងនេះបានរួមចំណែកទាំងស្រុង ឬដោយផ្នែក ក្នុងការគាំទ្រដល់ការឆ្លើយតបបន្ទាន់ ដោយផ្តោតលើវិស័យសុខាភិបាល រួមមាន÷ ១) ការស្វែងរក និងគ្រប់គ្រងករណីឆ្លង, ២) ឱសថ និង បរិក្ខារពេទ្យ និង ៣)ការត្រៀមខ្លួន, ការកសាងសមត្ថភាព និងវគ្គបណ្តុះបណ្តាល ។ ជាមួយគ្នានេះ ហិរញ្ញប្បទាននេះក៏បានផ្តល់ការគាំទ្របន្ទាន់ និងរយៈពេលខ្លី សម្រាប់វិស័យដទៃទៀតដែលមានតម្រូវការបន្ទាន់ ។ សាធារណរដ្ឋប្រជាមានិតចិនជាដៃគូនាំមុខគេដោយបានផ្តល់ធនធានប្រមាណ ២៨,១ លានដុល្លារ ខណៈពេលដែលជប៉ុនបានផ្តល់ទឹកប្រាក់ប្រមាណ ១៨,៧ លានដុល្លារ ។ រីឯភ្នាក់ងារអង្គការសហប្រជាជាតិក៏បានចូលរួមក្នុងការឆ្លើយតបនេះ ប្រមាណ ១០ លានដុល្លារដែរ ។

ការប្រែប្រួលនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការក្នុងឆ្នាំ ២០២១ បង្ហាញអំពីការកើនឡើងនៃការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ ក្នុងនោះការបើកផ្តល់ហិរញ្ញប្បទានកើនដល់ ៩៤ លានដុល្លារ ។ ជាក់ស្តែងសាធារណរដ្ឋប្រជាមានិតចិនបន្តជាដៃគូយុទ្ធសាស្ត្រ ដោយបានបើកផ្តល់ទឹកប្រាក់ចំនួន ៣០ លានដុល្លារ ។ អូស្ត្រាលីបានបង្កើនការគាំទ្ររបស់ខ្លួនពី ២,៦ លានដុល្លារ ក្នុងឆ្នាំ ២០២០ ដល់ ២៨,៧ លានដុល្លារ ក្នុងឆ្នាំ ២០២១ ។ ទន្ទឹមនឹងនេះ ដៃគូអភិវឌ្ឍន៍សំខាន់ ៤ បានប្រកាសពីផែនការបើកផ្តល់របស់ខ្លួនសម្រាប់គាំទ្រដល់ការឆ្លើយតបបន្ទាន់ក្នុងឆ្នាំ២០២២ ដែលមានហិរញ្ញប្បទាន ២៥,៩ លានដុល្លារ ក្នុងនោះសហរដ្ឋអាមេរិកគ្រោងផ្តល់ហិរញ្ញប្បទាន ១១,៨ លានដុល្លារ ខណៈដែលភ្នាក់ងារអង្គការសហប្រជាជាតិនឹងផ្តល់ ៩ លានដុល្លារ និងអូស្ត្រាលី ៤,៩ លានដុល្លារ ។

***ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ***

ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ ដៃគូអភិវឌ្ឍន៍បានរៀបចំការគាំទ្រ ឬ/និងបើកផ្តល់របស់ខ្លួនឡើងវិញ ដើម្បីធានាឱ្យមានសង្គតិភាពជាមួយ “ក្របខណ្ឌយុទ្ធសាស្ត្រនិងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ២០២១-២០២៣” ។ ដៃគូអភិវឌ្ឍន៍មួយចំនួន រួមមានធនាគារអភិវឌ្ឍន៍អាស៊ី, ជប៉ុន និងសាធារណរដ្ឋកូរ៉េ បានរៀបចំគម្រោងថ្មី ដើម្បី គាំទ្ររាជរដ្ឋាភិបាលក្នុងការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ ។ ដោយឡែក ដៃគូអភិវឌ្ឍន៍

មួយចំនួនទៀតបានបង្វែរធនធានរបស់ខ្លួន មកគាំទ្រសកម្មភាពនានាដែលពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ ខណៈដៃគូដទៃទៀត បានបញ្ច្រាបសមាសធាតុចាំបាច់មួយចំនួន ទៅក្នុងគម្រោងរបស់ខ្លួន សម្រាប់កាត់បន្ថយផលប៉ះពាល់នៃជំងឺកូវីដ-១៩ ។ ទោះបីជាគ្មានការបែងចែកច្បាស់លាស់អំពីការផ្តល់ហិរញ្ញប្បទានទាំងនេះ, ការវិភាគបានផ្តល់ការយល់ដឹងលើហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ដែលបានរួមចំណែកដោយផ្ទាល់ និងដោយប្រយោលក្នុងការស្តារសង្គម-សេដ្ឋកិច្ចកម្ពុជាឡើងវិញ ។

**តារាងទី ៤.៣ ការគាំទ្រទៅលើការស្តារឡើងវិញនៃសង្គម-សេដ្ឋកិច្ច (ពាន់ដុល្លារ)**

| ដៃគូអភិវឌ្ឍន៍ | 2020 | 2021 ប៉ាន់ស្មាន | 2022 ព្យាករណ៍ |
|---|---|---|---|
| ធនាគារអភិវឌ្ឍន៍អាស៊ី | 263,517 | 15,178 | 1,800 |
| អូស្ត្រាលី | 18,998 | 25,289 | 21,785 |
| សហភាពអឺរ៉ុប | 4,326 | 10,880 | 8,827 |
| GAVI | 585 | 778 | - |
| អាល្លឺម៉ង់ | 6,518 | 16,191 | 9,668 |
| អៀរឡង់ | - | 10 | - |
| ជប៉ុន | 234,017 | - | - |
| នូវែលសេឡង់ | - | 3,194 | - |
| សាធារណរដ្ឋកូរ៉េ | 52,849 | 2,731 | 1,630 |
| ស៊ុយអែត | 5,713 | 352 | - |
| ស្វីស | 4,580 | 4,585 | 3,538 |
| សហរដ្ឋអាមេរិក | 18,521 | 20,970 | 17,945 |
| ភ្នាក់ងារអង្គការសហប្រជាជាតិ | 27,460 | 33,723 | 28,330 |
| ធនាគារពិភពលោក | 28,336 | 13,450 | 10,998 |
| **សរុប** | **665,420** | **147,331** | **104,521** |

តារាងទី ៤.៣ បានបង្ហាញថា ក្នុងឆ្នាំ២០២០ ដៃគូអភិវឌ្ឍន៍បានផ្តល់ហិរញ្ញប្បទានចំនួន ៦៦៥ លានដុល្លារ សម្រាប់គាំទ្រការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ ។ ធនាគារអភិវឌ្ឍន៍អាស៊ី គឺជាដៃគូធំជាងគេ ដែលបានបើកផ្តល់ធនធាន ២៦៣ លានដុល្លារ ខណៈជប៉ុនបើកផ្តល់ ២៣៤ លានដុល្លារ និងសាធារណរដ្ឋកូរ៉េ ៥២,៨ លានដុល្លារ ។ ដៃគូអភិវឌ្ឍន៍ ៣ បានរៀបចំគម្រោងគាំទ្រ រាជរដ្ឋាភិបាល ដោយបានបើកផ្តល់ហិរញ្ញប្បទានទាំងអស់ក្នុងមួយលើក ក្នុងនោះ រួមមាន ធនាគារអភិវឌ្ឍន៍អាស៊ី ២៥០ លានដុល្លារ, ជប៉ុន ២០០ លានដុល្លារ, និង សាធារណរដ្ឋកូរ៉េ ៥០ លានដុល្លារ ។ រីឯធនាគារពិភពលោក ក៏បានបើកផ្តល់ហិរញ្ញប្បទាន ២៨ លានដុល្លារ ស្របពេលដែលភ្នាក់ងារអង្គការសហប្រជាជាតិបានបើកផ្តល់ ២៧ លានដុល្លារ ។ ក្នុងឆ្នាំ ២០២១ ហិរញ្ញប្បទានសម្រាប់គាំទ្រការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ អាចថយចុះមកត្រឹម ១៤៧ លានដុល្លារ ។ ភ្នាក់ងារអង្គការសហប្រជាជាតិ បានបង្កើនហិរញ្ញប្បទានដល់ ៣៣ លានដុល្លារ ស្របពេលដែលអូស្ត្រាលីកើនដល់ ២៥លានដុល្លារ និងសហរដ្ឋអាមេរិកកើនដល់ ២០លានដុល្លារ ។ រីឯសហភាពអឺរ៉ុប (EU/EC) ក៏បានបង្កើនការគាំទ្រដល់ ១០ លានដុល្លារ ។ ទន្ទឹមនឹងនេះ ការបើកផ្តល់ហិរញ្ញប្បទានគាំទ្រការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ សម្រាប់ឆ្នាំ ២០២២ ត្រូវបានព្យាករណ៍ក្នុងរង្វង់ប្រមាណ ១០៤ លានដុល្លារ ។

***ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម***

ជំងឺកូវីដ-១៩ បានបង្កបញ្ហាប្រឈមដែលពុំធ្លាប់មានកន្លងមកនៅកម្ពុជា ដែលកម្ពុជាអាចប្រែក្លាយទៅជាកាលានុវត្តភាពក្នុងពេលមានវិបត្តិនេះ ។ ការវិនិយោគកន្លងមកក្នុងប្រព័ន្ធសន្តិសុខសុខាភិបាល បានចាប់ផ្តើមផ្តល់ផ្លែផ្កា និងបានបង្កើតជាវិធានការសុខាភិបាលបុរេសកម្មសម្រាប់កម្ពុជា ។ ជំងឺកូវីដ-១៩ ជាកម្លាំងចលករដែលធ្វើឱ្យមានការកែទម្រង់រយៈពេលវែង និងហ្មត់ចត់ក្នុងវិស័យសុខាភិបាល ព្រមទាំងបោះជំហានឆ្ពោះទៅកាន់ការអនុវត្តប្រព័ន្ធថែទាំសុខភាពសកល ។ ទន្ទឹមនេះ ជំងឺរាតត្បាតនេះបានផ្តល់នូវកាលានុវត្តភាព

ថ្មីមួយ ដើម្បីពន្លឿនការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ស្របតាមស្ថានការណ៍ដែលមានការវិវិត្តឆាប់រហ័ស ។

រាជរដ្ឋាភិបាលបានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់គ្រួសារក្រីក្រ និងងាយរងគ្រោះ ៩ ជុំ ក្នុងរយៈពេល ១០ខែកន្លងមក ។ គិតត្រឹមខែកុម្ភៈ ឆ្នាំ២០២២ ប្រជាជនប្រមាណ ២,៧ លាននាក់ មកពី ៦៨៧ ៣៥៤ គ្រួសារទទួលបានជំនួយសាច់ប្រាក់ប្រមាណ ៥៩២,៥ លានដុល្លារ ។ បន្ថែមពីនេះ កម្មករ ៥ ៥៧៦ នាក់ មកពីសហគ្រាស ៤២ ក្នុងវិស័យងាយរងគ្រោះ ពិសេសក្នុងវិស័យកាត់ដេរ និងទេសចរណ៍ បានទទួលការឧបត្ថម្ភសាច់ប្រាក់ពីរាជរដ្ឋាភិបាល ។ ការឧបត្ថម្ភសាច់ប្រាក់នេះ បានដាក់ចេញ ៧៨ លើក និងទទួលបានប្រាក់ឧបត្ថម្ភប្រមាណពី ១៥ ទៅ ៤០ ដុល្លារ អនុលោមតាមកិច្ចសន្យាការងាររៀងៗខ្លួន ។

ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តរបប និងកម្មវិធីគាំពារសង្គម, ដៃគូអភិវឌ្ឍន៍បានដើរតួនាទីសំខាន់ក្នុងការធានាសន្តិសុខប្រាក់ចំណូល និងកាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ប្រជាជនកម្ពុជា ។ តារាងទី ៤.៤ បង្ហាញថា ក្នុងឆ្នាំ២០២០ សាធារណរដ្ឋកូរ៉េ គឺជាដៃគូអភិវឌ្ឍន៍ដែលបានចូលរួមច្រើនជាងគេ ក្នុងការគាំទ្រវិស័យគាំពារសង្គម តាមរយៈរបបថែទាំសុខភាព ដោយបើកផ្តល់ធនធាន ប្រមាណ ៥០ លានដុល្លារ ។ ការគាំទ្រនេះត្រូវបានចាត់ទុកថាជាជំនួយសង្គ្រោះបន្ទាន់សម្រាប់គាំទ្រប្រជាជនក្រីក្រ និងងាយរងគ្រោះគោលដៅក្នុងអំឡុងពេលនៃការបិទខ្ទប់ប្រទេស ។ ស៊ុយអែត គឺជាដៃគូអភិវឌ្ឍន៍ទី២ និងបានអនុវត្តគម្រោងដែលមានថវិកា ២ លានដុល្លារ គាំទ្រកម្មវិធីសុខុមាលភាពរបស់ប្រជាជនងាយរងគ្រោះ ដើម្បីលើកកម្ពស់ការទទួលបានសេវាសង្គមដែលនៅមានកម្រិត នៅថ្នាក់ក្រោមជាតិ ។ លើសពីនេះ អង្គការ UNICEF និងសហភាពអឺរ៉ុប បានចូលរួមគាំទ្រ និងពង្រឹងប្រព័ន្ធគាំពារសង្គម តាមរយៈការធ្វើសមាហរណកម្មការឆ្លើយតបនឹងជំងឺកូវីដ-១៩ សម្រាប់ប្រជាជនក្រីក្រក្នុងទីក្រុង, សហគមន៍នៅទីក្រុងដែលជួបការលំបាក, ប្រជាជនងាយរងគ្រោះ និងកម្មករដែលមិនស្ថិតនៅក្រោមរបបសន្តិសុខសង្គម ។

**តារាង ៤.៤: ហិរញ្ញប្បទានគាំទ្រវិស័យគាំពារសង្គមដោយដៃគូអភិវឌ្ឍន៍ (ពាន់ដុល្លារ)**

| ដៃគូអភិវឌ្ឍន៍ | 2020 | 2021 ប៉ាន់ស្មាន | 2022 ព្យាករណ៍ | 2023 ព្យាករណ៍ | សរុប |
|---|---:|---:|---:|---:|---:|
| សហភាពអឺរ៉ុប | 1,090.8 | 3,651.5 | 2,926.7 | 2,432.2 | 10,101.1 |
| អាល្លឺម៉ង់ | - | 297.2 | 3,087.4 | 3,473.1 | 6,857.6 |
| អង្គការ ILO | - | 250.0 | 337.5 | 112.5 | 700.0 |
| ជប៉ុន | - | 1,911.3 | - | - | 1,911.3 |
| សាធារណរដ្ឋកូរ៉េ | 50,000.0 | - | - | - | 50,000.0 |
| ស៊ុយអែត | 2,048.1 | - | - | - | 2,048.1 |
| ស្វីស | 169.4 | 43.9 | - | - | 213.3 |
| ចក្រភពអង់គ្លេស | 288.3 | - | - | - | 288.3 |
| អង្គការ UNDP | 450.3 | 643.4 | 749.3 | 37.4 | 1,880.3 |
| អង្គការ UNICEF | 1,150.0 | 2,368.3 | 690.6 | 704.8 | 4,913.6 |
| **សរុប** | **55,196.7** | **9,165.5** | **7,791.5** | **6,759.9** | **78,913.6** |

*ការរួមចំណែកក្នុងការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម*

ទន្ទឹមនឹងការគាំទ្រដោយផ្ទាល់ដល់វិស័យគាំពារសង្គម គម្រោងជាច្រើនត្រូវបានអនុវត្តនៅតាមវិស័យគោលដទៃទៀត (រួមមាន សុខាភិបាល, អប់រំ ។ល។) តាមរយៈការផ្សារភ្ជាប់ និងផ្តល់ការគាំទ្រដោយប្រយោលដល់ការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ។ គម្រោងទាំងនេះត្រូវបានកត់ត្រាក្នុងវិស័យសម្គាល់បន្ថែមគាំពារសង្គម សម្រាប់ការវិភាគកាន់តែច្បាស់អំពីវិស័យគាំពារសង្គម ដែលជាគោលនយោបាយអន្តរវិស័យ ។ តារាងទី ៤.៥ បង្ហាញថា អនុវិស័យ ៤ ពិសេសសម្រាប់ប្រព័ន្ធជំនួយសង្គម ទទួលបានការគាំទ្របន្ថែមពីគម្រោងរបស់ដៃគូអភិវឌ្ឍន៍ ក្នុងនោះមានគម្រោងមួយចំនួនបានផ្តល់ការគាំទ្រច្រើនជាង ១ អនុវិស័យនៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ។

ក្នុងឆ្នាំ ២០២០, ក្នុងចំណោមគម្រោង ១១, កម្មវិធីអភិវឌ្ឍន៍មូលធនមនុស្សទទួលបានការគាំទ្រប្រមាណ ៩ លានដុល្លារ ដែលផ្តល់ការគាំទ្រដល់សុខភាព និងអាហារូបត្ថម្ភរបស់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ៥ឆ្នាំ និងលើកកម្ពស់ការទទួលបានអាហារ តាមរយៈការផ្តល់អាហារតាមសាលាសម្រាប់កុមារថ្នាក់មត្តេយ្យសិក្សា និងបឋមសិក្សា ។ ជាមួយគ្នានេះ កម្មវិធីសុខុមាលភាពសម្រាប់ប្រជាជនងាយរងគ្រោះ គឺជាកម្មវិធីទី ២ ដែលទទួលបានការគាំទ្រប្រមាណ ១ លានដុល្លារ ។ បន្ទាប់មក គឺកម្មវិធីការឆ្លើយតបនឹងគ្រោះអាសន្ន ដែលគាំទ្រដល់ការពង្រឹងសមត្ថភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការឆ្លើយតបនឹងគ្រោះធម្មជាតិ និងគាំពារប្រព័ន្ធសន្តិសុខស្បៀងនៅមូលដ្ឋាន ។ ហិរញ្ញប្បទានសរុបសម្រាប់វិស័យគាំពារសង្គម បានកើនពី ១០ លានដុល្លារ ក្នុងឆ្នាំ ២០២០ ដល់ ១៨ លានដុល្លារ ក្នុងឆ្នាំ ២០២១ ។ ទន្ទឹមនេះ ក្នុងចន្លោះឆ្នាំ២០២០ និង ២០២១ ការបើកផ្តល់ហិរញ្ញប្បទានសម្រាប់ កម្មវិធីសុខុមាលភាពរបស់ប្រជាជនងាយរងគ្រោះ នៅរក្សាទំហំថេរ ខណៈធនធានសម្រាប់កម្មវិធីអភិវឌ្ឍន៍មូលធនមនុស្សបានកើនបន្តិច ចំនួន ១ លានដុល្លារ ។ ដោយឡែកកម្មវិធីការឆ្លើយតបបន្ទាន់ជាវិស័យសម្គាល់បន្ថែមទី ២ ដែលទទួលបានការគាំទ្រច្រើន នៅក្នុងឆ្នាំ ២០២១ ដោយបានកើនពី ៣២៤.៨០០ ដុល្លារ ក្នុងឆ្នាំ២០២០ ដល់ ៦ លានដុល្លារ ក្នុងឆ្នាំ២០២១ ។

**តារាង ៤.៥: ការចូលរួមចំណែករបស់ដៃគូអភិវឌ្ឍន៍ក្នុងការគាំពារសង្គម (ពាន់ដុល្លារ)**

| ការគាំពារសង្គម | 2020 | 2021 ប៉ាន់ស្មាន | 2022 ព្យាករណ៍ | 2023 ព្យាករណ៍ | ចំនួនគម្រោង | សរុប |
|---|---|---|---|---|---|---|
| ជំនួយសង្គម: ការឆ្លើយតបនឹងគ្រោះអាសន្ន | 324.8 | 6,013.1 | 376.5 | 415.9 | 2 | 7,130.3 |
| ជំនួយសង្គម: ការអភិវឌ្ឍមូលធនមនុស្ស | 9,012.0 | 10,243.2 | 6,956.8 | 6,751.1 | 3 | 32,963.2 |
| ជំនួយសង្គម: សុខុមាលភាពសង្គមរបស់ជនងាយរងគ្រោះ | 1,072.9 | 1,067.3 | 1,208.7 | - | 5 | 3,348.9 |
| ជំនួយសង្គម: TVET | - | 880.3 | 307.8 | 114.0 | 1 | 1,302.1 |
| **សរុប** | **10,409.8** | **18,203.9** | **8,849.9** | **7,281.0** | **11** | **44,744.6** |

# ជំពូក ៥

# ស្ថានភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្នុងអន្តរវិស័យ

រាជរដ្ឋាភិបាលទទួលស្គាល់ពីតួនាទីសំខាន់នៃអន្តរវិស័យ ក្នុងការរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន ។ គ.ជ.ន/ក.អ.ក បានបន្តសហការជាមួយបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ក្នុងការរៀបចំសេចក្តីណែនាំដែលមានភាពគ្រប់ជ្រុងជ្រោយ និងកែសម្រួលប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីតាមដានការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ក្នុងអន្តរវិស័យចំនួន ៣ គឺ ÷ សមភាពយេនឌ័រ, ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍវិស័យឯកជន ។ បន្ថែមលើការកត់ត្រាការគាំទ្រតាមវិស័យ និងអនុវិស័យ, វិស័យសម្គាល់បន្ថែមចំនួន ៣ ក៏ត្រូវបានកត់ត្រានៅក្នុងប្រព័ន្ធទិន្នន័យហិរញ្ញប្បទានដើម្បីវាស់វែងការគាំទ្រដោយប្រយោលក្រៅពីវិស័យគោល ដោយបានធ្វើចំណាត់ថ្នាក់ការគាំទ្រពីកម្រិតទាបទៅកម្រិតមធ្យម និងកម្រិតខ្ពស់ ។

ជំពូកនេះ នឹងវិភាគអំពីការគាំទ្រហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ដល់វិស័យគោល និងវិស័យសម្គាល់បន្ថែមទាំង ៣ ។ ការវិភាគ នឹងផ្តោតសំខាន់លើកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សម្រាប់វិស័យគោល និងអនុវិស័យ ក៏ដូចជាការបញ្ជ្រាបការគាំទ្រក្នុងវិស័យដទៃទៀត ដែលពាក់ព័ន្ធនឹងអន្តរវិស័យទាំង ៣ ។ ជាមួយគ្នានេះ ការវិភាគក៏នឹងផ្តោតលើការគាំទ្រដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាចំនួន ២ គឺគោលដៅទី ៥ ស្តីពីសមភាពយេនឌ័រ និងគោលដៅទី ១៣ ស្តីពីការប្រែប្រួលអាកាសធាតុ ។

### *ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់លើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី*

ដើម្បីតាមដានហិរញ្ញប្បទានគាំទ្រសមភាពយេនឌ័រ ក្នុងប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ, គ.ជ.ន/ក.អ.ក និងក្រសួងកិច្ចការនារី បានផ្តើមកិច្ចសហការក្នុងការបង្កើតវិស័យគោលសម្រាប់យេនឌ័រ និងអនុវិស័យយេនឌ័រ ដែលមានសង្គតិភាពជាមួយសេចក្តីណែនាំស្តីពីការបញ្ជ្រាបសមភាពយេនឌ័រ ។ តារាងទី ៥.១ បង្ហាញថាការបើកផ្តល់ហិរញ្ញប្បទានសរុបសម្រាប់វិស័យគោលយេនឌ័រ បានកើនពី ៥,៩៤ លានដុល្លារ ក្នុងឆ្នាំ២០២០ ដល់ ៦,៦០ លានដុល្លារ ក្នុងឆ្នាំ២០២១ ស្មើនឹង ០,៣២% នៃហិរញ្ញប្បទានសរុប ឆ្នាំ ២០២១ ។ ការកើនឡើងនៃការបើកផ្តល់នេះ គឺបំពេញដោយការកើនឡើងធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលពី ០,៩ លានដុល្លារ ក្នុងឆ្នាំ២០២០ ដល់ ១,៣ លានដុល្លារ ក្នុងឆ្នាំ២០២១ ។ នៅចន្លោះឆ្នាំ២០១៩-២០២១ អនុវិស័យស្តីពីយន្តការ, បណ្តាញ និងភាពជាដៃគូយេនឌ័រ ទទួលបានការគាំទ្រច្រើនជាងគេក្នុងទំហំ ៥,៣២ លានដុល្លារ ខណៈដែលហិរញ្ញប្បទានទំហំដូចគ្នានេះ បានគាំទ្រដល់អនុវិស័យផ្សេងៗ ។ ក្របខណ្ឌគោលនយោបាយ និងគតិយុត្តិ ជាអនុវិស័យបន្ទាប់ដែលទទួលបានហិរញ្ញប្បទានច្រើន ។ ទោះជាយ៉ាងនេះក្តី អនុវិស័យស្តីពីការសិក្សាស្រាវជ្រាវ, ស្ថិតិ, ការតាមដាន និងវាយតម្លៃយេនឌ័រ ទទួលបានការគាំទ្រតិចតួច ដែលទាមទារការចូលរួមគាំទ្ររបស់ដៃគូអភិវឌ្ឍន៍បន្ថែមទៀត ដោយសារអនុវិស័យនេះមានសារៈសំខាន់ ។

**តារាងទី ៥.១៖ ការបើកផ្តល់ហិរញ្ញប្បទានគាំទ្រវិស័យគោលយេនឌ័រ ឆ្នាំ២០១៩-២០២១ (លានដុល្លារ)**

| វិស័យគោល និងអនុវិស័យយេនឌ័រ | ២០១៩ ជាក់ស្តែង | ២០២០ ជាក់ស្តែង | ២០២១ ប៉ាន់ស្មាន | សរុបឆ្នាំ ២០១៩-២០២១ |
|---|---|---|---|---|
| ការលើកកម្ពស់គុណនេយ្យភាព និងការវិនិយោគដែលឆ្លើយតបនឹងយេនឌ័រ | 0.02 | 0.04 | 0.08 | 0.15 |
| ការសិក្សាស្រាវជ្រាវ ស្ថិតិ ការតាមដាន និងវាយតម្លៃយេនឌ័រ | 0.05 | 0.00 | - | 0.05 |
| ក្របខណ្ឌគោលនយោបាយ និងគតិយុត្តិ | 1.18 | 1.20 | 1.03 | 3.42 |
| យន្តការ បណ្តាញ និងភាពជាដៃគូ | 2.51 | 1.07 | 1.73 | 5.32 |
| ការលើកកម្ពស់ផ្នត់គំនិតជាវិជ្ជមាន | 0.41 | 0.36 | 0.37 | 1.15 |
| ផ្សេងៗ | 0.92 | 2.35 | 2.03 | 5.30 |
| **សរុប** | **5.09** | **5.04** | **5.26** | **15.41** |
| **NGOs (ធនធានផ្ទាល់)** | **0.87** | **0.88** | **1.32** | **3.08** |
| **សរុបរួម** | **5.97** | **5.93** | **6.59** | **18.50** |

ដៃគូអភិវឌ្ឍន៍ចំនួន ១៣ បានគាំទ្រយ៉ាងសកម្ម និងគាំទ្រផ្ទាល់ដល់វិស័យគោលយេនឌ័រ ។ នៅចន្លោះឆ្នាំ២០១៩-២០២១ ការបើកផ្តល់ហិរញ្ញប្បទានសរុបសម្រាប់វិស័យយេនឌ័រមានទំហំ ៥ លានដុល្លារ ក្នុងមួយឆ្នាំ ទោះបីដៃគូអភិវឌ្ឍន៍មួយចំនួន ដូចជា ស៊ុយអែត និងអង្គការ UNDP បានបញ្ចប់ការគាំទ្រដល់វិស័យនេះក៏ដោយ ។ អូស្ត្រាលី, ជប៉ុន, UN Women, អាល្លឺម៉ង់ និងសហភាពអឺរ៉ុប ជាដៃគូអភិវឌ្ឍន៍ដែលបានគាំទ្រវិស័យយេនឌ័រច្រើនជាងគេ ដោយបានបើកផ្តល់ហិរញ្ញប្បទានសរុប ១១,៧៧ លានដុល្លារ ស្មើនឹង ៧៦% នៃហិរញ្ញប្បទានសរុបសម្រាប់គាំទ្រគម្រោងនានានៃវិស័យយេនឌ័រ ។

**តារាងទី ៥.២៖ ការបើកផ្តល់ហិរញ្ញប្បទានគាំទ្រវិស័យគោលយេនឌ័ររបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៩-២០២១ (លានដុល្លារ)**

| ដៃគូអភិវឌ្ឍន៍ | ២០១៩ ជាក់ស្តែង | ២០២០ ជាក់ស្តែង | ២០២១ ប៉ាន់ស្មាន | សរុបឆ្នាំ ២០១៩-២០២១ |
|---|---|---|---|---|
| Australia | 0.52 | 2.30 | 2.03 | 4.86 |
| Japan | 1.78 | 0.45 | 0.68 | 2.92 |
| UN Women | 0.59 | 0.44 | 0.71 | 1.75 |
| Germany | 0.48 | 0.31 | 0.33 | 1.13 |
| EU/EC | 0.35 | 0.35 | 0.37 | 1.08 |
| USA | 0.13 | 0.29 | 0.65 | 1.07 |
| ILO | 0.30 | 0.33 | 0.19 | 0.83 |
| Sweden | 0.28 | 0.23 | - | 0.52 |
| Canada | 0.12 | 0.13 | 0.11 | 0.37 |
| UNFPA | 0.03 | 0.08 | 0.15 | 0.27 |
| UNDP | 0.16 | 0.04 | - | 0.21 |
| Switzerland | 0.20 | 0.00 | - | 0.20 |
| UK | 0.11 | 0.02 | - | 0.13 |
| **សរុប** | **5.09** | **5.04** | **5.26** | **15.41** |

តារាងទី ៥.៣ បង្ហាញថា ការបើកផ្តល់ហិរញ្ញប្បទានក្នុងឆ្នាំ២០២១ ដែលត្រូវបានប៉ាន់ស្មានថាមានទំហំ ៤៦៥,០៨ លានដុល្លារ ស្មើនឹង ១/៤ នៃហិរញ្ញប្បទានសរុបឆ្នាំ២០២១ បានគាំទ្រដល់ការលើកកម្ពស់ការបញ្ជ្រាបសមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ។ ការទ្រទ្រង់ថវិកា និងជញ្ជីងទូទាត់ ជាវិស័យដែលបានបញ្ជ្រាបយេនឌ័រ រហូតដល់ ១០០% ។ ទន្ទឹមនឹងនេះ ការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ច និងរដ្ឋបាល ជាវិស័យសំខាន់ទី ២ និងទី ៣ ដែលបានបញ្ជ្រាបយេនឌ័រ ប្រមាណ ៦៤% និង៥១% ។ ដោយឡែក

វិស័យថាមពល និងអគ្គិសនី និងវិស័យវប្បធម៌ និងសិល្បៈ បានបញ្ជ្រាបយេនឌ័រតិចជាង ១% នៃធនធានសម្រាប់វិស័យនេះ ក្នុងឆ្នាំ២០២១ ។

**តារាងទី ៥.៣ : ការបញ្ជ្រាបសមភាពយេនឌ័រតាមវិស័យ ឆ្នាំ២០១៩-២០២១ (លានដុល្លារ)**

| វិស័យ | ២០១៩ | ២០២០ | ២០២១ ប៉ាន់ស្មាន | | | | ធនធានតាមវិស័យ ឆ្នាំ២០២១ | យេនឌ័រ (% នៃធនធានតាមវិស័យ) |
|---|---|---|---|---|---|---|---|---|
| | | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |
| ការទ្រទ្រង់ថវិកា និងជញ្ជីងទូទាត់ | - | 261.33 | - | 10.697 | - | 10.69 | 10.69 | 100.00% |
| ការប្រែប្រួលអាកាសធាតុ | 6.74 | 5.90 | 0.96 | 4.081 | 0.23 | 5.27 | 8.28 | 63.69% |
| អភិបាលកិច្ច និងរដ្ឋបាល | 36.00 | 42.87 | 5.72 | 33.266 | 5.98 | 44.96 | 88.70 | 50.69% |
| ទេសចរណ៍ | 2.79 | 2.37 | 0.18 | 3.018 | - | 3.20 | 6.48 | 49.33% |
| សេវាធនាគារ និងធុរកិច្ច | 1.85 | 0.78 | 0.14 | 1.033 | 0.17 | 1.35 | 2.97 | 45.38% |
| សុខាភិបាល | 64.97 | 74.91 | 68.34 | 65.759 | 2.08 | 136.18 | 315.11 | 43.22% |
| គាំពារសង្គម | 0.80 | 3.84 | 0.03 | 3.303 | - | 3.33 | 9.21 | 36.18% |
| អប់រំ | 83.90 | 94.05 | 15.97 | 47.069 | 4.21 | 67.25 | 192.38 | 34.96% |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | 1.68 | 1.14 | - | 3.493 | 0.01 | 3.50 | 11.02 | 31.80% |
| ផ្សេងៗ | 3.74 | 2.48 | 1.18 | 1.845 | 1.42 | 4.45 | 15.42 | 28.86% |
| ទឹកស្អាត និងអនាម័យ | 63.68 | 12.84 | 39.94 | 7.863 | 3.19 | 50.99 | 178.31 | 28.60% |
| អភិវឌ្ឍន៍ជនបទ | 15.47 | 16.14 | 3.41 | 18.26 | 3.38 | 25.05 | 95.46 | 26.25% |
| ជំនួយសង្គ្រោះបន្ទាន់ និងស្បៀងអាហារ | 0.11 | 0.54 | 1.59 | 0.25 | 0.48 | 2.33 | 9.16 | 25.43% |
| កសិកម្ម | 39.94 | 37.26 | 17.55 | 29.702 | 6.60 | 53.87 | 254.69 | 21.15% |
| បរិស្ថាន និងចីរភាព | 5.58 | 7.80 | 2.11 | 4.69 | 0.04 | 6.84 | 33.34 | 20.52% |
| សហគមន៍ និងសុខុមាលភាពសង្គម | 12.58 | 10.08 | 0.01 | 14.062 | - | 14.07 | 74.67 | 18.85% |
| នគរូបនីយកម្ម និងការគ្រប់គ្រង | 16.26 | 10.21 | 4.05 | 3.523 | 0.40 | 7.98 | 48.14 | 16.59% |
| ព័ត៌មាន និងទូរគមនាគមន៍ | 0.03 | 0.18 | 0.00 | 0.515 | - | 0.52 | 8.96 | 5.81% |
| ការដឹកជញ្ជូន | 28.11 | 21.75 | 0.43 | 20.74 | - | 21.17 | 444.45 | 4.76% |
| ហ៊ីវ/អេដស៍ | 2.04 | 3.66 | - | 0.18 | - | 0.18 | 4.81 | 3.78% |
| ថាមពល និងអគ្គិសនី | 1.84 | 12.73 | 1.26 | 0.42 | - | 1.69 | 190.77 | 0.89% |
| វប្បធម៌ និងសិល្បៈ | 0.19 | 0.58 | 0.09 | 0.03 | - | 0.12 | 22.28 | 0.56% |
| **សរុប** | **388.38** | **623.57** | **163.03** | **273.81** | **28.24** | **465.08** | **2,025.40** | **22.96%** |

តារាងទី ៥.៤ បង្ហាញថា ដៃគូអភិវឌ្ឍន៍ចំនួន ៣២ បានបញ្ជ្រាបសមភាពយេនឌ័រទៅក្នុងគម្រោងរបស់ខ្លួន ស្មើនឹង ២៣% នៃហិរញ្ញប្បទានសរុបឆ្នាំ២០២១ ។ GAVI និង UNAIDS បានបញ្ជ្រាបសមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ១០០% នៃធនធានរបស់ខ្លួន ខណៈដែលកាណាដា និង UNESCO បានបញ្ជ្រាប ៨០% ។ បើគិតពីទំហំហិរញ្ញប្បទានវិញ ធនាគារអភិវឌ្ឍន៍អាស៊ីជាដៃគូ ដែលបានបញ្ជ្រាបសមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីច្រើនជាងគេរហូតដល់ ៨៤ លានដុល្លារ និងបន្ទាប់មកសហរដ្ឋអាមេរិក ៥៤ លានដុល្លារ និងធនាគារពិភពលោក ៥២ លានដុល្លារ ។

### តារាងទី ៥.៤: ការបញ្ជ្រាបសមភាពយេនឌ័ររបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៩-២០២១ (លានដុល្លារ)

| ដៃគូអភិវឌ្ឍន៍ | ២០១៩ | ២០២០ | ២០២១ ប៉ាន់ស្មាន | | | | ធនធានរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ ២០២១ | យេនឌ័រ (%នៃធនធានរបស់ដៃគូអភិវឌ្ឍន៍) |
|---|---|---|---|---|---|---|---|---|
| | | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |
| GAVI | 20.08 | 8.86 | 8.32 | 0.77 | - | 9.10 | 9.10 | 100.00% |
| UNAIDS | 0.21 | 0.07 | - | 0.18 | - | 0.18 | 0.18 | 100.00% |
| Canada | 1.88 | 1.51 | 0.82 | 1.58 | 0.08 | 2.49 | 2.93 | 84.90% |
| UNESCO | 4.07 | 3.78 | 2.72 | 0.36 | - | 3.08 | 3.69 | 83.64% |
| UNFPA | 1.58 | 2.06 | - | 2.23 | 0.13 | 2.36 | 3.40 | 69.56% |
| Switzerland | 7.46 | 10.90 | 7.69 | 3.58 | 0.54 | 11.83 | 17.11 | 69.13% |
| Australia | 15.88 | 12.85 | 2.74 | 39.10 | 2.16 | 44.01 | 66.47 | 66.20% |
| Ireland | 0.76 | 0.75 | 1.03 | - | - | 1.03 | 1.57 | 65.44% |
| FAO | 1.75 | 1.02 | 0.24 | 0.56 | 0.43 | 1.24 | 1.98 | 62.99% |
| Global Fund | - | - | 26.63 | - | - | 26.63 | 42.80 | 62.23% |
| Germany | 18.60 | 17.18 | 10.81 | 15.68 | 1.36 | 27.86 | 44.83 | 62.14% |
| Sweden | 16.08 | 20.82 | 7.09 | 2.93 | 3.47 | 13.50 | 22.46 | 60.10% |
| World Bank | 41.22 | 51.04 | 17.36 | 32.41 | 1.88 | 51.66 | 87.39 | 59.12% |
| USA | 47.70 | 48.03 | 13.91 | 34.64 | 5.61 | 54.16 | 112.11 | 48.31% |
| EU/EC | 32.46 | 47.36 | 9.69 | 25.12 | - | 34.82 | 76.90 | 45.27% |
| ILO | 1.71 | 1.47 | 0.38 | 1.68 | - | 2.07 | 4.89 | 42.32% |
| ADB | 85.43 | 328.80 | 7.50 | 65.44 | 11.08 | 84.03 | 204.83 | 41.03% |
| UNICEF | 6.28 | 10.75 | - | 11.98 | - | 11.98 | 29.42 | 40.73% |
| IAEA | - | 0.30 | 0.31 | 0.03 | - | 0.35 | 0.86 | 40.57% |
| UNDP | 5.13 | 4.48 | 0.68 | 3.01 | 0.05 | 3.75 | 9.51 | 39.46% |
| IFAD | 4.68 | 6.62 | 2.44 | 3.16 | 0.11 | 5.72 | 14.73 | 38.86% |
| UK | 0.61 | 0.65 | 0.75 | 0.44 | - | 1.19 | 3.41 | 35.02% |
| New Zealand | 3.93 | 3.76 | 0.24 | 1.66 | 1.06 | 2.97 | 8.59 | 34.58% |
| WHO | 0.54 | 3.19 | 4.026 | - | - | 4.02 | 12.07 | 33.34% |
| France | 44.57 | 18.27 | 36.81 | 0.01 | - | 36.83 | 117.37 | 31.38% |
| UN Women | 0.25 | 0.25 | - | - | 0.23 | 0.23 | 0.95 | 24.55% |
| Republic of Korea | 18.02 | 14.10 | 0.10 | 24.27 | - | 24.38 | 119.77 | 20.36% |
| Czech Republic | 0.95 | 0.75 | 0.29 | - | - | 0.29 | 2.73 | 10.62% |
| WFP | 2.11 | 0.79 | - | 0.85 | - | 0.85 | 8.09 | 10.61% |
| UNIDO | 0.16 | 0.08 | - | 0.19 | - | 0.19 | 2.29 | 8.37% |
| Japan | 4.09 | 2.91 | 0.34 | 1.82 | - | 2.17 | 400.58 | 0.54% |
| UNOCHR | 0.06 | 0.04 | - | - | - | - | - | 0% |
| Other | - | - | - | - | - | - | 592.26 | 0% |
| **សរុប** | **388.38** | **623.57** | **163.03** | **273.81** | **28.24** | **465.08** | **2,025.40** | **22.96%** |

### *ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការប្រែប្រួលអាកាសធាតុ*

គ.ជ.ន/ក.អ.ក និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បាន និងកំពុងសហការយ៉ាងជិតស្និទ្ធក្នុងការរៀបចំ និងផ្សព្វផ្សាយសេចក្តីណែនាំដើម្បីកត់ត្រាហិរញ្ញប្បទានសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ ។ ហិរញ្ញប្បទានគាំទ្រវិស័យគោលប្រែប្រួលអាកាសធាតុមានទំហំ ៩,០១ លានដុល្លារ ក្នុងឆ្នាំ២០២០ និងបានធ្លាក់ចុះមកត្រឹម ៨,២៨ លានដុល្លារ ក្នុងឆ្នាំ២០២១ ស្មើនឹង ០,៤% នៃហិរញ្ញប្បទានសរុបឆ្នាំ២០២១ ។ ការធ្លាក់ចុះទំហំហិរញ្ញប្បទាននេះ គឺដោយសារធនធានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាល បានធ្លាក់ចុះពី ០,៨៩ លានដុល្លារ ក្នុងឆ្នាំ២០២០ មកត្រឹម ០,០៦ លានដុល្លារ ក្នុងឆ្នាំ២០២១ ទោះបីទំហំហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍មិនមានការប្រែប្រួលក្នុងរយៈពេលដូចគ្នាក៏ដោយ ។

### តារាងទី ៥.៥: ការបើកផ្តល់ហិរញ្ញប្បទានគាំទ្រវិស័យគោលប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៩-២០២១ (លានដុល្លារ)

| វិស័យ និងអនុវិស័យប្រែប្រួលអាកាសធាតុ | ២០១៩ ជាក់ស្តែង | ២០២០ ជាក់ស្តែង | ២០២១ ប៉ាន់ស្មាន | សរុប ២០១៩-២០២១ |
|---|---|---|---|---|
| ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | 11.67 | 7.64 | 3.82 | 23.14 |
| ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ | 0.57 | 0.47 | 4.39 | 5.44 |
| ផ្សេងៗ | 0.01 | 0.01 | - | 0.02 |
| **សរុប** | **12.26** | **8.11** | **8.21** | **28.6** |
| **NGO (ធនធានផ្ទាល់)** | **1.03** | **0.89** | **0.06** | **1.99** |
| **សរុបរួម** | **13.30** | **9.01** | **8.28** | **30.6** |

ផ្អែកតាមប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ, ដៃគូអភិវឌ្ឍន៍ចំនួន ១៦ បាន និង កំពុងគាំទ្រដល់វិស័យគោលប្រែប្រួលអាកាសធាតុ ។ នៅចន្លោះឆ្នាំ២០១៩-២០២១ ដៃគូអភិវឌ្ឍន៍ចំនួន ៥ រួមមាន ÷ ស៊ុយអែត, UNDP, សហភាពអឺរ៉ុប, ជប៉ុន និងសាធារណរដ្ឋកូរ៉េ បានគាំទ្រដល់វិស័យប្រែប្រួលអាកាសធាតុច្រើនជាងគេប្រមាណជាង ២០ លានដុល្លារ ស្មើនឹង ៧៣% នៃហិរញ្ញប្បទានសរុបសម្រាប់វិស័យនេះ ។ ទោះបី ស៊ុយអែត និង UNDP ធ្លាប់ជាដៃគូដែលផ្តល់ការគាំទ្រដល់វិស័យប្រែប្រួលអាកាសធាតុច្រើនជាងគេ, ការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូទាំងពីរបានធ្លាក់ចុះជាបន្តបន្ទាប់ ដោយស៊ុយអែតបានផ្តល់ហិរញ្ញប្បទាន ត្រឹមតែ ០,៤៦ លានដុល្លារ ក្នុងឆ្នាំ២០២១ ខណៈដែល UNDP បានផ្តល់ហិរញ្ញប្បទាន ០,០៣ លានដុល្លារ ក្នុងរយៈពេលដូចគ្នា ហើយបានក្លាយជាដៃគូផ្តល់ការគាំទ្រតិចជាងគេ បន្ទាប់ពី UNICEF ។

### តារាងទី ៥.៦: ការបើកផ្តល់ហិរញ្ញប្បទានគាំទ្រវិស័យគោលប្រែប្រួលអាកាសធាតុរបស់ដៃគូ ឆ្នាំ២០១៩-២០២១ (លានដុល្លារ)

| ដៃគូអភិវឌ្ឍន៍ | ២០១៩ ជាក់ស្តែង | ២០២០ ជាក់ស្តែង | ២០២១ ប៉ាន់ស្មាន | សរុប ២០១៩-២០២១ |
|---|---|---|---|---|
| Sweden | 2.95 | 3.23 | 0.46 | 6.66 |
| UNDP | 3.43 | 1.46 | 0.03 | 4.93 |
| EU/EC | 0.49 | 1.80 | 1.58 | 3.88 |
| Japan | 2.74 | - | - | 2.74 |
| Republic of Korea | - | - | 2.60 | 2.60 |
| UNIDO | 0.57 | 0.36 | 1.43 | 2.37 |
| IFAD | 1.14 | 0.19 | - | 1.33 |
| New Zealand | 0.27 | 0.29 | 0.28 | 0.85 |
| UN Women | 0.25 | 0.25 | 0.23 | 0.73 |
| FAO | 0.05 | 0.20 | 0.40 | 0.66 |
| Czech Republic | 0.26 | 0.17 | 0.18 | 0.61 |
| WFP | 0.06 | 0.13 | 0.39 | 0.59 |
| Germany | - | - | 0.21 | 0.21 |
| Ireland | - | - | 0.20 | 0.20 |
| UK | - | - | 0.15 | 0.15 |
| UNICEF | 0.005 | 0.005 | 0.005 | 0.015 |
| **សរុប** | **12.26** | **8.11** | **8.21** | **28.60** |

តារាងទី ៥.៧ បង្ហាញថា នៅចន្លោះឆ្នាំ២០១៩-២០២១ វិស័យកសិកម្មបានបញ្ជ្រាបវិស័យប្រែប្រួលអាកាសធាតុច្រើនជាងគេប្រមាណជាង ៥០% នៃធនធានសរុបសម្រាប់វិស័យនេះ ។ ក្នុងឆ្នាំ២០២១ ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្មមានហិរញ្ញប្បទានទំហំ ១៤៦,៣៣ លានដុល្លារ ស្មើនឹង ៥៧% នៃ

ហិរញ្ញប្បទានសរុបគាំទ្រវិស័យកសិកម្ម ។ វិស័យនគូបនីយកម្ម និងការគ្រប់គ្រង និងវិស័យថាមពល និងអគ្គិសនីជាវិស័យទី ២ និងទី ៣ ដែលទទួលបានហិរញ្ញប្បទានបញ្ជ្រាបការប្រែប្រួលអាកាសធាតុប្រមាណ ៣០% ។ ហិរញ្ញប្បទាន ១៩០ លានដុល្លារ ដែលបានផ្ដល់សម្រាប់វិស័យថាមពល និងអគ្គិសនី ក្នុងនោះ ហិរញ្ញ-ប្បទានចំនួន ៦០ លានដុល្លារ ត្រូវបានផ្ដល់សម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ ។ វិស័យទេសចរណ៍ និងសហគមន៍ និងសុខុមាលភាពសង្គម ទទួលបានហិរញ្ញប្បទានបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ត្រឹមតែ ១% ក្នុងរយៈពេលដូចគ្នា ។

**តារាងទី ៥.៧ : ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុតាមវិស័យ ឆ្នាំ២០១៩-២០២១ (លានដុល្លារ)**

| វិស័យ | ២០១៩ | ២០២០ | ២០២១ ប៉ាន់ស្មាន | | | | ធនធានតាមវិស័យឆ្នាំ ២០២១ | ប្រែប្រួលអាកាសធាតុ (%នៃធនធានតាមវិស័យ) |
|---|---|---|---|---|---|---|---|---|
| | | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |
| កសិកម្ម | 173.66 | 137.4 | 19.10 | 106.81 | 20.41 | 146.33 | 254.69 | 57.45% |
| នគូបនីយកម្ម និងការគ្រប់គ្រង | 20.94 | 29.60 | 7.17 | 7.58 | 0.40 | 15.16 | 48.14 | 31.48% |
| ថាមពល និងអគ្គិសនី | 75.42 | 87.80 | 57.65 | 1.47 | 0.81 | 59.95 | 190.77 | 31.42% |
| បរិស្ថាន និងអភិរក្ស | 18.25 | 14.53 | 0.79 | 2.70 | 5.99 | 9.49 | 33.34 | 28.46% |
| ទឹកស្អាត និងអនាម័យ | 59.67 | 7.74 | 1.06 | 40.31 | 4.22 | 45.6 | 178.31 | 25.57% |
| ការគាំពារសង្គម | - | 0.01 | 0.13 | 0.08 | 1.91 | 2.12 | 9.21 | 22.99% |
| ការអភិវឌ្ឍជនបទ | 7.02 | 7.77 | 0.29 | 8.13 | 7.62 | 16.06 | 95.46 | 16.82% |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | 0.06 | 0.02 | - | 1.15 | - | 1.16 | 11.02 | 10.52% |
| សេវាធនាគារ និងធុរកិច្ច | 0.17 | 0.16 | 0.12 | 0.15 | - | 0.27 | 2.97 | 9.07% |
| វប្បធម៌ សិល្បៈ និងកីឡា | 1.82 | 1.84 | - | 1.84 | - | 1.85 | 22.28 | 8.30% |
| ជំនួយសង្គ្រោះបន្ទាន់ និងស្បៀងអាហារ | 0.116 | 0.22 | 0.48 | - | 0.25 | 0.73 | 9.16 | 7.96% |
| ដឹកជញ្ជូន | 36.38 | 27.52 | 8.96 | 20.74 | 0.43 | 30.14 | 444.45 | 6.78% |
| យេនឌ័រ | 0.50 | 0.25 | 0.43 | - | - | 0.44 | 6.59 | 6.67% |
| អប់រំ | 15.04 | 21.50 | 9.59 | 1.79 | 1.05 | 12.44 | 192.38 | 6.46% |
| អភិបាលកិច្ច និងរដ្ឋបាល | 5.12 | 10.32 | 2.71 | 1.57 | 0.36 | 4.66 | 88.70 | 5.25% |
| ផ្សេងៗ | 0.57 | 1.99 | 0.75 | 1.22 | - | 1.98 | 41.59 | 4.75% |
| សុខាភិបាល | 10.30 | 22.97 | 11.55 | 2.38 | - | 13.93 | 315.11 | 4.42% |
| ទេសចរណ៍ | - | 0.07 | 0.08 | - | - | 0.09 | 6.48 | 1.38% |
| សហគមន៍ & សុខុមាលភាពសង្គម | 0.81 | 0.19 | 0.01 | 0.01 | - | 0.03 | 74.67 | 0.04% |
| សរុប | 425.94 | 371.67 | 120.93 | 198.01 | 43.48 | 362.43 | 2,025.40 | 17.89% |

តារាងទី ៥.៨ បង្ហាញថា ក្នុងចន្លោះឆ្នាំ២០១៩-២០២១ ដៃគូអភិវឌ្ឍន៍ចំនួន ២៩ បានគាំទ្រដល់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ។ ក្នុងឆ្នាំ២០២១ ហិរញ្ញប្បទានទំហំ ១៨% នៃហិរញ្ញប្បទានសរុបត្រូវបានបើកផ្ដល់ សម្រាប់គាំទ្រការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ។ ធនាគារពិភពលោក, បារាំង, អៀរឡង់, WHO, IAEA, ធនាគារអភិវឌ្ឍន៍អាស៊ី, UNICEF, UNDP, សាធារណរដ្ឋប្រជាមានិតចិន, IFAD និង UN Women បានផ្ដល់ហិរញ្ញប្បទានប្រមាណ ២០% នៃហិរញ្ញប្បទានសរុបរបស់ខ្លួនសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ ។ សាធារណរដ្ឋប្រជាមានិតចិន និងធនាគារអភិវឌ្ឍន៍អាស៊ី គឺជាដៃគូដែលផ្ដល់ហិរញ្ញប្បទាន

ច្រើនជាងគេ ក្នុងទំហំ ៨០,៨៣ លានដុល្លារ និង៦៥,២៥ លានដុល្លារ នៃហិរញ្ញប្បទានសរុបរបស់ខ្លួនក្នុងឆ្នាំ២០២១ សម្រាប់បញ្ច្រាបការប្រែប្រួលអាកាសធាតុ ។

**តារាងទី ៥.៨ : ការបញ្ច្រាបការប្រែប្រួលអាកាសធាតុរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៩-២០២១ (លានដុល្លារ)**

| ដៃគូអភិវឌ្ឍន៍ | ២០១៩ | ២០២០ | ២០២១ ប៉ាន់ស្មាន | | | | ធនធានរបស់ដៃគូអភិវឌ្ឍន៍ឆ្នាំ២០២១ | ការប្រែប្រួលអាកាសធាតុ (% នៃធនធានរបស់ដៃគូអភិវឌ្ឍន៍) |
|---|---|---|---|---|---|---|---|---|
| | | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |
| World Bank | 34.35 | 37.61 | 4.27 | 20.27 | 7.03 | 31.58 | 87.39 | 36.13% |
| France | 78.30 | 21.44 | 0.71 | 38.73 | 0.63 | 40.09 | 117.37 | 34.15% |
| Ireland | - | - | - | 0.53 | - | 0.53 | 1.57 | 33.92% |
| WHO | 0.54 | 3.19 | 4.02 | - | - | 4.02 | 12.07 | 33.33% |
| IAEA | - | 0.2 | 0.13 | 0.15 | - | 0.28 | 0.86 | 33.03% |
| ADB | 96.06 | 66.13 | - | 53.50 | 11.75 | 65.25 | 204.83 | 31.85% |
| Republic of Korea | 11.83 | 13.74 | 8.86 | 28.06 | 0.45 | 37.38 | 119.77 | 31.21% |
| UNICEF | 4.46 | 8.88 | 7.49 | 1.53 | - | 9.03 | 29.42 | 30.70% |
| UNDP | 2.09 | 1.74 | 0.26 | 0.92 | 1.04 | 2.24 | 9.51 | 23.56% |
| China | 120.45 | 125.22 | 56.83 | 24 | - | 80.83 | 343.14 | 23.55% |
| IFAD | 3 | 4.53 | - | - | 3.28 | 3.28 | 14.73 | 22.27% |
| UN Women | - | - | 0.19 | - | - | 0.19 | 0.95 | 20.25% |
| Germany | 4.03 | 5.94 | 7.21 | 0.92 | 0.79 | 8.93 | 44.83 | 19.92% |
| FAO | 1.35 | 0.37 | 0.04 | 0.11 | 0.18 | 0.34 | 1.98 | 17.59% |
| New Zealand | 0.27 | 0.22 | - | 1.305 | - | 1.30 | 8.59 | 15.19% |
| USA | 11.05 | 13.29 | 6.30 | 6.41 | 3.864 | 16.57 | 112.11 | 14.78% |
| EU/EC | 10.28 | 2.51 | 2.95 | 4.94 | 2.67 | 10.57 | 76.90 | 13.75% |
| Japan | 32.02 | 55.94 | 16.14 | 12.74 | 11.41 | 40.29 | 400.58 | 10.05% |
| ILO | 0.11 | 0.01 | 0.47 | - | - | 0.47 | 4.89 | 9.62% |
| Australia | 9.23 | 4.89 | 2.93 | 2.90 | - | 5.84 | 66.47 | 8.78% |
| Switzerland | 1.14 | 1.79 | 0.96 | 0.47 | - | 1.43 | 17.11 | 8.37% |
| WFP | 2.08 | 0.73 | 0.41 | - | 0.25 | 0.66 | 8.09 | 8.15% |
| UK | 0.09 | 0.13 | 0.15 | 0.07 | - | 0.22 | 3.41 | 6.64% |
| Canada | 0.28 | 0.12 | 0.17 | 0.01 | - | 0.18 | 2.93 | 6.40% |
| UNIDO | 0.16 | 0.07 | 0.05 | - | 0.05 | 0.10 | 2.29 | 4.40% |
| UNFPA | 0.07 | 0.18 | 0.13 | - | - | 0.13 | 3.4 | 3.82% |
| Czech Republic | 0.22 | 0.07 | - | 0.08 | - | 0.08 | 2.73 | 3.22% |
| UNESCO | 0.03 | 0.04 | - | 0.11 | - | 0.11 | 3.69 | 3.14% |
| Sweden | 2.34 | 2.56 | 0.17 | 0.17 | 0.04 | 0.39 | 22.46 | 1.74% |
| Others | - | - | - | - | - | - | 301.02 | 0% |
| **សរុប** | **425.94** | **371.67** | **120.93** | **198.01** | **43.48** | **362.43** | **2,025.40** | **17.89%** |

***ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការអភិវឌ្ឍវិស័យឯកជន***

ការអភិវឌ្ឍវិស័យឯកជន នៅតែជាអាទិភាពរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ ។ តារាងទី ៥.៩ បង្ហាញថា ក្នុងឆ្នាំ២០២១ ហិរញ្ញប្បទាន ៦៩៣ លានដុល្លារ ស្មើនឹង ៣៤,២៥% នៃហិរញ្ញប្បទានសរុប បានបញ្ច្រាបការអភិវឌ្ឍវិស័យឯកជន ពោលគឺកើន ជាមធ្យមចំនួន ១៣% ។ វិស័យចំនួន ២ គឺ វិស័យដឹកជញ្ជូន និងថាមពល និងវិស័យអគ្គិសនី ទទួលបានហិរញ្ញប្បទានបញ្ច្រាបការអភិវឌ្ឍវិស័យឯកជនច្រើនជាងគេ ទំហំ ៤៨៣,៤២ លានដុល្លារ ស្មើនឹង ៦៩% នៃធនធានសរុបឆ្នាំ២០២១ សម្រាប់បញ្ច្រាបការអភិវឌ្ឍវិស័យឯកជន ។ សាធារណរដ្ឋប្រជាមានិតចិន និងជប៉ុន បានបញ្ច្រាបការគាំទ្ររបស់ខ្លួនដល់ការអភិវឌ្ឍវិស័យឯកជនច្រើនជាងគេ ក្នុងវិស័យហេដ្ឋា-

វចនាសម្ព័ន្ធវិស័យដឹកជញ្ជូន និងវិស័យថាមពល និងអគ្គិសនី ឆ្នាំ២០២១ ។ លើសពីនេះ វិស័យចំនួន ៣ រួមមាន ÷ វិស័យកម្មន្តសាល, រ៉ែ និងពាណិជ្ជកម្ម, វិស័យទេសចរណ៍ និងសេវាធនាគារ និងធុរកិច្ច ក៏បានគាំទ្រដល់ការបញ្ជ្រាបការអភិវឌ្ឍវិស័យឯកជនច្រើន ។

**តារាងទី ៥.៩ : ការបញ្ជ្រាបការអភិវឌ្ឍវិស័យឯកជនតាមវិស័យ ឆ្នាំ២០១៩-២០២១ (លានដុល្លារ)**

| វិស័យ | ២០១៩ | ២០២០ | ២០២១ ប៉ាន់ស្មាន | | | | ធនធានតាមវិស័យ ឆ្នាំ២០២១ | ការអភិវឌ្ឍវិស័យឯកជន (% នៃធនធានតាមវិស័យ) |
|---|---|---|---|---|---|---|---|---|
| | | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |
| ដឹកជញ្ជូន | 314.23 | 329.77 | 1.00 | 355.50 | 1.00 | 357.51 | 444.45 | 80.43% |
| ថាមពល និងអគ្គិសនី | 115.01 | 130.93 | 0.87 | 124.03 | 1.00 | 125.91 | 190.77 | 66% |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | 5.75 | 3.61 | 1.06 | 1.82 | 2.98 | 5.88 | 11.02 | 53.35% |
| ទេសចរណ៍ | 3.66 | 2.37 | - | 3.01 | 0.18 | 3.2 | 6.48 | 49.32% |
| សេវាធនាគារ និងធុរកិច្ច | 1.8 | 0.63 | - | 0.12 | 1.22 | 1.35 | 2.97 | 45.41% |
| គាំពារសង្គម | 0.98 | 1.16 | 3.55 | 0.08 | 0.12 | 3.75 | 9.21 | 40.77% |
| យេនឌ័រ | 0.82 | 2.42 | 2.19 | - | - | 2.19 | 6.59 | 33.23% |
| ការប្រែប្រួលអាកាសធាតុ | 2.5 | 2.03 | 1.15 | 1.48 | 0.1 | 2.74 | 8.28 | 33.07% |
| ការអភិវឌ្ឍជនបទ | 24.75 | 13.01 | 11.62 | 10.21 | 5.2 | 27.04 | 95.46 | 28.32% |
| ទឹកស្អាត និងអនាម័យ | 9.76 | 7.77 | 38.02 | 2.16 | 4.22 | 44.4 | 178.31 | 24.9% |
| នគរូបនីយកម្ម និងការគ្រប់គ្រង | 15.97 | 9.58 | 6.12 | 1.45 | 0.4 | 7.98 | 48.14 | 16.58% |
| អភិបាលកិច្ច និងរដ្ឋបាល | 7.82 | 17.31 | 6.61 | 7.74 | 0.03 | 14.39 | 88.70 | 16.23% |
| បរិស្ថាន និងអភិរក្ស | 6.14 | 5.89 | 2.11 | 2.56 | 0.68 | 5.37 | 33.34 | 16.11% |
| កសិកម្ម | 69.45 | 38.73 | 12.52 | 14.93 | 12.85 | 40.32 | 254.69 | 15.83% |
| អប់រំ | 17.63 | 24.38 | 2.62 | 20.19 | 3.91 | 26.73 | 192.38 | 13.89% |
| សហគមន៍ & សុខុមាលភាពសង្គម | 4.04 | 7.08 | 2.03 | 2.96 | 1.56 | 6.56 | 74.67 | 8.78% |
| ផ្សេងៗ | 6.34 | 2.06 | 1.39 | 0.13 | 0.42 | 1.95 | 24.33 | 8.01% |
| ជំនួយសង្គ្រោះបន្ទាន់ និងស្បៀងអាហារ | 0.11 | 0.23 | 0.73 | - | - | 0.73 | 9.16 | 7.99% |
| វប្បធម៌ និងសិល្បៈ | 1.81 | 1.11 | 1.33 | - | - | 1.33 | 22.28 | 6% |
| សុខាភិបាល | 9.09 | 10.71 | 9.09 | 4.99 | - | 14.09 | 315.11 | 4.47% |
| ព័ត៌មានវិទ្យា និងទំនាក់ទំនង | 0.04 | 0.03 | 0.01 | 0.21 | - | 0.22 | 8.96 | 2.5% |
| **សរុប** | **617.79** | **610.90** | **104.11** | **553.64** | **35.95** | **693.71** | **2,025.40** | **34.25%** |

តារាងទី ៥.១០ បង្ហាញថា ដៃគូអភិវឌ្ឍន៍ចំនួន ២៧ បានគាំទ្រដល់ការបញ្ជ្រាបការអភិវឌ្ឍវិស័យឯកជន ។ ជប៉ុន, សាធារណរដ្ឋប្រជាមានិតចិន, ILO និង IFAD បានផ្តល់ហិរញ្ញប្បទានគាំទ្រការបញ្ជ្រាបការអភិវឌ្ឍវិស័យឯកជនទៅក្នុងគម្រោងរបស់ខ្លួនច្រើនជាងគេ ។ សាធារណរដ្ឋប្រជាមានិតចិន និងជប៉ុន បានគាំទ្រដល់ការបញ្ជ្រាបការអភិវឌ្ឍវិស័យឯកជនប្រមាណ ៦៣% នៃហិរញ្ញប្បទានរបស់ខ្លួន ក្នុងឆ្នាំ២០២១ ។

## តារាងទី ៥.១០: ការបញ្ជ្រាបការអភិវឌ្ឍវិស័យឯកជនរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៩-២០២១ (លានដុល្លារ)

| ដៃគូអភិវឌ្ឍន៍ | ២០១៩ | ២០២០ | ២០២១ ប៉ាន់ស្មាន | | | | ធនធានរបស់ដៃគូអភិវឌ្ឍន៍ឆ្នាំ ២០២១ | ការអភិវឌ្ឍវិស័យឯកជន (% នៃធនធានរបស់ដៃគូអភិវឌ្ឍន៍) |
|---|---|---|---|---|---|---|---|---|
| | | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |
| UNIDO | 0.73 | 0.44 | - | 1.53 | 0.09 | 1.63 | 2.29 | 71.12% |
| Japan | 84.25 | 120.89 | - | 265.93 | 0.34 | 266.28 | 400.58 | 66.47% |
| China | 308.29 | 295.12 | - | 206.45 | | 206.45 | 343.14 | 60.16% |
| ILO | 1.72 | 1.49 | 0.38 | 0.08 | 1.68 | 2.15 | 4.89 | 44.07% |
| IFAD | 4.68 | 6.62 | - | 3.28 | 2.44 | 5.72 | 14.73 | 38.85% |
| New Zealand | 2.21 | 1.65 | 1.53 | 0.86 | 0.70 | 3.09 | 8.59 | 36.04% |
| WHO | 0.54 | 3.19 | 4.02 | - | - | 4.02 | 12.07 | 33.33% |
| France | 71.70 | 40.77 | 37.43 | 0.50 | 0.71 | 38.64 | 117.37 | 32.92% |
| USA | 25.85 | 28.33 | 9.44 | 17.50 | 8.87 | 35.82 | 112.11 | 31.95% |
| UNICEF | 4.55 | 5.15 | 3.92 | 4.48 | | 8.40 | 29.42 | 28.56% |
| UNDP | 3.11 | 2.32 | 0.41 | 1.51 | 0.65 | 2.58 | 9.51 | 27.13% |
| ADB | 58.46 | 57.62 | 9.50 | 40.91 | 4.64 | 55.06 | 204.83 | 26.88% |
| IAEA | - | 0.22 | 0.08 | 0.06 | 0.07 | 0.22 | 0.86 | 26.42% |
| EU/EC | 9.50 | 13.68 | 14.12 | | 6.03 | 20.16 | 76.90 | 26.21% |
| Australia | 13.83 | 12.73 | 7.38 | 3.10 | 3.77 | 14.26 | 66.47 | 21.45% |
| Germany | 5.63 | 6.53 | 3.06 | 2.60 | 2.27 | 7.95 | 44.83 | 17.73% |
| Switzerland | 4.14 | 2.46 | 0.37 | 1.96 | 0.36 | 2.70 | 17.11 | 15.79% |
| UNESCO | 0.52 | 0.27 | 0.48 | - | - | 0.48 | 3.69 | 13.21% |
| Czech Republic | 0.25 | 0.62 | 0.26 | 0.08 | - | 0.35 | 2.73 | 13.11% |
| WFP | 2.11 | 0.79 | 0.44 | 0.41 | - | 0.85 | 8.09 | 10.6% |
| Sweden | 1.59 | 2.04 | 0.99 | 1.26 | - | 2.26 | 22.46 | 10.06% |
| Republic of Korea | 13.18 | 5.42 | 9.99 | - | - | 9.99 | 119.77 | 8.34% |
| World Bank | 0.16 | 1.93 | - | 1.00 | 3.15 | 4.15 | 87.39 | 4.74% |
| UNFPA | 0.03 | 0.10 | 0.15 | | | 0.15 | 3.40 | 4.52% |
| Canada | 0.42 | 0.31 | - | | 0.13 | 0.13 | 2.93 | 4.5% |
| FAO | 0.01 | 0.04 | 0.01 | 0.04 | - | 0.05 | 1.98 | 2.62% |
| UK | 0.23 | 0.05 | 0.05 | 0.02 | - | 0.07 | 3.41 | 2.16% |
| Others | - | | - | - | - | - | 303.73 | 0.% |
| **សរុប** | **617.79** | **610.90** | **104.10** | **553.64** | **35.95** | **693.71** | **2,025.40** | **34.25%** |

# ជំពូក ៦

## តួនាទីហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការគាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា

ឈរលើទស្សនវិស័យវែងឆ្ងាយឆ្ពោះទៅឆ្នាំ២០៣០ និង២០៥០, រាជរដ្ឋាភិបាលបានអនុម័ត និងកំពុងអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥ (IDP) ដែលជាយុទ្ធសាស្ត្រកំណើនថ្មីដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម និងរក្សាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈការធ្វើឱ្យប្រសើរឡើងនូវពិពិធកម្មសេដ្ឋកិច្ច, ការពង្រឹងសមត្ថភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាពដើម្បីឈានទៅសម្រេចការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងស្រុក និងការធ្វើសមាហរណកម្មស៊ីជម្រៅទៅក្នុងនិម្មាបនកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក ។

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល, បណ្តាក្រសួង និងស្ថាប័នបាន និងកំពុងអនុវត្តវិធានការគោលនយោបាយ និងផែនការសកម្មភាព ដែលបានកំណត់ក្នុងគោលនយោបាយ IDP ។ នៅឆ្នាំ២០២១ ការវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តគោលនយោបាយ IDP ត្រូវបានរៀបចំដើម្បីវាយតម្លៃវឌ្ឍនភាព និងបច្ច័យនៃការអនុវត្តសម្រាប់ឆ្នាំ២០១៥-២០២០ និងផ្តល់អនុសាសន៍គោលនយោបាយ ដើម្បីធ្វើឱ្យប្រសើរឡើង និងពន្លឿនការអនុវត្តនៅដំណាក់កាលបន្ទាប់ ។ លទ្ធផលនៃការវាយតម្លៃបានបង្ហាញថា ការអនុវត្តផែនការសកម្មភាព, វិធានការគោលនយោបាយ ក៏ដូចជាវិធានការគន្លឹះបួនជាក់ស្តែង សម្រេចវឌ្ឍនភាពល្អប្រសើរ ធៀបនឹងចំណុចដៅនៃគោលនយោបាយ ។ ជាក់ស្តែង សេដ្ឋកិច្ចកម្ពុជាបានផ្លាស់ប្តូររចនាសម្ព័ន្ធ ដោយសារចំណែកនៃវិស័យឧស្សាហកម្មក្នុង ផ.ស.ស. បានកើនពី ២៧,៧% ក្នុងឆ្នាំ២០១៥ ដល់ ៣៤,២% ក្នុងឆ្នាំ២០១៩ ខ្ពស់ជាងគោលដៅឆ្នាំ២០២៥ (៣០%) ។ ទោះជាយ៉ាងនេះក្តី សមិទ្ធកម្មនៃវិស័យកម្មន្តសាលហាក់មិនទាន់មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ឡើយ ។

### *តួនាទីហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា*

ហិរញ្ញប្បទានសហប្រតិបត្តិការ ដើរតួនាទីជាកាតាលីករក្នុងការកៀរគរប្រភពធនធានដទៃទៀតសម្រាប់គាំទ្រការអនុវត្តគោលនយោបាយ IDP និងវិស័យអាទិភាព រួមមាន ÷ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធភ័ស្តុភារកម្ម, កិច្ចសម្រួលពាណិជ្ជកម្ម និងការលើកកម្ពស់ភាពប្រកួតប្រជែងសេដ្ឋកិច្ច, ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម, ការពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍធនធានមនុស្ស ក៏ដូចជាការអភិវឌ្ឍជំនាញ ។ ក្នុងន័យនេះ ហិរញ្ញប្បទាននឹងជួយបង្កើតបរិស្ថានអំណោយផលសម្រាប់វិនិយោគឯកជន ដែលជំរុញការវិនិយោគ និងការបង្កើនសកម្មភាពឧស្សាហកម្ម។

ដោយឃើញពីតួនាទីសំខាន់នៃហិរញ្ញប្បទានសហប្រតិបត្តិការ, ផ្អែកតាមទិន្នន័យដែលដៃគូអភិវឌ្ឍន៍បានផ្តល់ក្នុងប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានតាមដានយ៉ាងទៀងទាត់ និងបានវិភាគអំពីលំហូរហិរញ្ញប្បទានសម្រាប់គាំទ្រគោលនយោបាយ IDP សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយ និងជាឯកសារយោងសម្រាប់កិច្ចពិគ្រោះយោបល់ភាពជាដៃគូ ។

*ការវិភាគហិរញ្ញប្បទានគាំទ្រគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា*

តារាងទី ៦.១ បង្ហាញថា ក្នុងឆ្នាំ២០១៩ ហិរញ្ញប្បទានទំហំ ៣០០,៣ លានដុល្លារ ស្មើនឹង ១៧,៦% នៃហិរញ្ញប្បទានសរុប (មិនរាប់បញ្ចូលធនធានរបស់អង្គការមិនមែនរដ្ឋាភិបាល) ត្រូវបានបើកផ្តល់សម្រាប់គាំទ្រវិធានការគន្លឹះបួនជាក់ស្តែង, វិធានការគោលនយោបាយ និងផែនការសកម្មភាព នៃគោលនយោបាយ IDP ។ ក្នុងឆ្នាំ២០២០ ការបើកផ្តល់ហិរញ្ញប្បទានមានទំហំ ៣១៨,៣ លានដុល្លារ ពោលគឺកើនប្រមាណ ៦% ធៀបនឹងឆ្នាំ២០១៩ ។ ការបើកផ្តល់ហិរញ្ញប្បទានក្នុងឆ្នាំ២០២១ ត្រូវបានប៉ាន់ស្មានថាមានទំហំ ៣០៦,១ លានដុល្លារ ហើយធនធានប្រហែល ២/៣ បានគាំទ្រដល់ការអនុវត្តវិធានការគន្លឹះបួនជាក់ស្តែង ក្នុងនោះ ធនធាន ១៩០,៧ លានដុល្លារ បានគាំទ្រវិស័យថាមពល(គាំទ្រភាគច្រើនដោយសាធារណរដ្ឋប្រជាមានិតចិន និងជប៉ុន) ។

**តារាងទី ៦.១ : ហិរញ្ញប្បទានគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា**

**ឆ្នាំ២០១៨-២០១៩ (លានដុល្លារ)**

| ដៃគូអភិវឌ្ឍន៍ | ២០១៩ | ២០២០ | ២០២១ | | | | | | ២០១៩-២០២១ |
|---|---|---|---|---|---|---|---|---|---|
| | | | ការជំរុញការទាក់ទាញវិនិយោគ | ការពង្រីកសហគ្រាសធុនតូច និងមធ្យម | ការកែលម្អបរិស្ថាននិយ័តកម្ម | ការសម្របសម្រួលគោលនយោបាយគាំទ្រ | វិធានការគន្លឹះបួនជាក់ស្តែង | ២០២១ | |
| សាធារណរដ្ឋប្រជាមានិតចិន | 147.1 | 147.5 | - | - | - | - | 113.68 | 113.7 | 408.3 |
| ជប៉ុន | 19.2 | 28.8 | 12.2 | - | - | 13.47 | 67.20 | 92.9 | 140.9 |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 51.6 | 29.7 | 21.7 | - | - | 21.1 | 1.17 | 43.9 | 125.2 |
| បារាំង | 39.9 | 70.6 | - | - | - | 1.1 | 1.05 | 2.2 | 112.7 |
| អូស្ត្រាលី | 10.0 | 7.4 | - | - | - | 5.5 | 2.43 | 7.9 | 25.3 |
| ធនាគារពិភពលោក | 6.7 | 7.6 | - | - | - | 8.09 | - | 8.1 | 22.4 |
| សាធារណរដ្ឋកូរ៉េ | 5.9 | 7.3 | - | 0.3 | 0.1 | 2.18 | 5.67 | 8.3 | 21.5 |
| សហភាពអឺរ៉ុប | 5.2 | 3.9 | 0.2 | - | 3.65 | - | 1.73 | 5.6 | 14.7 |
| អាល្លឺម៉ង់ | 3.8 | 3.1 | - | 1.3 | 4.2 | - | 0.59 | 6.0 | 12.9 |
| មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម | 2.2 | 4.0 | - | 4.9 | - | - | - | 4.9 | 11.1 |
| សហរដ្ឋអាមេរិក | 0.8 | 1.5 | - | 1 | 0.45 | 3.5 | 0.02 | 5.0 | 7.3 |
| ស្វីស | 2.3 | 1.8 | - | - | 0.01 | 2.52 | - | 2.5 | 6.6 |
| នូវែលសេឡង់ | 2.1 | 1.5 | - | - | - | - | - | - | 3.6 |
| ស៊ុយអែត | 0.6 | 1.2 | - | - | - | 0.93 | - | 0.9 | 2.7 |
| កាណាដា | 1.0 | 0.9 | - | 0.1 | 0.3 | 0.26 | - | 0.7 | 2.6 |
| សាធារណរដ្ឋឆែក | 0.3 | 0.5 | - | 0.1 | - | 1.05 | 0.07 | 1.2 | 2 |
| អង្គការយូនីដូ | 0.5 | 0.5 | 0.4 | 0.1 | - | 0.18 | - | 0.7 | 1.7 |
| អង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍ | 0.4 | 0.4 | - | 0.25 | 0.19 | - | 0.15 | 0.6 | 1.4 |
| អង្គការពលកម្មអន្តរជាតិ | 0.2 | 0.04 | - | - | - | 0.45 | - | 0.5 | 0.7 |
| ចក្រភពអង់គ្លេស | 0.2 | 0.02 | - | - | - | 0.4 | - | 0.4 | 0.6 |
| IAEA | - | 0.25 | - | 0.1 | - | - | 0.11 | 0.2 | 0.5 |
| ***សរុប*** | **300.3** | **318.3** | **34.5** | **8.1** | **8.82** | **60.84** | **193.86** | **306.1** | **924.7** |

ពិនិត្យជារួម, ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការបានបង្ហាញថា ដៃគូអភិវឌ្ឍន៍ ចំនួន ២១ បានគាំទ្រការអនុវត្តគោលនយោបាយ IDP ក្នុងចន្លោះឆ្នាំ២០១៩-២០២១ ។ ដៃគូអភិវឌ្ឍន៍ដែលផ្តល់ធនធានច្រើនជាងគេ រួមមាន÷ សាធារណប្រជាមានិតចិន, ជប៉ុន, ធនាគារអភិវឌ្ឍន៍អាស៊ី, បារាំង និងអូស្ត្រាលី ហើយដៃគូភាគច្រើន បាន និងកំពុងគាំទ្រការសម្របសម្រួលគោលនយោបាយគាំទ្រ ដូចជា ការអភិវឌ្ឍធនធានមនុស្ស, វិទ្យាសាស្ត្រ, បច្ចេកវិទ្យា និងការបង្កើននវានុវត្តន៍ ។ ក្នុងឆ្នាំ២០២១ ដៃគូអភិវឌ្ឍន៍ ៤ រួមមាន ÷ ធនាគារអភិវឌ្ឍន៍អាស៊ី, ជប៉ុន, អង្គការយូនីដូ និងសហភាពអឺរ៉ុប បានផ្តល់ហិរញ្ញប្បទាន ៣៤,៥ លានដុល្លារ សម្រាប់គាំទ្រដល់ការជំរុញការវិនិយោគ ។

តារាងទី ៦.២ បង្ហាញថា ក្នុងចន្លោះឆ្នាំ២០១៥-២០២២ ហិរញ្ញប្បទានទំហំ ១ ៧៩៩,២ លានដុល្លារ ពោលគឺប្រមាណ ២២៥ លានដុល្លារ ក្នុងមួយឆ្នាំ បានគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ។ វិធានការគន្លឹះបួនជាក់ស្តែង ទទួលបានការគាំទ្រច្រើនជាងគេ ក្នុងទំហំ ១ ២២០,៥ លានដុល្លារ ខណៈដែលវិធានការគោលនយោបាយស្តីពីការពង្រីកសហគ្រាសធុនតូច និងមធ្យម ទទួលបានការគាំទ្រត្រឹមតែ ប្រមាណ ៤៨,៨ លានដុល្លារ សមមូលនឹង ៣% នៃហិរញ្ញប្បទានសរុបគាំទ្រគោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា សម្រាប់ឆ្នាំ២០១៥-២០២២ ។

**តារាងទី ៦.២ : ធនធានរយៈពេលមធ្យមសម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា *(លានដុល្លារ)***

| វិធានការគោលនយោបាយ និងវិធានការគន្លឹះ បួនជាក់ស្តែង | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ ប៉ាន់ស្មាន | ២០២២ ព្យាករណ៍ | សរុប |
|---|---|---|---|---|---|---|---|---|---|
| ការជំរុញការទាក់ទាញវិនិយោគ | 0.2 | 3.3 | 1.8 | 2.3 | 47.6 | 15.3 | 34.5 | 40.7 | 145.7 |
| ការពង្រីក និងទំនើបកម្ម សហគ្រាសធុនតូច និងមធ្យម | 1.1 | 1.7 | 3.6 | 3.9 | 7.3 | 7.0 | 8.1 | 16.0 | 48.8 |
| ការកែលម្អបរិស្ថាននិយ័តកម្ម | 4.3 | 9.0 | 25.9 | 9.2 | 8.3 | 5.0 | 8.8 | 8.0 | 78.5 |
| ការសម្របសម្រួលគោលនយោបាយគាំទ្រ | 27.4 | 22.2 | 28.2 | 29.3 | 35.3 | 52.8 | 60.8 | 49.7 | 305.7 |
| វិធានការគន្លឹះបួនជាក់ស្តែង | 55.9 | 148.0 | 162.0 | 104.8 | 201.9 | 238.2 | 193.8 | 115.9 | 1 220.5 |
| **សរុប** | **88.9** | **184.2** | **221.4** | **149.5** | **300.3** | **318.3** | **306.1** | **230.4** | **1 799.2** |

តារាងទី ៦.៣ បង្ហាញថា សាធារណរដ្ឋប្រជាមានិតចិន, ជប៉ុន, ធនាគារអភិវឌ្ឍន៍អាស៊ី, បារាំង និង អូស្ត្រាលី គឺជាដៃគូអភិវឌ្ឍន៍ដែលបានផ្តល់ហិរញ្ញប្បទានច្រើនជាងគេ សរុប ១ ៥៦៦,២ លានដុល្លារ ស្មើនឹង ៨៧% នៃហិរញ្ញប្បទានសរុបគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា សម្រាប់ឆ្នាំ២០១៥-២០២២។

**តារាងទី ៦.៣ ៖ ធនធានរយៈពេលមធ្យមរបស់ដៃគូអភិវឌ្ឍន៍សម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា *(លានដុល្លារ)***

| ដៃគូអភិវឌ្ឍន៍ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ ប៉ាន់ស្មាន | ២០២២ ព្យាករណ៍ | សរុប |
|---|---|---|---|---|---|---|---|---|---|
| សាធារណរដ្ឋប្រជាមានិតចិន | 45.1 | 122.2 | 133.2 | 54.7 | 147.1 | 147.5 | 113.7 | 42.5 | 805.9 |
| ជប៉ុន | 12.8 | 19.0 | 16.5 | 24.8 | 19.2 | 28.8 | 92.9 | 46.0 | 260.0 |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 11.1 | 9.8 | 19.0 | 22.0 | 51.6 | 29.7 | 43.9 | 51.6 | 238.7 |
| បារាំង | 1.2 | 13.0 | 21.4 | 19.2 | 39.9 | 70.6 | 2.1 | 27.2 | 194.6 |
| អូស្ត្រាលី | 7.3 | 9.5 | 11.4 | 10.5 | 10.0 | 7.4 | 8.0 | 2.9 | 67.0 |
| ធនាគារពិភពលោក | 1.8 | - | - | 0.1 | 6.7 | 7.6 | 8.1 | 16.5 | 40.8 |
| សាធារណរដ្ឋកូរ៉េ | - | 1.1 | 6.3 | 4.9 | 5.9 | 7.3 | 8.3 | 5.2 | 39.1 |
| សហភាពអឺរ៉ុប | 2.8 | 1.7 | 1.3 | 2.5 | 5.2 | 3.9 | 5.6 | 4.6 | 27.6 |
| មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម | - | - | 0.01 | 0.6 | 2.2 | 4.0 | 4.9 | 12.2 | 23.9 |
| អាល្លឺម៉ង់ | - | 1.1 | 2.0 | 1.9 | 3.8 | 3.1 | 6.0 | 5.9 | 23.8 |
| សហរដ្ឋអាមេរិក | 1.2 | 0.8 | 1.0 | 0.3 | 0.8 | 1.5 | 5.0 | 5.5 | 16.0 |
| ស្វីស | 0.5 | 0.8 | 2.0 | 2.5 | 2.3 | 1.8 | 2.5 | 2.3 | 14.8 |
| នូវែលសេឡង់ | 2.6 | 1.9 | 3.1 | 2.2 | 2.1 | 1.5 | - | 0.4 | 13.7 |
| ស៊ុយអែត | 1.1 | 1.3 | 1.2 | 0.9 | 0.6 | 1.2 | 0.9 | 4.2 | 11.3 |
| កាណាដា | 0.1 | 0.4 | 0.5 | 1.1 | 1.0 | 0.9 | 0.7 | 0.7 | 5.5 |
| អង្គការពលកម្មអន្តរជាតិ | 0.9 | 1.0 | 1.0 | 0.4 | 0.2 | 0.04 | 0.5 | 0.4 | 4.3 |
| សាធារណរដ្ឋឆែក | 0.3 | 0.4 | 0.3 | 0.01 | 0.3 | 0.5 | 1.2 | 0.3 | 3.4 |
| អង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍ | - | 0.1 | 0.6 | 0.3 | 0.4 | 0.4 | 0.6 | 0.6 | 2.9 |
| អង្គការយូនីដូ | 0.1 | 0.1 | 0.2 | 0.1 | 0.5 | 0.5 | 0.6 | 0.8 | 2.8 |
| ចក្រភពអង់គ្លេស | - | - | 0.05 | 0.4 | 0.2 | 0.02 | 0.4 | 0.7 | 1.8 |
| IAEA | - | - | - | 0.2 | - | 0.3 | 0.3 | 0.1 | 0.8 |
| អង្គការយូណេស្កូ | - | - | 0.1 | 0.1 | - | - | - | - | 0.2 |
| **សរុប** | **88.9** | **184.2** | **221.4** | **149.5** | **300.3** | **318.3** | **306.1** | **230.4** | **1,799.2** |

***ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងឧត្តមសិក្សា***

ដោយទទួលស្គាល់ពីសារៈសំខាន់នៃការអភិវឌ្ឍនធនធានមនុស្ស និងជំនាញ ក្នុងការគាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្ម, រាជរដ្ឋាភិបាលបានដាក់ចេញ តាមរយៈគោលនយោបាយ IDP នូវវិធានការគោលនយោបាយមួយចំនួន ដើម្បីជំរុញការអភិវឌ្ឍនធនធានមនុស្ស និងជំនាញ ។ ជាមួយគ្នានេះ គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ ត្រូវបានអនុម័តក្នុងខែមិថុនា ឆ្នាំ២០១៧ ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក៏ដូចជាផ្តល់ជាវេទិកាសម្រាប់ភាគីពាក់ព័ន្ធចូលរួមពិភាក្សា និងកៀរគរធនធាន ។

តារាងទី ៦.៤ បង្ហាញថា ក្នុងចន្លោះឆ្នាំ២០១៧-២០២២ ដៃគូអភិវឌ្ឍន៍ចំនួន ១៧ បានបើកផ្តល់ហិរញ្ញប្បទាន ២៥៥,១ លានដុល្លារ ដែលគិតជាមធ្យម ៤២,៥ លានដុល្លារ ក្នុងមួយឆ្នាំ សម្រាប់គាំទ្រវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងឧត្តមសិក្សា ។ ហិរញ្ញប្បទានប្រមាណ ៧៧% នៃហិរញ្ញប្បទាន

សរុប ត្រូវបានបើកផ្តល់ដោយដៃគូអភិវឌ្ឍន៍ចំនួន ៥ គឺ ÷ ធនាគារអភិវឌ្ឍន៍អាស៊ី, ជប៉ុន, ធនាគារពិភពលោក, អូស្ត្រាលី និងបារាំង ។

**តារាងទី ៦.៤ : ធនធានរបស់ដៃគូអភិវឌ្ឍន៍គាំទ្រដល់វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងឧត្តមសិក្សា *(លានដុល្លារ)***

| ដៃគូអភិវឌ្ឍន៍ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ ប៉ាន់ស្មាន | ២០២២ ព្យាករណ៍ | សរុប |
|---|---|---|---|---|---|---|---|
| ធនាគារអភិវឌ្ឍន៍អាស៊ី | 2.1 | 7.9 | 8.3 | 9.6 | 21.1 | 14.1 | 63.1 |
| ជប៉ុន | 5.8 | 5.9 | 5.8 | 4 | 13.4 | 4.5 | 39.4 |
| ធនាគារពិភពលោក | - | 0.1 | 6.7 | 7.5 | 8.1 | 16.5 | 38.9 |
| អូស្ត្រាលី | 7.2 | 6.9 | 5.9 | 4.5 | 5.5 | - | 30 |
| បារាំង | 0.9 | 1 | 0.9 | 20.1 | 1.1 | 0.03 | 24.03 |
| ស៊ុីស | 2.1 | 2.5 | 2.3 | 1.8 | 2.5 | 2.3 | 13.5 |
| សាធារណរដ្ឋកូរ៉េ | 4.2 | 0.4 | 1.1 | 0.9 | 2.2 | 2.7 | 11.5 |
| នូវែលសេឡង់ | 3.1 | 2.2 | 2.1 | 1.5 | - | - | 8.9 |
| ស៊ុយអែត | 1.1 | 0.9 | 0.6 | 1.2 | 0.9 | 4.2 | 8.9 |
| សហរដ្ឋអាមេរិក | 0.2 | 0.2 | 0.3 | 1 | 3.5 | 3.5 | 8.7 |
| កាណាដា | 0.2 | 0.4 | 0.4 | 0.3 | 0.3 | 0.3 | 1.9 |
| សាធារណរដ្ឋឆែក | - | - | 0.3 | 0.4 | 1 | 0.2 | 1.9 |
| អង្គការពលកម្មអន្តរជាតិ | 0.5 | 0.2 | 0.2 | 0.04 | 0.4 | 0.4 | 1.74 |
| ចក្រភពអង់គ្លេស | 0.1 | 0.4 | 0.1 | 0.01 | 0.4 | 0.7 | 1.71 |
| អង្គការយូនីសេហ្វ | - | - | - | 0.01 | 0.2 | 0.3 | 0.51 |
| សហភាពអឺរ៉ុប | 0.2 | 0.07 | - | - | - | - | 0.27 |
| អង្គការយូណេស្កូ | 0.1 | 0.12 | - | - | - | - | 0.22 |
| **សរុប** | **27.8** | **29.1** | **35** | **52.8** | **60.6** | **49.7** | **255.1** |

# ជំពូក ៧

# ការគាំទ្រហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) គឺជាក្របខណ្ឌគោលនយោបាយជាតិដែលបានធ្វើជាតិតូបនីយកម្មលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសកល (គ.អ.ច.) ឆ្នាំ២០៣០ ដោយផ្តោតលើទិដ្ឋភាពសេដ្ឋកិច្ច, សង្គម និងបរិស្ថាន ។ ក្នុងពេលដែល គ.អ.ច. មានគោលដៅសរុបត្រឹម ១៧, គ.អ.ច.ក. មានគោលដៅសរុបចំនួន ១៨ ដោយសារកម្ពុជាបានបញ្ចូលបន្ថែមនូវគោលដៅអាទិភាពមួយទៀតស្តីពីការបោសសម្អាតគ្រាប់មីននៅកម្ពុជា និងមានចំណុចដៅសរុបចំនួន ៨៨ ។

ក្របខណ្ឌ គ.អ.ច.ក. ត្រូវបានធ្វើសមាហរណកម្មទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ (ផ.យ.អ.ជ.) ព្រមទាំងបានផ្សារភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្រថវិកា សម្រាប់ជាមូលដ្ឋានក្នុងការគិតគូរអំពីរបៀបវារៈគោលនយោបាយរយៈពេលវែង សម្រាប់ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងគោលដៅលុបបំបាត់ភាពក្រីក្រ និងកំណត់នូវគន្លងសេដ្ឋកិច្ចឈានឆ្ពោះទៅសម្រេចចក្ខុវិស័យ ឆ្នាំ២០៣០ និង ២០៥០ ។ គ.អ.ច.ក. គឺជាគោលនយោបាយណែនាំ ដែលចូលរួមដល់ការរៀបចំផែនការ, ការអនុវត្តថវិកា, ការអនុវត្តគោលនយោបាយ, ការអនុវត្តថវិកា និងការត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយ សម្រាប់ការធ្វើសេចក្តីសម្រេចចិត្តនានា ។

ដើម្បីសម្រេចបានរបៀបវារៈស្តីពីកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ២០៣០ រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចជូនក្រសួងផែនការ ជាស្ថាប័នបង្គោលក្នុងការដឹកនាំការធ្វើជាតិតូបនីយកម្មនេះ ដោយសង្កត់ធ្ងន់ទៅលើគោលការណ៍ "ការមិនបោះបង់នរណាម្នាក់ឱ្យនៅឯកោ" និងមានការចូលរួមពីគ្រប់ដៃគូពាក់ព័ន្ធដែលបានផ្តល់ហិរញ្ញប្បទានអភិវឌ្ឍន៍ ។ ការវាយតម្លៃការអនុវត្ត គ.អ.ច.ក. តាមរយៈការត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត និងការត្រួតពិនិត្យប្រចាំឆ្នាំ ត្រូវបានរៀបចំឡើង ស្របតាមអភិក្រម "ទូទាំងរាជរដ្ឋាភិបាល" ដោយមានការចូលរួមពីក្រសួង និងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលមូលដ្ឋាន ។

ការត្រួតពិនិត្យបានបង្ហាញអំពីវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការអនុវត្ត គ.អ.ច.ក. ប៉ុន្តែកង្វះខាតធនធាន គឺជាបញ្ហាប្រឈមដែលរាំងស្ទះដល់ការឈានទៅសម្រេចបាន គ.អ.ច.ក. ប្រកបដោយមហិច្ឆតានេះ ។ បញ្ហានេះទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងក្នុងការកៀរគរធនធាន សម្រាប់សម្រួលដល់ការអនុវត្ត គ.អ.ច.ក. ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានបញ្ជាក់អំពីតួនាទីសំខាន់របស់តួអង្គអភិវឌ្ឍន៍ទាំងអស់ ដោយខិតខំរក្សាឱ្យបាននូវកម្រិតហិរញ្ញប្បទានសហប្រតិបត្តិការ និងជំរុញការវិនិយោគឯកជន ក្នុងគោលដៅឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍នៃ គ.អ.ច.ក.។

លើសពីនេះ ការរីករាលដាលនៃជំងឺកូវីដ-១៩ ជាបញ្ហាប្រឈមបន្ថែម ដែលបានប៉ះពាល់ដល់ការអនុវត្ត គ.អ.ច.ក. ចាប់ពីដើមឆ្នាំ ២០២០ មក ។ ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច, ការលុបបំបាត់ភាពក្រីក្រ, ការពង្រឹងវិស័យសុខាភិបាល, ការធានាសុវត្ថិភាពចំនីអាហារ, ការលើកកម្ពស់យេនឌ័រ និងការអប់រំ បានទទួលរងនូវ

ផលប៉ះពាល់ ដែលធ្វើឱ្យវិសមភាព និងយេនឌ័រ មានគម្លាតកាន់តែធំឡើង ។ លើមូលដ្ឋាននេះ ក្រសួងផែនការបានដាក់ចេញនូវគំនិតផ្តួចផ្តើមក្នុងការពិនិត្យ និងកែសម្រួលបញ្ជីចំណុចដៅ និងសូចនាករនៃ គ.អ.ច.ក. ដែលត្រូវឆ្លុះបញ្ចាំងអំពីភាពចាំបាច់របស់រាជរដ្ឋាភិបាល ដើម្បីស្តារសេដ្ឋកិច្ចឡើងវិញក្នុងវិបត្តិកូវីដ-១៩ ក៏ដូចជាឈានឆ្ពោះទៅសម្រេចឱ្យបាននូវរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ២០៣០ ។

*ការគាំទ្រហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា*

ក្នុងអំឡុងវិបត្តិជំងឺកូវីដ-១៩ កំណើនសេដ្ឋកិច្ចកម្ពុជាបានប្រឈមនឹងផលប៉ះពាល់ ទន្ទឹមនឹងការកើនឡើងនៃចំណាយរដ្ឋ សម្រាប់ឆ្លើយតបបន្ទាន់ទៅនឹងជំងឺកូវីដ-១៩ និងស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ បានជះឥទ្ធិពលដល់ធនធាន សម្រាប់អនុវត្តឱ្យបានសម្រេចគោលដៅនានានៃ គ.អ.ច.ក.។ ទោះបីជាសេដ្ឋកិច្ចកម្ពុជានៅបន្តរក្សាបានភាពនឹងនរ, ការវិនិយោគ និងចំណូលសាធារណៈនៅមានភាពល្អប្រសើរ ដែលជាមូលដ្ឋានរឹងមាំសម្រាប់ការអនុវត្ត គ.អ.ច.ក. ។ ទោះបីជាយ៉ាងនេះក្តី ហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ សម្រាប់គាំទ្រដល់ការអនុវត្ត គ.អ.ច.ក. កាន់តែមានសារៈសំខាន់ ។

ទន្ទឹមនឹងតួនាទីដ៏សំខាន់របស់ដៃគូអភិវឌ្ឍន៍ និងតម្រូវការក្នុងការវាស់វែងវឌ្ឍនភាពនៃការអនុវត្ត គ.អ.ច.ក. ក្នុងអំឡុងវិបត្តិជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលបានកែសម្រួលប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ដែលគ្រប់គ្រងដោយ គ.ជ.ន/ក.អ.ក សម្រាប់កត់ត្រាហិរញ្ញប្បទានដែលគាំទ្រដល់ការអនុវត្ត គ.អ.ច.ក. ដែលនេះគឺជាការកែសម្រួលនៃដំណើរការតាមដានការអនុវត្ត គ.អ.ច.ក. ក្នុងបរិការណ៍ប្រែប្រួលសកល ។

តារាងទី ៧.១ បង្ហាញអំពីហិរញ្ញប្បទានសហប្រតិបត្តិការដែលបានគាំទ្រគោលដៅទាំង ១៨ នៃ គ.អ.ច.ក. ពីឆ្នាំ ២០១៩ ដល់ ២០២២ ។ ក្នុងតារាងនេះ គោលដៅទី ៩ "ឧស្សាហកម្ម, នវានុវត្តន៍ និងហេដ្ឋារចនាសម្ព័ន្ធ" ទទួលបានការគាំទ្រច្រើនជាងគេ ជាមធ្យមប្រមាណ ៣៥% នៃហិរញ្ញប្បទានសរុបដែលគាំទ្រ គ.អ.ច.ក ។ ចំណែកឯគោលដៅទី ៣ "សុខភាពល្អ និងសុខុមាលភាព" ទទួលបានធនធានច្រើនលំដាប់ទី ២ ចំនួន ១៦% ។ ប្រការនេះបង្ហាញអំពីការតម្រឹមធនធានរបស់ដៃគូអភិវឌ្ឍន៍ជាមួយនឹងអាទិភាពរបស់រាជរដ្ឋាភិបាល លើការអភិវឌ្ឍធនធានមនុស្ស និងការឆ្លើយតបទៅនឹងវិបត្តិជំងឺកូវីដ-១៩ ផងដែរ ។ រីឯគោលដៅដទៃទៀតទទួលបានការគាំទ្រតិចជាង ១០% នៃហិរញ្ញប្បទានសរុបដែលគាំទ្រ គ.អ.ច.ក ក្នុងនោះគោលដៅទី ១២ "ការផលិត និងការប្រើប្រាស់" និងគោលដៅទី ១៥ "ជីវិតរស់នៅលើផែនដី" បានទទួលធនធានគាំទ្រតិចជាងគេបំផុត ។

**តារាងទី ៧.១ : ការបើកផ្តល់ហិរញ្ញប្បទានតាមគោលដៅ គ.អ.ច.ក. ឆ្នាំ ២០១៩-២០២២ (លានដុល្លារ)**

| គោលដៅ | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) | 2019 | 2020 | 2021 ប៉ាន់ស្មាន | 2022 ព្យាករណ៍ | ភាគរយ ធៀបនឹងការបើកផ្តល់សរុប |
|---|---|---|---|---|---|---|
| 1 | បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង | 55 | 46 | 64 | 78 | 4% |
| 2 | បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព | 79 | 91 | 106 | 100 | 6% |
| 3 | ធានាឱ្យជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខុមាលភាពរបស់មនុស្សគ្រប់រូប និងគ្រប់វ័យ | 151 | 562 | 208 | 137 | 16% |
| 4 | ធានាការអប់រំប្រកបដោយគុណភាព បរិយាប័ន្ន និងសមធម៌ និងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិត សម្រាប់ប្រជាជនគ្រប់រូប | 113 | 120 | 91 | 127 | 7% |
| 5 | សម្រេចឱ្យបានសមភាពយេនឌ័រនិងពង្រឹកភាពអង់អាចរបស់ស្ត្រីនិងកុមារីគ្រប់រូប | 33 | 114 | 33 | 35 | 3% |
| 6 | ធានាឱ្យមានទឹកនិងអនាម័យនិងការគ្រប់គ្រងទឹកអនាម័យប្រកបដោយចីរភាពសម្រាប់ប្រជាជនគ្រប់រូប | 96 | 71 | 148 | 98 | 6% |
| 7 | ធានាឱ្យទទួលបានថាមពលដែលមានលក្ខណៈបច្ចេកទេសទំនើបប្រកបដោយចីរភាព អាចជឿជាក់បាន និងមានតម្លៃសមរម្យ សម្រាប់ប្រជាជនគ្រប់រូប | 105 | 128 | 129 | 78 | 7% |
| 8 | ធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាប័ន្ន មានមុខរបរពេញលេញ និងផលិតភាព និងមានការងារសមរម្យសម្រាប់ប្រជាជនគ្រប់រូប | 52 | 40 | 66 | 88 | 4% |
| 9 | កសាងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងបម្រែបម្រួលអាកាសធាតុ លើកកម្ពស់ឧស្សាហូបនីយកម្មប្រកបដោយចីរភាពនិងបរិយាប័ន្ន និងលើកកម្ពស់នវានុវត្តន៍ | 557 | 540 | 538 | 678 | 35% |
| 10 | កាត់បន្ថយវិសមភាពទាំងក្នុងប្រទេស និងក្នុងចំណោមបណ្តាប្រទេសនានា | 9 | 85 | 11 | 11 | 2% |
| 11 | ធ្វើឱ្យទីក្រុង និងកន្លែងតាំងទីលំនៅថ្មីសម្រាប់ប្រជាជន មានលក្ខណៈបរិយាប័ន្ន សុវត្ថិភាព ធន់នឹងបម្រែបម្រួលអាកាសធាតុ និងចីរភាព | 40 | 42 | 57 | 42 | 3% |
| 12 | ធានាឱ្យមានចីរភាពក្នុងទម្រង់នៃការប្រើប្រាស់ និងផលិតកម្ម | 6 | 6 | 8 | 7 | 0% |
| 13 | ចាត់វិធានការជាបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុ និងផលប៉ះពាល់ | 49 | 46 | 80 | 74 | 4% |
| 14 | អភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាពនូវមហាសមុទ្រ សមុទ្រ និងធនធានសមុទ្រ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព | 11 | 11 | 13 | 21 | 1% |
| 15 | ការពារ ស្តារ និងជំរុញការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូស៊ីនៅលើដែនគោក គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ប្រយុទ្ធប្រឆាំងនឹងឱនភាពដី បញ្ឈប់និងបង្វែរទិសនៃការសឹករេចរឹលគុណភាពដី និងបញ្ឈប់កុំឱ្យបាត់បង់ជីជាតិដីនិងជីវៈចម្រុះ | 7 | 4 | 3 | 3 | 0% |
| 16 | លើកកម្ពស់សង្គមដែលមានសន្តិភាពប្រកបដោយបរិយាប័ន្ន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ផ្តល់នូវការទទួលបានយុត្តិធម៌សម្រាប់ប្រជាជនគ្រប់រូបនិងកសាងស្ថាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាប័ន្ននៅគ្រប់កម្រិត | 15 | 31 | 19 | 18 | 1% |
| 17 | ពង្រឹងមធ្យោបាយអនុវត្តនានានិងបង្កើតភាពរស់រវើកនៃភាពជាដៃគូសកលសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព | 10 | 8 | 12 | 12 | 1% |
| 18 | បញ្ចប់ផលប៉ះពាល់អវិជ្ជមានរបស់មីន/សំណល់ជាតិផ្ទុះពីសង្គ្រាម និងជំរុញការសង្គ្រោះជនរងគ្រោះ | 16 | 17 | 16 | 11 | 1% |
| | **សរុប** | **1,403** | **1,960** | **1,603** | **1,617** | **100%** |

តារាងទី ៧.២ បង្ហាញអំពីការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ សម្រាប់គាំទ្រដល់ការអនុវត្ត គ.អ.ច.ក. ក្នុងឆ្នាំ ២០២១ ។ ជប៉ុនបានបើកផ្តល់ហិរញ្ញប្បទានច្រើនជាងគេ ចំនួន ៣៩៦ លានដុល្លារ ស្មើនឹង

២៥% នៃហិរញ្ញប្បទានសរុប, បន្ទាប់គឺសាធារណរដ្ឋប្រជាមានិតចិន (៣៤២ លានដុល្លារ ស្មើនឹង ២១%) និង ធនាគារអភិវឌ្ឍន៍អាស៊ី (១២៥ លានដុល្លារ ស្មើនឹង ៨%) ។ ជប៉ុនបានបើកផ្តល់ហិរញ្ញប្បទានច្រើនជាងគេ ដើម្បី គាំទ្រការអនុវត្តគោលដៅទី ៩ “ឧស្សាហកម្ម, នវានុវត្តន៍ និងហេដ្ឋារចនាសម្ព័ន្ធ” ចំនួន ១៩០ លានដុល្លារ និងគោលដៅទី ៧ “ការធានាឱ្យទទួលបានថាមពលស្អាត” ចំនួន ៦៧ លានដុល្លារ ដែលបង្ហាញអំពីការរួម ចំណែកដ៏សំខាន់ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា ។ សាធារណរដ្ឋប្រជាមានិតចិន បានបើកផ្តល់

**តារាងទី ៧.២ : ការបើកផ្តល់របស់ដៃគូអភិវឌ្ឍន៍សំខាន់ៗតាមគោលដៅ គ.អ.ច.ក. ឆ្នាំ២០២១ (លានដុល្លារ)**

| គ.អ.ច.ក | ដៃគូអភិវឌ្ឍន៍ | | | | | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | Japan | China | ADB | France | USA | Korea | World Bank | UN Agency | Australia | EU/EC | Other | |
| គ.១ | 1.40 | - | 2.62 | 1.53 | 8.04 | 13.59 | 3.51 | 8.99 | 0.23 | 12.21 | 11.61 | 63.73 |
| គ.២ | 22.05 | 10.07 | 13.16 | 0.34 | 4.64 | 13.10 | 15.86 | 12.79 | 4.04 | 2.29 | 7.65 | 106.00 |
| គ.៣ | 8.55 | 11.07 | - | 27.42 | 30.85 | 8.65 | 15.24 | 14.31 | 29.11 | - | 62.99 | 208.18 |
| គ.៤ | 16.64 | 4.14 | 11.25 | 1.55 | 8.43 | 8.84 | 8.28 | 12.78 | 6.26 | 7.30 | 5.52 | 91.01 |
| គ.៥ | 0.69 | - | 0.01 | 0.78 | 11.59 | - | - | 4.46 | 5.71 | 1.67 | 8.49 | 33.41 |
| គ.៦ | 36.97 | 3.85 | 33.46 | 52.74 | 5.69 | 0.18 | 1.76 | 6.50 | 2.43 | 4.19 | 0.57 | 148.35 |
| គ.៧ | 67.20 | 56.84 | 1.05 | 0.66 | 0.01 | - | - | 0.38 | 2.43 | 0.27 | 0.42 | 129.27 |
| គ.៨ | 7.80 | - | 7.01 | 1.10 | 11.80 | 10.91 | 2.64 | 5.83 | 4.26 | 5.65 | 9.47 | 66.47 |
| គ.៩ | 189.61 | 256.56 | 33.42 | - | 0.92 | 18.48 | 36.93 | 0.72 | - | 0.22 | 0.96 | 537.80 |
| គ.១០ | 0.24 | | 0.01 | 0.07 | 1.35 | - | - | 3.93 | 2.17 | 2.38 | 0.48 | 10.63 |
| គ.១១ | 38.01 | - | 6.72 | 2.81 | 1.44 | 5.90 | - | 1.65 | 0.07 | - | 0.16 | 56.76 |
| គ.១២ | 0.59 | - | - | 0.24 | 1.87 | 0.04 | - | 1.41 | 3.03 | - | 0.69 | 7.87 |
| គ.១៣ | 2.23 | - | 16.45 | 26.56 | 4.38 | 15.49 | 1.77 | 6.22 | - | 4.56 | 2.34 | 80.00 |
| គ.១៤ | 0.21 | - | - | 0.27 | 0.42 | - | 1.41 | 0.01 | - | 10.46 | - | 12.77 |
| គ.១៥ | 0.03 | - | - | 0.33 | 0.64 | - | - | 0.94 | - | - | 0.83 | 2.77 |
| គ.១៦ | 0.69 | - | 0.12 | 0.57 | 8.82 | 0.25 | - | 3.03 | 3.52 | 0.52 | 1.86 | 19.37 |
| គ.១៧ | - | - | - | 0.28 | 1.72 | 0.33 | - | 2.76 | 0.08 | 0.83 | 6.17 | 12.18 |
| គ.១៨ | 3.01 | - | - | - | 7.00 | 1.66 | - | 0.03 | 1.58 | - | 2.66 | 15.94 |
| **សរុប** | **395.91** | **342.53** | **125.30** | **117.25** | **109.6** | **97.42** | **87.40** | **86.74** | **64.91** | **52.55** | **122.89** | **1,603** |
| **ភាគរយធៀបនឹងការបើកផ្តល់សរុប** | **25%** | **21%** | **8%** | **7%** | **7%** | **6%** | **5%** | **5%** | **4%** | **3%** | **8%** | **100%** |

ហិរញ្ញប្បទានសម្រាប់គោលដៅទី ៩ ចំនួន ២៥៦ លានដុល្លារ និងគោលដៅទី ៧ ចំនួន ៥៧ លានដុល្លារ ដែលបានបង្ហាញអំពីធន្ទះខ្ពស់ក្នុងការគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកម្ពុជា ។ រីឯធនាគារអភិវឌ្ឍន៍អាស៊ី បានបើកផ្តល់ហិរញ្ញប្បទាន ច្រើនសម្រាប់គោលដៅទី ៦ "ទឹកស្អាត និងអនាម័យ" និងគោលដៅ ទី ៩ "ឧស្សាហកម្ម, នវានុវត្តន៍ និងហេដ្ឋារចនាសម្ព័ន្ធ" ចំនួន ៣៣ លានដុល្លារ សម្រាប់គោលដៅនីមួយៗ ក្នុងគោលដៅគាំទ្រដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទ ។ ដៃគូអភិវឌ្ឍន៍ដទៃទៀតដែលមានហិរញ្ញប្បទានចំនួន១២៣ លានដុល្លារ ស្មើនឹង ៨% នៃហិរញ្ញប្បទានសរុប បានផ្តោតការគាំទ្រភាគច្រើន ទៅលើគោលដៅទី៣ "សុខភាពល្អ និងសុខុមាលភាព" ចំនួន ៦៣ លានដុល្លារ ដែលបានបង្ហាញយ៉ាងច្បាស់អំពីការឆ្លើយតបរបស់វិស័យសុខាភិបាលទៅនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ។

## *វឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា គោលដៅទី ១៧ : ភាពជាដៃគូ*

រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាលើកកម្ពស់ស័ក្តិសិទ្ធភាពនៃកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល ។ សមិទ្ធផលសំខាន់ៗ រួមមាន ការកៀរគរធនធាន និងការតម្រឹមធនធានជាមួយអាទិភាពនៃកិច្ចអភិវឌ្ឍន៍ជាតិ, ភាពជាដៃគូប្រកបដោយបរិយាប័ន្ន និងការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ ។ ជាក់ស្តែង យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ បានបន្តសម្របសម្រួលការអនុវត្តយន្តការភាពជាដៃគូ និងបានក្តាប់យកកាលានុវត្តភាពសម្រាប់កៀរគរហិរញ្ញប្បទានសហប្រតិបត្តិការ និងពង្រឹងភាពជាដៃគូជាមួយគ្រប់ភាគីពាក់ព័ន្ធ ដើម្បីគាំទ្រការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ។ ជារួម ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន, គ.ជ.ទ/ក.អ.ក សម្រេចបានវឌ្ឍនភាពក្នុងការអនុវត្តគោលដៅទី ១៧ នៃ គ.អ.ច.ក. "ពង្រឹងមធ្យោបាយអនុវត្ត និងបង្កើតភាពរស់រវើកនៃភាពជាដៃគូ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព" ។ តារាងទី ៧.៣ បង្ហាញអំពីការសម្រេចបានតាមចំណុចដៅ និងលើសចំណុចដៅ ក្នុងការអនុវត្តរាល់សូចនាកររបស់គោលដៅទី ១៧ នេះ ។

**តារាងទី ៧.៣ : គោលដៅទី ១៧ ពង្រឹងមធ្យោបាយអនុវត្ត និងបង្កើតភាពរស់រវើកនៃភាពជាដៃគូសកល សម្រាប់កិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព**

| ចំណុចដៅ និងសូចនាករ | | ឯកតា | ចំណុចដៅនៃគោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាពកម្ពុជា | | | | | | | ជាក់ស្តែង | | | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | |
| 17.3 | កៀរគរធនធានហិរញ្ញវត្ថុបន្ថែមទៀតពីប្រភពចម្រុះ សម្រាប់ផ្តល់ដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ | | | | | | | | | | | | | | | សម្រេចបានដូចគ្រោងទុក |
| 17.3.1 | សមាមាត្រហិរញ្ញប្ប-ទានធៀបនឹង ផ.ស.ស | សមមាត្រធៀបនឹង ផ.ស.ស | 7.35 | 7.35 | 6.87 | 6.42 | 6.00 | 5.61 | 5.26 | 6.43 | 6.86 | 6.12 | 7.05 | 6.46 | 5.40 | សម្រេចបានមុនចំណុចដៅ |
| 17.9 | លើកកម្ពស់ការគាំទ្រពីអន្តរជាតិ សម្រាប់កសាងសមត្ថភាពដែលបានកំណត់ចំណុចដៅ ប្រកបដោយប្រសិទ្ធភាព ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីគាំទ្រផែនការជាតិ ក្នុងការអនុវត្តនូវគ្រប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (រួមទាំងកិច្ចសហប្រតិបត្តិការជើង-ត្បូង ,កិច្ចសហប្រតិបត្តិការត្បូង-ត្បូង និងកិច្ចសហប្រតិបត្តិការត្រីកោណ | | | | | | | | | | | | | | | សម្រេចបានដូចគ្រោងទុក |

| ចំណុចដៅ និងសូចនាករ | | ឯកតា | ចំណុចដៅនៃគោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាពកម្ពុជា | | | | | | | ជាក់ស្តែង | | | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | |
| 17.9.1 | ទំហំហិរញ្ញប្បទានសហប្រតិបត្តិការ និងកិច្ចសហប្រតិបត្តិការបច្ចេកទេស (រួមទាំងកិច្ចសហប្រតិបត្តិការត្បូង-ត្បូង និងកិច្ចសហប្រតិបត្តិការត្រីកោណបានសន្យាផ្តល់ដល់កម្ពុជា | សមមាត្រធៀបនឹង ផ.ស.ស | 1.31 | 1.31 | 1.23 | 1.15 | 1.07 | 1.00 | 0.94 | 1.53 | 1.87 | 1.45 | 1.85 | 1.44 | 0.80 | សម្រេចបានមុនចំណុចដៅ |
| 17.9.2 | ទំហំហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រគោលនយោបាយសេដ្ឋកិច្ច និងការអភិវឌ្ឍ ដែលបានប្តេជ្ញាផ្តល់ឱ្យកម្ពុជាធៀបនឹងផែនការ | សមមាត្រធៀបនឹង ផ.ស.ស | 0.03 | 0.03 | 0.02 | 0.02 | 0.02 | 0.02 | 0.02 | 0.04 | 0.05 | 0.04 | 0.04 | 0.03 | 0.02 | សម្រេចបានមុនចំណុចដៅ |
| 17.10 | លើកកម្ពស់ប្រព័ន្ធពាណិជ្ជកម្មចម្រុះ, បើកទូលាយ និងសមធម៌ ដែលមានលក្ខណៈជាសកល និងផ្អែកលើមូលដ្ឋានច្បាប់ ក្រោមអង្គការពាណិជ្ជកម្មពិភពលោក រួមទាំងតាមរយៈការបញ្ចប់ការចរចា ក្រោមរបៀបវារៈទីក្រុងដូហាស្តីពីកិច្ចអភិវឌ្ឍន៍ | | | | | | | | | | | | | | | ក្រសួងពាណិជ្ជកម្ម |
| 17.10.1 | ចំនួនច្បាប់ និងបទដ្ឋានគតិយុត្តិពាណិជ្ជកម្ម ដែលរៀបចំឡើងដើម្បីសម្រួលដល់អ្នកវិនិយោគក្នុងស្រុក និងធុរជន | ចំនួន | 7 | 7 | 7 | 8 | 8 | 8 | 9 | 7 | 7 | 7 | NA | NA | NA | ក្រសួងពាណិជ្ជកម្ម |
| 17.17.1 | ទំហំហិរញ្ញប្បទានសហប្រតិបត្តិការដែលបានសន្យាផ្តល់ឱ្យសង្គមស៊ីវិលធៀបនឹង ផ.ស.ស | សមមាត្រធៀបនឹង ផ.ស.ស | 0.01 | 0.01 | 0.01 | 0.01 | 0.01 | 0.01 | 0.01 | 0.03 | 0.03 | 0.04 | 0.05 | 0.02 | 0.02 | សម្រេចបានមុនចំណុចដៅ |

# ជំពូក ៨
# ការចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជា

កម្ពុជាត្រូវបានចាត់ទុកជាប្រទេសមួយដែលមានសេដ្ឋកិច្ចលូតលាស់ឆាប់រហ័ស ដោយសារមានកំណើនសេដ្ឋកិច្ចលឿន ។ នៅមុនឆ្នាំ ២០២០ ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ក្នុងក្របខណ្ឌនៃយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ បានជំរុញឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព លើមាគ៌ាឆ្ពោះទៅការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ។

ការរីករាលដាលនៃជំងឺកូវីដ-១៩ បានជះឥទ្ធិពលដល់គ្រប់ប្រទេសទាំងអស់ រួមទាំងកម្ពុជា ដែលនាំឱ្យកំណើនសេដ្ឋកិច្ចកម្ពុជាធ្លាក់ចុះមក -៣,១% ក្នុងឆ្នាំ ២០២០ ហើយអត្រាភាពក្រីក្របានកើនឡើងដល់ ១៧.៨% ដោយសារផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើចន្ទល់នៃកំណើនសេដ្ឋកិច្ច (វិស័យកម្មន្តសាល, កសិកម្ម និងទេសចរណ៍) គួបផ្សំនឹងការផ្លាស់ប្តូរវិធីសាស្ត្រគណនាថ្មីនៃអត្រាភាពក្រីក្រ ។ ឆ្លើយតបទៅនឹងបញ្ហាប្រឈមនេះ, រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការឆ្លើយតប សម្រាប់ទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងគោលដៅរក្សាបាននូវចលនការសម្រាប់ដំណើរការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ។

រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវផែនការស្តារសង្គម-សេដ្ឋកិច្ចកម្ពុជាឡើងវិញ ស្របតាមអភិក្រម "ទូទាំងសង្គម" ដើម្បីជំរុញឱ្យសេដ្ឋកិច្ចកម្ពុជាត្រឡប់មកស្ថានភាពដើមវិញ ។ កិច្ចប្រឹងប្រែងនេះបានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាងើបឡើងវិញក្នុងកំណើន ៣% ក្នុងឆ្នាំ២០២១ ។ ប្រការនេះបានធ្វើឱ្យកម្ពុជាសម្រេចបាននូវលក្ខខណ្ឌវិនិច្ឆ័យសម្រាប់ចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចដោយសារកម្ពុជាសម្រេចបានកម្រិតចំណូលជាតិសម្រាប់ប្រជាជនម្នាក់ ១ ៣៧៧ ដុល្លារ, សន្ទស្សន៍នៃការអភិវឌ្ឍធនធានមនុស្ស ៧៤,៣ និង សន្ទស្សន៍នៃភាពងាយរងគ្រោះខាងសេដ្ឋកិច្ច ៣០,៦ ។

**តារាងទី ៨.១: លក្ខខណ្ឌវិនិច្ឆ័យសម្រាប់កម្ពុជាចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច**

| លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ការចាកចេញ | ពិន្ទុកំណត់ ឆ្នាំ២០២១ | កម្ពុជា |
|---|---|---|
| ចំណូលជាតិសម្រាប់ប្រជាជនម្នាក់ | ១.២២២ ដុល្លារ ឬ ខ្ពស់ជាង | ១.៣៧៧ ដុល្លារ |
| ការអភិវឌ្ឍធនធានមនុស្ស | ៦៦ ឬ ខ្ពស់ជាង | ៧៤,៣ |
| ភាពងាយរងគ្រោះខាងសេដ្ឋកិច្ច | ៣២ ឬ ទាបជាង | ៣០,៦ |

យោងតាមលក្ខខណ្ឌវិនិច្ឆ័យទាំង ៣ នេះ, កម្ពុជាត្រូវបានសម្រេចដាក់បញ្ចូលក្នុងបញ្ជីប្រទេសសម្រាប់ការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច នៅកិច្ចប្រជុំត្រួតពិនិត្យរបស់គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ ក្នុងឆ្នាំ ២០២១ ។ ផ្អែកលើវឌ្ឍនភាពទាំងនេះ កម្ពុជារំពឹងថានឹងបន្តសម្រេចបានលក្ខខណ្ឌវិនិច្ឆ័យក្នុងកិច្ចប្រជុំត្រួតពិនិត្យលើកទី ២ ម្តងទៀត ក្នុងឆ្នាំ២០២៤ ។ បន្ទាប់ពីកិច្ចប្រជុំត្រួតពិនិត្យលើកទី ២ និងការអនុម័តពីមហាសន្និបាតអង្គការសហប្រជាជាតិ នាឆ្នាំបន្ទាប់ ប្រទេសបេក្ខភាពនីមួយៗ រួមទាំងកម្ពុជាផងដែរអាចមានរយៈពេលអន្តរកាល ៣ឆ្នាំ មុននឹងការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចត្រូវប្រកាសជាផ្លូវការ ។ ប្រទេសនីមួយៗអាចបន្តទទួលបានការគាំទ្រ និងភាពអនុគ្រោះរយៈពេល ៣ឆ្នាំបន្ថែម

ទៀត ដើម្បីធានាថាប្រទេសនោះមិនធ្លាក់ចូលក្នុងក្រុមប្រទេសអភិវឌ្ឍន៍តិចតួចម្តងទៀតឡើយ ។ ផ្អែកលើសេណារីយ៉ូនេះ កម្ពុជាអាចឆ្លងផុតពីប្រទេសអភិវឌ្ឍន៍តិចតួច ក្នុងឆ្នាំ ២០២៧ និងរយៈពេលអន្តរកាលអាចបន្តរហូតដល់ឆ្នាំ ២០៣០ ។

**តារាងទី ៨.២: សង្ខេបស្តីពីវឌ្ឍនភាពរបស់កម្ពុជាក្នុងដំណើរចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច**

| | |
|---|---|
| **ឆ្នាំ០ កិច្ចប្រជុំត្រួតពិនិត្យលើកទីមួយ (២០២១)** | គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិបានពិនិត្យវឌ្ឍនភាព និងប្រកាសដាក់កម្ពុជាចូលក្នុងបញ្ជីចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ក្នុងខែកុម្ភៈ ឆ្នាំ២០២១ (លទ្ធផលលើកទី១) |
| **ឆ្នាំ០-៣ (២០២១-២០២៤)** | ដំណាក់កាលប្រមូលព័ត៌មាន និងការរៀបចំនានា **(កម្ពុជានាបច្ចុប្បន្ន)** |
| **ឆ្នាំ៣ កិច្ចប្រជុំត្រួតពិនិត្យបន្ទាប់ (២០២៤)** | គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិពិនិត្យវឌ្ឍនភាពនៃលក្ខខណ្ឌវិនិច្ឆ័យ (លទ្ធផលលើកទី២) និងស្នើទៅ ECOSOC ដើម្បីពិនិត្យ (បន្ទាប់មក មហាសន្និបាតរបស់អង្គការសហប្រជាជាតិ ផ្តល់ការអនុម័ត) |
| **ឆ្នាំ៣-៦ (២០២៤-២០២៧)** | ដំណាក់កាលត្រៀម និងការរៀបចំយុទ្ធសាស្ត្រអន្តរកាល |
| **ឆ្នាំ៦ (២០២៧)** | ការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចត្រូវបានប្រកាសជាផ្លូវការ និងការចាប់ផ្តើមនូវដំណាក់កាលអន្តរកាល |
| **បន្ទាប់ពីឆ្នាំ៦ (២០២៧ តទៅ)** | ដំណាក់កាលអនុវត្តយុទ្ធសាស្ត្រអន្តរកាល ដោយធានាបានការបន្តទទួលបានការគាំទ្រ និងភាពអនុគ្រោះនានា |

- ចាប់ផ្តើមការរៀបចំសម្រាប់ដំណើរការចាកចេញ ដោយមានការគាំទ្រពីការិយាល័យសម្របសម្រួលអង្គការសហប្រជាជាតិ
- ពង្រឹងការយល់ដឹងអំពីដំណើរការ, ផលប៉ះពាល់ និងតាមដានវឌ្ឍនភាព (ដោយគិតគូរអំពីផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងវិបត្តិដទៃទៀត)
- រៀបចំរបាយការណ៍វាយតម្លៃផលប៉ះពាល់ (UNDESA) និងរបាយការណ៍ស្ថានភាពងាយរងគ្រោះ (UNCTAD)

បន្ទាប់ពីឆ្នាំនេះទៅ, ការយល់ដឹងអំពីការចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជា តម្រូវឱ្យរៀបចំយុទ្ធសាស្ត្រជាតិស្តីពីអន្តរកាលប្រកបដោយភាពរលូន ដើម្បីជួយសម្រួលដំណើរការរៀបចំឆ្ពោះទៅរកការវាយតម្លៃម្តងទៀតក្នុងឆ្នាំខាងមុខ សម្រាប់សម្រេចដាក់បញ្ចូលក្នុងបញ្ជីចាកចេញជាលើកទី ២ និងជាមូលដ្ឋានផ្តល់លក្ខខណ្ឌគ្រប់គ្រាន់ដល់កម្ពុជា ក្នុងការចាកចេញជាផ្លូវការពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ។

ការអូសបន្លាយនៃជំងឺកូវីដ-១៩ ពិសេសការលេចឡើងនៃមេរោគកូវីដ-១៩ បំប្លែងថ្មី បានជះឥទ្ធិពលដល់ដំណើរការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ។ ចំពោះកម្ពុជា, លក្ខខណ្ឌវិនិច្ឆ័យទាំង ៣ សម្រាប់ការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច នឹងត្រូវទទួលរងផលប៉ះពាល់ ។ ក្នុងបរិការណ៍នៃជំងឺកូវីដ-១៩, ការអភិវឌ្ឍធនធានមនុស្សត្រូវរងផលប៉ះពាល់ដោយផ្ទាល់ ដោយសារជំងឺកូវីដ-១៩ បានប៉ះពាល់ដល់គ្រប់ផ្នែកនៃប្រព័ន្ធសុខាភិបាល ។ ជំងឺកូវីដ-១៩ នេះ ក៏បានប៉ះពាល់ដល់ផលិតភាពសេដ្ឋកិច្ច, ការវិនិយោគ និងពាណិជ្ជកម្ម ដែលសុទ្ធសឹងតែអាចជះឥទ្ធិពលដល់ចំណូលជាតិសរុប ។ បញ្ហាប្រឈមនេះនឹងនាំទៅដល់វិសមភាពនៃកម្រិតជីវភាពរស់នៅ, ប្រាក់ចំណូល, ការអប់រំ និងការទទួលបានឱកាសនានាសម្រាប់ការស្តារឡើងវិញឱ្យបានដល់កម្រិតមុនវិបត្តិជំងឺកូវីដ-១៩ ។

*ផលបច្ច័យនៃការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជា*

ការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច នឹងមានផលប៉ះពាល់ដល់វិធានការគាំទ្រអន្តរជាតិ ដែលពាក់ព័ន្ធនឹងហិរញ្ញប្បទានសហប្រតិបត្តិការ និងពាណិជ្ជកម្ម ។ ខ្លឹមសារសង្ខេបអំពីផលចំណេញ និងការខាតបង់ ដែលកើតឡើងដោយសារការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច មានដូចខាងក្រោម ។

**តារាងទី ៨.៣: ផលចំណេញ និងការខាតបង់នៃការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច**

| ប្រទេសអភិវឌ្ឍន៍តិចតួចទទួលបាន | ផលចំណេញនៃការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច | ការខាតបង់នៃការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច |
|---|---|---|
| ការទទួលបានវិធានការគាំទ្រអន្តរជាតិពាក់ព័ន្ធនឹងហិរញ្ញប្បទានសហប្រតិបត្តិការ និងពាណិជ្ជកម្ម | កិត្យានុភាពជាតិលើឆាកអន្តរជាតិ និងការទទួលស្គាល់អំពីសមិទ្ធផលជាតិ | បាត់បង់វិធានការគាំទ្រអន្តរជាតិផ្នែកពាណិជ្ជកម្ម÷ ការអនុគ្រោះពន្ធនាំចូលទីផ្សារ (ការអនុគ្រោះពន្ធ និងការមិនកំណត់កូតាទំនិញនាំចូល, ប្រព័ន្ធអនុគ្រោះទូទៅ, ភាពបត់បែនចំពោះវិធានការប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក) |
| វិធានការគាំទ្រអន្តរជាតិ ផ្នែកពាណិជ្ជកម្ម÷ ការអនុគ្រោះនាំចេញទៅកាន់ទីផ្សារ, លក្ខខណ្ឌ និងភាពអនុគ្រោះជាក់លាក់, ជំនួយបច្ចេកទេសផ្នែកពាណិជ្ជកម្ម, ការចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក | សញ្ញាណវិជ្ជមានបង្ហាញពីបរិយាកាសអំណោយផលដល់ការវិនិយោគ និងហេដ្ឋារចនាសម្ព័ន្ធរឹងមាំ | បាត់បង់ភាពអនុគ្រោះ (បទបញ្ញត្តិនៃអង្គការពាណិជ្ជកម្មពិភពលោក, កិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា និងពាណិជ្ជកម្ម, ការបំពេញខាតក្នុងការនាំចេញ) |
| ជំនួយបច្ចេកទេស÷ កិច្ចសហប្រតិបត្តិការបច្ចេកទេសសម្រាប់ជំរុញពាណិជ្ជកម្ម, ហិរញ្ញប្បទានសម្រាប់ពាណិជ្ជកម្ម | សញ្ញាណវិជ្ជមានបង្ហាញពីស្ថិរភាពនយោបាយ | លទ្ធភាពកាត់បន្ថយហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូទ្វេភាគី និងពហុភាគី |
| វិធានការគាំទ្រអន្តរជាតិ ផ្នែកបច្ចេកវិទ្យា÷ ហិរញ្ញប្បទានសម្រាប់វិទ្យាសាស្ត្រ, បច្ចេកវិទ្យា និងនវានុវត្តន៍, កិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា និងពាណិជ្ជកម្ម (TRIPs TRIMs), ការផ្ទេរបច្ចេកវិទ្យាពាក់ព័ន្ធនឹងការប្រែប្រួលអាកាស | សញ្ញាណវិជ្ជមានបង្ហាញពីគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដែលអាចទស្សន៍ទាយបាន និងការប្តេជ្ញាចិត្តឆ្ពោះទៅការអភិវឌ្ឍប្រកបដោយចីរភាព | បាត់បង់លទ្ធភាពចូលរួមក្នុងយន្តការជាក់លាក់ (បច្ចេកវិទ្យាធនាគារ, កិច្ចសហប្រតិបត្តិការបច្ចេកទេសសម្រាប់ជំរុញពាណិជ្ជកម្ម, ហិរញ្ញប្បទានសម្រាប់ពាណិជ្ជកម្ម) |
| វិធានការគាំទ្រអន្តរជាតិទូទៅដទៃ÷ ការរួមចំណែក ក្នុងអង្គការអន្តរជាតិ, ការធ្វើដំណើរ និងការស្រាវជ្រាវ | វិហូរវិនិយោគផ្ទាល់ពីបរទេសកាន់តែកើនឡើង | បាត់បង់លទ្ធភាពទទួលការគាំទ្រជាក់លាក់ដទៃទៀតសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច (ជំនួយថវិកាអង្គការសហប្រជាជាតិ, ការគាំទ្រលើការធ្វើដំណើរ |

ក្នុងឋានៈប្រទេសអភិវឌ្ឍន៍តិចតួច, កម្ពុជាទទួលបានផលប្រយោជន៍ពីវិធានការគាំទ្រអន្តរជាតិ ដែលរួមមាន÷ ផ្នែកហិរញ្ញប្បទានសហប្រតិបត្តិការ និងពាណិជ្ជកម្ម និងជំនួយបច្ចេកទេស ។ ការផ្លាស់ប្តូរឋានៈនេះនឹងអាចបាត់បង់ជាបណ្តើរៗនូវវិធានការគាំទ្រអន្តរជាតិ ដែលអាចឈានទៅដល់ការកាត់បន្ថយហិរញ្ញប្បទានសហប្រតិបត្តិការ និងលក្ខខណ្ឌសម្បទាននៃហិរញ្ញប្បទាន ។ ការផ្តល់ភាពអនុគ្រោះជាក់លាក់ និងការគាំទ្រសម្រាប់ចូលរួមកិច្ចប្រជុំអន្តរជាតិនានា ក៏ត្រូវបាត់បង់ក្រោយការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ។

ខណៈដែលកម្ពុជាទទួលបានផលប្រយោជន៍ពីវិធានការគាំទ្រអន្តរជាតិ ក្នុងឋានៈប្រទេសអភិវឌ្ឍន៍តិចតួច, ការចាកចេញពីចំណាត់ថ្នាក់ក្រុមប្រទេសនេះនាពេលអនាគត នឹងនាំដល់ការបាត់បង់ផលប្រយោជន៍ទាំងនេះ ប៉ុន្តែស្ថានភាពល្អប្រសើរនៃសេដ្ឋកិច្ចក៏អាចទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសផងដែរ ។ លើមូលដ្ឋាននេះ រាជរដ្ឋាភិបាល បានគិតគូរអំពីវិធានការសម្រាប់ជួយសម្រាលការខាតបង់ដែលអាចកើតមានឡើងក្រោយពេលដែលកម្ពុជាបានចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ។

ក្នុងន័យនេះ រាជរដ្ឋាភិបាល បានប្រឹងប្រែងចរចារជាមួយដៃគូពាណិជ្ជកម្ម ដើម្បីពង្រីកវិសាលភាពនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដោយផ្អែកលើភាពអំណោយផលរបស់កម្ពុជាសម្រាប់ការវិនិយោគ ។ កិច្ចព្រម-ព្រៀងពាណិជ្ជកម្មសេរី កម្រិតទ្វេភាគី និងកម្រិតតំបន់ ដូចជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ និងកិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ រំពឹងថា នឹងនាំមកនូវផលប្រយោជន៍យ៉ាងច្រើនដែលអាចទូទាត់ជំនួសការខាតបង់ដែលបណ្តាលមកពីការថយចុះនៃកម្រិតសម្បទាននៃហិរញ្ញប្បទានសហប្រតិបត្តិការ ។ ដូច្នេះ រាជរដ្ឋាភិបាលនឹងបន្តតម្រង់ទិស និងសម្របសម្រួលគោលនយោបាយជាតិ និងវិធានការគាំទ្រអន្តរជាតិ ដោយផ្តោតលើសង្គតិភាព និងភាពស៊ីចង្វាក់គ្នាក្នុងផ្នែកពាណិជ្ជកម្ម, ហិរញ្ញវត្ថុ, បច្ចេកវិទ្យា និងការអភិវឌ្ឍសមត្ថភាព ។

***ផែនទីចង្អុលផ្លូវសម្រាប់ការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច***

ស្ថិតក្នុងបរិការណ៍នៃប្រទេសអភិវឌ្ឍន៍តិចតួច, កម្មវិធីសកម្មភាពទីក្រុងអ៊ីស្តង់ប៊ុល (២០១១-២០២០) ដែលបានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដើម្បីធានាសង្គតិភាពផ្នែកគោលនយោបាយនៃការអភិវឌ្ឍប្រកបដោយចីរភាព បានកំណត់គោលដៅដើម្បីជួយសម្រួល និងគាំទ្រដល់ក្រុមប្រទេសអភិវឌ្ឍន៍តិចតួចឱ្យសម្រេចបាននូវលក្ខខណ្ឌវិនិច្ឆ័យក្នុងការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច នាត្រឹមឆ្នាំ ២០២០ ។ ក្នុងការត្រួតពិនិត្យការអនុវត្តកម្មវិធីសកម្មភាពទីក្រុងអ៊ីស្តង់ប៊ុលនេះ កម្ពុជាត្រូវបានវាយតម្លៃថាបានសម្រេចសមិទ្ធកម្មសេដ្ឋកិច្ចល្អប្រសើរ មុនពេលការរីករាលដាលនៃជំងឺកូវីដ-១៩ ។

កម្មវិធីសកម្មភាពទីក្រុងដូហា (២០២១-២០៣០) ដែលកំពុងត្រូវបានរៀបចំ គឺជាផែនទីចង្អុលផ្លូវក្នុងការគាំទ្រក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ដើម្បីកំណត់ការងារដែលត្រូវប្រឈមដោះស្រាយ ។ ជាក់ស្តែង កម្មវិធីសកម្មភាពទីក្រុងដូហា បានរំលេចអំពីស្ថានភាពងាយរងគ្រោះរបស់ក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ដែលអាចរារាំងដល់ការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជា នាកិច្ចប្រជុំត្រួតពិនិត្យក្នុងឆ្នាំ ២០២៤ ។ ក្នុងន័យនេះ ការកាត់បន្ថយភាពងាយរងគ្រោះ និងការកសាងភាពធន់ នឹងក្លាយជាមូលដ្ឋានគ្រឹះចាំបាច់សម្រាប់អនុវត្តកម្មវិធីសកម្មភាពទីក្រុងដូហា ។ លើសពីនេះ ការរៀបចំយន្តការជាតិ ដូចជាគណៈកម្មាធិការជាតិ ឬក្រុមការងារទទួលបន្ទុកការត្រៀមចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជា គឺជាការចាំបាច់ដើម្បីកំណត់តម្រូវការជាក់លាក់ ក្នុងការអនុវត្តសកម្មភាពនាពេលអនាគត ។

ទោះជាយ៉ាងនេះក្តី, ស្ថានភាពនៃជំងឺកូវីដ-១៩ ដែលកំពុងអូសបន្លាយ បានក្លាយជាការបញ្ហាព្រួយបារម្ភដែលអាចប៉ះពាល់ដល់វឌ្ឍនភាពរបស់កម្ពុជាក្នុងការអនុវត្តកម្មវិធីសកម្មភាពថ្មីនេះ ។ ក្នុងន័យនេះ ការរៀបចំផែនទីចង្អុលផ្លូវប្រកបដោយភាពយកចិត្តទុកដាក់ខ្ពស់ នឹងត្រួសត្រាយផ្លូវសម្រាប់កម្ពុជាឆ្ពោះទៅវឌ្ឍនភាពល្អ

ប្រសើរសម្រាប់ការត្រួតពិនិត្យលើកទី២ និងការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចប្រកបដោយជោគជ័យនាពេលអនាគត ។

កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការស្តារសេដ្ឋកិច្ចឡើងវិញប្រកបដោយបរិយាប័ន្ន, ភាពធន់ និងចីរភាព ព្រមទាំងការគាំទ្រពីសហគមន៍អន្តរជាតិ បានក្លាយជាសសរស្តម្ភអាទិភាពរបស់ផែនទីចង្អុលផ្លូវនេះ ។ ប្រការនេះអាចបញ្ជាក់ថា ទោះបីទម្រង់ហិរញ្ញប្បទានសហប្រតិបត្តិការបានប្រែប្រួលពីហិរញ្ញប្បទានឥតសំណងទៅជាឥណទានសម្បទានកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅតែបន្តដើរតួនាទីសំខាន់ សម្រាប់គាំទ្ររាជរដ្ឋាភិបាលក្នុងដំណើរឆ្ពោះទៅការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច និងការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារសេដ្ឋកិច្ចកម្ពុជា ក្រោយវិបត្តិជំងឺកូវីដ-១៩ ។

***គោលនយោបាយសំខាន់ៗ***

ទោះបីការអូសបន្លាយ ឬការបន្តឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច ដែលត្រូវពឹងអាស្រ័យទៅលើឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលយ៉ាងណាក៏ដោយ, ក៏ទស្សនៈវិស័យសេដ្ឋកិច្ចរយៈពេលខ្លី និងមធ្យម គឺជាកត្តាសំខាន់សម្រាប់បន្តជំរុញកំណើនសេដ្ឋកិច្ច និងកសាងភាពធន់សម្រាប់ប្រទេសជាតិ ។ ខណៈដែលផែនទីចង្អុលផ្លូវ ជាត្រីវិស័យដែលអាចជួយកំណត់ជំហានសំខាន់ៗ, អនុសាសន៍ខាងគោលនយោបាយ និងវិស័យអាទិភាពនៅតែមានសារៈសំខាន់ ដើម្បីកាត់បន្ថយហានិភ័យផ្នែកសេដ្ឋកិច្ច និងជួយតម្រង់កម្ពុជាឱ្យស្ថិតលើមាគ៌ានៃការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចប្រកបដោយចីរភាព។

**ការវិនិយោគលើមូលធនមនុស្ស :** ការពង្រឹងគុណភាពនៃមូលធនមនុស្ស គឺជាការងារអាទិភាព ពិសេសវិស័យសុខភាពសាធារណៈ និងវិស័យអប់រំ ក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ-១៩ ។ ទន្ទឹមនឹងនេះ, ការពង្រីកវិសាលភាពក្នុងវិស័យគាំពារសង្គម អាចជួយកាត់បន្ថយភាពងាយរងគ្រោះដែលបង្កឡើងដោយវិបត្តិសកលនេះ ។ ឈរលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការគាំទ្រជនងាយរងគ្រោះ តាមរយៈការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម និងក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ដោយផ្អែកលើសសរស្តម្ភ ៣ គឺការកែទម្រង់, ការស្តារ និងការកសាងភាពធន់ ដើម្បីវិនិយោគលើការអភិវឌ្ឍធនធានមនុស្ស ។

**គោលនយោបាយឧស្សាហកម្ម :** រាជរដ្ឋាភិបាលបានខិតខំជម្នះដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធ តាមរយៈការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ដូចមានបញ្ជាក់ក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥ ។ មជ្ឈមណ្ឌលឧស្សាហកម្ម, របៀងសេដ្ឋកិច្ច និងប៉ូលសេដ្ឋកិច្ច នឹងជួយជំរុញការតភ្ជាប់សេដ្ឋកិច្ចក្នុងស្រុក សំដៅបន្តជំរុញភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា ។ម្យ៉ាងទៀត ការលើកកម្ពស់សហគ្រាសខ្នាតមីក្រូ, ខ្នាតតូច និងមធ្យម ដែលដើរតួនាទីសំខាន់ក្នុងសេដ្ឋកិច្ចជាតិនឹងបង្កើតបរិយាកាសអំណោយផលដល់ការធ្វើអាជីវកម្ម និងការជំរុញកំណើនការងារ ។

**ហេដ្ឋារចនាសម្ព័ន្ធ និងភ័ស្តុភារកម្ម :** កំណើនប្រកបដោយចីរភាព និងភាពធន់ ទាមទារហេដ្ឋារចនា-សម្ព័ន្ធ និងភស្តុភារកម្មប្រកបដោយគុណភាព ។ ដូច្នេះ ការអភិវឌ្ឍស្ពាន, ផ្លូវថ្នល់ និងប្រព័ន្ធទំនាក់ទំនង ក៏ដូចជា

ហេដ្ឋារចនាសម្ព័ន្ធដទៃទៀត ដែលធន់នឹងការប្រែប្រួលអាកាសធាតុ ដែលជាផ្នែកមួយនៃការកសាងសមត្ថភាពផលិតកម្ម នឹងជួយលើកកម្ពស់ភាពប្រកួតប្រជែងសេដ្ឋកិច្ចកម្ពុជា ។

**ពិពិធកម្មសេដ្ឋកិច្ច** : សកម្មភាពឧស្សាហកម្មកម្ពុជា ដែលធ្លាប់បានផ្តោតខ្លាំងលើអតិពលកម្ម និងមានតម្លៃបន្ថែមទាប បានបន្ទុចបង្អាក់ការធ្វើទំនើបកម្មឧស្សាហកម្ម ។ សក្តានុពលសម្រាប់លើកកម្ពស់ពិពិធកម្មសេដ្ឋកិច្ច ត្រូវបានរំខានដោយការកើនឡើងនៃថ្លៃឈ្នួលពលកម្ម និងមូលធនមនុស្សនៅមានកម្រិត ក៏ដូចជាការចំណាយខ្ពស់លើថ្លៃអគ្គិសនី និងដឹកជញ្ជូន ។ ឧស្សាហូបនីយកម្មគឺជាមូលដ្ឋានចាំបាច់សម្រាប់លើកកម្ពស់ពិពិធកម្ម និងភាពប្រកួតប្រជែងនៅគ្រប់វិស័យ ។ ក្នុងន័យនេះ លទ្ធភាពជំរុញកំណើនឧស្សាហកម្មត្រូវពឹងផ្អែកលើការវិនិយោគបន្ថែមក្នុងការលើកកម្ពស់ការនាំចេញ និងការធ្វើពិពិធកម្មផលិតផលឧស្សាហកម្ម ដែលទាំងនេះអាចសម្រេចបាន តាមរយៈការពង្រីកបន្ថែមនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ។

រាជរដ្ឋាភិបាលបានប្រឹងប្រែងក្នុងភាពបុរេសកម្ម ដើម្បីឈានទៅសម្រេចកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន, កិច្ចព្រមព្រៀងពាណិជ្ជកម្មកម្ពុជា-កូរ៉េ និងកិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ និងបន្តពិគគ្រោះចរចាដើម្បីបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយសហភាពសេដ្ឋកិច្ចអឺរ៉ាស៊ី ដែលរំពឹងថានឹងអាចទាក់ទាញការវិនិយោគឯកជន រួមទាំងការវិនិយោគផ្ទាល់ពីបរទេស បានកាន់តែច្រើន ។ ការវិនិយោគ ឯកជននឹងផ្តល់កាលានុវត្តភាពសម្រាប់ចាកចេញពីភាពក្រីក្រ ក៏ដូចជាប្រែក្លាយពីភាពងាយរងគ្រោះទៅជាភាពរឹងមាំខាងពាណិជ្ជកម្ម ។ តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី, កម្ពុជាអាចពង្រីកទីផ្សារបន្ថែមទៀត ក្រៅពីទីផ្សារ សហភាពអឺរ៉ុប និងទីផ្សារអាមេរិកដែលបច្ចុប្បន្ន គឺជាទីផ្សារនាំចេញធំជាងគេរបស់កម្ពុជា ។ ទោះជាយ៉ាងនេះក្តី ក៏ដំណើរការនៃការធ្វើពិពិធកម្មសេដ្ឋកិច្ចកម្ពុជានៅតែប្រឈមជាមួយនឹងបញ្ហា ដែលពាក់ព័ន្ធនឹងសមត្ថភាពផ្នែក បច្ចេកវិទ្យាដែលនៅមានកម្រិត និងការអភិវឌ្ឍជំនាញថ្មី ។

